# នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
# នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

## ព័ត៌មានពិស្តារនៃការដាក់ឯកសារ

សំណុំរឿងលេខ : ០០២/១៩-០៩-២០០៧-អវតក/អជសដ
ដាក់ទៅ : អង្គជំនុំជម្រះសាលាដំបូង
ថ្ងៃដាក់ : ថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៣
ភាគីអ្នកដាក់ : សហព្រះរាជអាជ្ញា
ភាសាដើម : អង់គ្លេស

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 27-May-2013, 16:00
CMS/CFO: Sann Rada

## ចំណាត់ថ្នាក់ឯកសារ

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: **សាធារណៈ ជាមួយឧបសម្ព័ន្ធសម្ងាត់ ក និង ខ**

ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះសាលាដំបូង: សាធារណៈ/Public

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យឯកសារបណ្តោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

## ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញានៅនឹងសេចក្តីជូនដំណឹងរបស់មេធាវីការពារក្តី ចំពោះការទទួលយកកំណត់ហេតុសាក្សី ពាក្យបណ្តឹង និងប្រតិចារឹក

---

**អ្នកដាក់ឯកសារ:**

សហព្រះរាជអាជ្ញា:
លោកស្រី ជា លាង
លោក Andrew CAYLEY

**អ្នកទទួលឯកសារ:**

អង្គជំនុំជម្រះសាលាដំបូង:
ចៅក្រម និល ណុន, ប្រធាន
ចៅក្រម Silvia CARTWRIGHT
ចៅក្រម យ៉ា សុខន
ចៅក្រម Jean-Marc LAVERGNE
ចៅក្រម យូ ឧត្តរា

សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី:
ពេជ អង្គ
Elisabeth SIMONNEAU FORT

**ចម្លងជូន:**

ជនជាប់ចោទ:
នួន ជា
ខៀវ សំផន

ក្រុមមេធាវីការពារក្តី:
លោក សុន អរុណ
លោក Victor KOPPE
លោក គង់ សំអុន
Anta GUISSE
Arthur VERCKEN
Jacques VERGES

## ផ្នែក I - សេចក្ដីផ្ដើម

១. សហព្រះរាជអាជ្ញា ធ្វើការឆ្លើយតបទៅនឹងការជំទាស់ដែលលើកឡើងដោយមេធាវីការពារក្ដី ខៀវ សំផន[1] និង នួន ជា[2] ចំពោះការទទួលយកកំណត់ហេតុស្ដាប់សាក្សី និងពាក្យបណ្ដឹងដែលបានចុះបញ្ជី នៅក្នុងឧបសម្ព័ន្ធ ១២ និង១៣ ដែលបានកែសម្រួលឡើងវិញរបស់សហព្រះរាជអាជ្ញា ព្រមទាំងប្រតិចារឹកនៃសំណុំរឿង 00១ ដូចបានកំណត់នៅក្នុងឧបសម្ព័ន្ធ ១១។ សហព្រះរាជអាជ្ញា បង្រួមប្រវត្តិនីតិវិធីតាមរយៈសេចក្ដីយោង ដូចមានចែងក្នុងសេចក្ដីសន្និដ្ឋានរបស់ខ្លួន ចុះថ្ងៃទី៩ ខែមេសា ឆ្នាំ២0១៣[3] ដែលមានឧបសម្ព័ន្ធ១២ និង១៣ ដែលបានកែសម្រួលឡើងវិញ។

២. កម្លាំងជំរុញចំពោះសេចក្ដីសន្និដ្ឋានផ្លូវច្បាប់របស់មេធាវីការពារក្ដី គឺថា អង្គជំនុំជម្រះសាលាដំបូង មានការភ័ន្តច្រឡំនៅក្នុងការបកស្រាយរបស់ខ្លួនអំពីគោលការណ៍នានា ដែលគ្រប់គ្រងទៅលើការ ទទួលយកភ័ស្ដុតាងសក្ខីកម្មជាលាយល័ក្ខណ៍អក្សរ នៅក្នុងសេចក្ដីសម្រេចរបស់ខ្លួន ចុះថ្ងៃទី២0 ខែ មិថុនា ឆ្នាំ២0១២[4] ("សេចក្ដីសម្រេចស្ដីពីកំណត់ហេតុ")។ មេធាវីការពារក្ដីស្វែងរកយ៉ាងមាន ប្រសិទ្ធិភាពនូវការពិចារណាឡើងវិញចំពោះសេចក្ដីសម្រេចស្ដីពីកំណត់ហេតុ។ ពួកគេជាអ្នកធ្វើឱ្យ ការបកស្រាយកាន់តែរីកធំឡើងអំពីការសាកល្បងនៃ "អំពើ និងការប្រព្រឹត្ដ" អនុវត្តនៅក្រោមវិធាន ៩២*ស្ទួន*(ក) នៃតុលាការ*ពិសេស* នានា។ ពួកគេក៏ទទូចឱ្យមានការអនុវត្ត និងការពង្រីកជាសំខាន់ នូវល័ក្ខណវិនិច្ឆ័យនៃវិធាន៩២*ស្ទួន*(គ) ផងដែរ ដែលតម្រូវឱ្យមានការពិចារណាដាច់ដោយឡែក មួយថាតើ ម្ចាស់កំណត់ហេតុជាលាយល័ក្ខណ៍អក្សរទាំងអស់ គួរត្រូវបានកោះហៅមកដេញដោល

---

[1] **E277** សេចក្ដីសន្និដ្ឋានអនុលោមតាមវិធាន ៩២ អំពីច្បាប់អនុវត្តលើការទទួលយកជាភ័ស្ដុតាងនូវកំណត់ហេតុស្ដាប់ចម្លើយ ជំនួសឱ្យសក្ខីកម្មផ្ទាល់មាត់, ១0 មេសា ២0១៣ ('**E277** សេចក្ដីសន្និដ្ឋានរបស់ ខៀវ សំផន ស្ដីពីច្បាប់ជាធរមាន'); **E208/5** សេចក្ដីជំទាស់របស់ ខៀវ សំផន ទៅនឹងការដាក់បញ្ចូលក្នុងកិច្ចពិភាក្សានូវសក្ខីកម្ម ជាលាយលក្ខណ៍អក្សរមួយចំនួនដែលស្នើដោយសហព្រះរាជអាជ្ញា និងដើមបណ្ដឹងរដ្ឋប្បវេណី ជំនួសឱ្យសក្ខីកម្មផ្ទាល់មាត់, ២៦ មេសា ២0១៣ ('**E208/5** សេចក្ដីជំទាស់របស់ ខៀវ សំផន)។

[2] **E96/8/1** ការឆ្លើយតបជាបឋមទៅនឹងសំណើបន្ថែមរបស់សហព្រះរាជអាជ្ញា សុំដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងនូវកំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី និងប្រតិចារិត, ៨ វិច្ឆិកា ២0១២ ('**E96/8/1** អញ្ញត្រកម្មរបស់ នួន ជា); **E223/2/8** ការជំទាស់ទៅនឹងសំណើសុំដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងនូវកំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី និងប្រតិចារិត, ២៦ មេសា ២0១៣ ('**E223/2/8** ការជំទាស់របស់ នួន ជា ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២0១៣'); **E223/2/8/1** ឧបសម្ព័ន្ធបន្ថែមពាក់ព័ន្ធនឹងការជំទាស់ទៅនឹងកំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សីនិងប្រតិចារឹកនានា, ២៩ មេសា ២0១៣។

[3] **E278** សេចក្ដីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា អំពីឧបសម្ព័ន្ធទី ១២ និងទី ១៣ ដែលបានកែសម្រួលឡើងវិញ ក្នុងបញ្ជីឯកសារសម្រាប់សវនាការរបស់ខ្លួន អនុលោមតាមវិធាន៨0(៣) (កំណត់ហេតុស្ដាប់ចម្លើយសាក្សី និងពាក្យបណ្ដឹង), ៩ មេសា ២0១៣ ('**E278** សេចក្ដីសន្និដ្ឋានរបស់ កសព អំពីឧបសម្ព័ន្ធទី ១២ និងទី ១៣ ដែលបានកែសម្រួលឡើងវិញ អនុលោមតាមវិធាន៨0(៣)')។

[4] **E96/7** សេចក្ដីសម្រេចលើសំណើសុំរបស់សហព្រះរាជ្ញា អនុលោមតាមវិធាន ៩២ ពាក់ព័ន្ធនឹងការទទួលយកកំណត់ហេតុស្ដាប់ចម្លើយសាក្សី និងឯកសារនានានៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង, ២0 មិថុនា ២0១២ ('**E96/7** សេចក្ដីសម្រេចលើកំណត់ហេតុ')។

ឬក៏អត់នោះ។ មេធាវីការពារក្តីក៏អះអាងផងដែរថា ការទទួលយកប្រតិចារឹកនៃសំណុំរឿង 00១ គឺជាការរំលោភសិទ្ធិទទួលបានសវនាការដោយត្រឹមត្រូវ និងយុត្តិធម៌របស់ពួកគេ។ ជាចុងក្រោយពួកគេក៏ដាក់ការជំទាស់បន្ថែមមួយចំនួនទៀត រួមទាំង ការជំទាស់ដែលផ្អែកទៅលើវិសាលភាពនៃសវនាការ និងភាពមិនអាចឲ្យជឿទុកចិត្តបានដែលពួកគេបានលើកឡើងចំពោះកំណត់ហេតុជាក់លាក់មួយចំនួនផង។ នៅក្នុងចម្លើយតបនេះ សហព្រះរាជអាជ្ញាសូមរក្សាគោលជំហរថា អង្គជំនុំជម្រះសាលាដំបូងស្ថិតក្នុងឆន្ទានុសិទ្ធិរបស់ខ្លួនបានយ៉ាងល្អ ក្នុងការអនុម័តគោលការណ៍នានាចេញពីប្រភពអន្តរជាតិមកប្រើក្នុងបរិបទនៃ អ.វ.ត.ក។ សេចក្តីសម្រេចស្តីពីកំណត់ហេតុ ធ្វើការបកស្រាយយ៉ាងត្រឹមត្រូវនូវវិធីសាស្ត្រសាកល្បងចំពោះ "អំពើ និងការប្រព្រឹត្ត" និងបានបង្រួបបង្រួមលក្ខខណ្ឌតម្រូវនៃសិទ្ធិទទួលបានសវនាការដោយត្រឹមត្រូវនៅក្នុងគំរូនីតិវិធីរបស់អ.វ.ត.ក។ សហព្រះរាជអាជ្ញាស្នើឲ្យអង្គជំនុំជម្រះបដិសេធការជំទាស់នានារបស់មេធាវីការពារក្តី ហើយស្នើឲ្យទទួលយកកំណត់ហេតុស្តាប់ ពាក្យបណ្តឹង និងប្រតិចារឹកនៃសំនុំរឿង00១។

## ផ្នែក II - បញ្ហានានាដែលបានលើកឡើងនៅក្នុងសេចក្តីជំទាស់របស់មេធាវីការពារក្តី

## ១. ថាតើវិធីសាស្ត្ររបស់អង្គជំនុំជម្រះសាលាដំបូងបំពេញនូវលក្ខខណ្ឌតម្រូវការជំនុំជម្រះដោយយុត្តិធម៌ទេ

៣. ក្រុមមេធាវីការពារក្តីរបស់ នួន ជា បានពោលអះអាងថា ដើម្បីស្វែងរកការណែនាំនៅក្នុងវិធានផ្ទៃក្នុងដែលកំពុងនៅជាធរមានតាមកម្រិតអន្តរជាតិ ដែលអង្គជំនុំជម្រះសាលាដំបូងបាន "បង្កើតនៅក្នុងរបបបរទេសមួយដែលផ្អែកទៅលើអ្វីដែលមិនមែនជាច្បាប់ទាំងស្រុង របស់តុលាការ*ពិសេស*នានា" ហើយថានៅក្នុងកាលៈទេសៈទាំងនេះ "គោងតែមានការប្រុងប្រយ័ត្នក្នុងការយកមកអនុវត្តនូវរបបខាងលើនេះទាំងស្រុង" [5]។ ផ្អែកតាមមេធាវីការពារក្តី ការណ៍នេះគឺតម្រូវឲ្យមានការអនុវត្តយ៉ាងម៉តចត់នូវរាល់បទបញ្ញត្តិទាំងអស់នៃវិធាន៨២ស្ទួននៃវិធានផ្ទៃក្នុងដែកក្នុងនេះរួមមាន៖ ក) សេចក្តីបញ្ជាក់ពីលក្ខខណ្ឌតម្រូវ។ និង ខ)ការពិចារណា ទាក់ទងទៅនឹងកំណត់ហេតុស្តាប់ចម្លើយសាក្សីនីមួយៗ ថាតើម្ចាស់របស់វាគួរតែត្រូវបានដាក់ឲ្យសួរដេញដោលដោយភាគីបដិបក្សដែរឬទេ? [6] ។ចំណែកឯលក្ខខណ្ឌតម្រូវចុងក្រោយនេះ ពួកគេបានលើកឡើងថាកំណត់ហេតុស្តាប់ចម្លើយសាក្សីណាមួយ "គោងតែត្រូវបានដាក់ឲ្យសួរដេញដោលដោយភាគីបដិបក្ស(បើពុំនោះទេនឹងត្រូវលប់ចេញ) បើសិនជាកំណត់ហេតុនោះមានសារៈសំខាន់គ្រប់គ្រាន់នៅក្នុងបរិបទនៃករណីដែលប្រឆាំងនឹងជនជាប់ចោទ"[7]។ ក្រុមមេធាវី

[5] ការជំទាស់បឋមរបស់នួនជា កថាខណ្ឌទី៥

[6] ការជំទាស់បឋមរបស់នួនជា កថាខណ្ឌទី៦, ៩, ១០,១៤

[7] According to the Nuon Chea Defence, this includes statements which describe criminal conduct that is "highly proximate to the accused" and statements which go to "any live issue between the parties:" Nuon Chea Preliminary Objections, para 12; see also para 13.

ការពារក្ដីរបស់ នួន ជា បានលើកបន្ថែមទៀតថា សេចក្ដីសម្រេចរបស់អង្គជំនុំជម្រះមិនស្រប គ្នានឹងវិធានស្ដីពីនីតិវិធីនៅក្នុងកម្រិតអន្តរជាតិ ហើយវាមិនស៊ីសង្វាក់គ្នានឹងលក្ខខណ្ឌតម្រូវសម្រាប់ការជំនុំជម្រះក្ដីត្រឹមត្រូវ ដូចដែលបានចែងកំណត់នៅក្នុងកាតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ហើយនឹងអនុសញ្ញាទិវីបអឺរ៉ុបស្ដីពីសិទ្ធិមនុស្ស(ECHR)[8]។ ក្រុមមេធាវីការពារក្ដីរបស់ ខៀវ សំផន បានគាំទ្រដល់សារណាទាំងនេះ ហើយបានប្រកែកតវ៉ាបន្ថែមទៀតថា កំណត់ហេតុស្ដាប់ចម្លើយសាក្សីណាមួយមិនអាចទទួលយកដោយគ្មានការសួរដេញដោលដោយភាគីបដិបក្សបានទេ ប្រសិនបើ ក)កំណត់ហេតុនោះមានការជាប់ទាក់ទង*ដោយផ្ទាល់ ឬដោយប្រយោល* ទៅនឹងវិធីសាស្ត្រនៃការទទួលខុសត្រូវដែលត្រូវបានចោទប្រកាន់ប្រឆាំងនឹងជនជាប់ចោទ។ ឬប្រសិនជា ខ)ទាក់ទងទៅនឹង "បញ្ហាដែលមានទំនាស់ដោយភាគីនានានៅក្នុងសវនាការ" ដែលរួមទាំងបញ្ហាខាងអង្គច្បាប់ផង[9]។

៤. បញ្ហាជាបឋម សហព្រះរាជអាជ្ញា សូមលើកឡើងថា ការដាក់សារណារបស់ក្រុមមេធាវីការពារក្ដីគឺស្មើនឹងសំណើសុំឲ្យពិនិត្យពិចារណាឡើងវិញលើសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះ ដូចជាអំពីថាតើធ្វើដូចម្ដេច ដើម្បីឲ្យអនុវត្តបានល្អប្រសើរបំផុតវិធីសាស្ត្រនៃនីតិវិធីដែលចេញមកពីតុលាការអន្តរជាតិនានានៅក្នុងកាលៈទេសៈពិសេសតែមួយគ្មានពីររបស់ អវតក នេះ។ នៅក្នុងសារណារបស់មេធាវីការពារក្ដី មិនបានលើកឡើង អំពីលក្ខខណ្ឌជាមុនខាងគតិយុត្តិដែលអាចអនុវត្តបានចំពោះសំណើខាងលើនេះទេ ដូចជាការបង្ហាញជូននូវអំណះអំណាងថ្មីៗ ឬការបង្ហាញឲ្យឃើញអំពីកំហុសណាមួយច្បាស់លាស់[10]។ សហព្រះរាជអាជ្ញា សូមកត់សំគាល់ថា អំណាចដើម្បីធ្វើការពិនិត្យពិចារណាឡើងវិញលើសេចក្ដីសម្រេចណាមួយ គឺត្រូវបានអនុវត្តតែនៅក្នុងកាលទេសៈពិសេសតែប៉ុណ្ណោះ ដែលមេធាវីការពារក្ដីមិនបានបង្ហាញឲ្យឃើញអំពីរឿងនេះឡើយ[11]។

៥. សហព្រះរាជអាជ្ញា សូមរលឹកជាថ្មីឡើងវិញថា ការដាក់សារណារបស់ខ្លួនអនុលោមតាមវិធាន៩២ ស្ដីពីការទទួលយកនូវកំណត់ហេតុស្ដាប់ចម្លើយសាក្សីមួយចំនួន បានផ្ដល់នូវការពិពណ៌នាទូទៅ ត្រួសៗយ៉ាងពិស្ដារអំពីវិធានផ្ទៃក្នុងជាធរមាន និងអំពីករណីយុត្តិសាស្ត្រនៅក្នុងកម្រិតអន្តរជាតិណាមួយនោះឡើយ[12]។ សហព្រះរាជអាជ្ញាសូមឲ្យអង្គជំនុំជម្រះយកការណែនាំពីវិធានទាំងនេះ ហើយសម្រប

---

8 Nuon Chea Objections 26 April 2013, paras 10-11.

9 Khieu Samphan Submissions on Applicable Law, paras 12, 14 - 17; see also Khieu Samphan Objections, para 20 - 21.

10 See, for example, D250/3/2/1/8 Decision on the Reconsideration of the Admissibility of Civil Party Applications, 1 July 2011, at para 6.

11 Ibid.

12 **E96** Co-Prosecutors' Rule 92 Submission Regarding the Admission of Written Witness Statements Before the Trial Chamber, 15 June 2011, at paras 12 - 20.

វិធានទាំងនេះជាមួយនឹងប្រព័ន្ធដែលអាចអនុវត្តបាននៅចំពោះមុខ អវតក ដែលរួមទាំងច្បាប់នីតិវិធីរដ្ឋប្បវេណីរបស់តុលាការនេះ ដែលនៅក្នុងនេះកំណត់ហេតុស្តាប់ចម្លើយសាក្សី និងភ័ស្តុតាងដទៃទៀត មិនត្រូវបានប្រមូលផ្តុំដោយភាគីនានានោះទេ ប៉ុន្តែដោយស្ថាប័នស៊ើបអង្កេតដែលឯករាជ្យ និងមិនលំអៀងណាមួយរបស់តុលាការ[13]។

៦. សហព្រះរាជអាជ្ញា សូមជូនជាមតិដើម្បីពិចារណាថា អង្គជំនុំជម្រះសាលាដំបូងបានបន្តដំណើរការដោយត្រឹមត្រូវនៅក្នុងវិធីសាស្ត្ររបស់ខ្លួន ឆ្ពោះទៅរកភាពអាចទទួលយកបាននៃភ័ស្តុតាងដែលមានទម្រង់ជាកំណត់ហេតុស្តាប់ចម្លើយសាក្សី។ ផ្ទុយពីសារណារបស់មេធាវីការពារក្តី គឺគ្មានការតម្រូវឱ្យយកនូវវិធាននានារបស់តុលាការអន្តរជាតិ*ពិសេស* មកមកអនុវត្តតាម*ទាំងអស់* នោះឡើយ។ មាត្រា ៣៣ថ្មីនៃច្បាប់ អវតក ផ្តល់អំណាចឱ្យអង្គជំនុំជម្រះដើម្បីស្វែងរក "*ការណែនាំ* នៅក្នុងវិធានស្តីពីនីតិវិធីដែលបានបង្កើតឡើងនៅកម្រិតអន្តរជាតិ"[14]។ ជាជាងការយកមកដាក់បញ្ចូលនូវឈុតនៃវិធានរបស់បរទេសនៅក្នុងនីតិវិធីរបស់ អវតក នោះ អង្គជំនុំជម្រះបានផ្អែកការសម្រេចរបស់ខ្លួនដោយត្រឹមត្រូវលើមូលដ្ឋានដោយបានគិតគូរយកចិត្តទុកដាក់លើ៖ ក)ច្បាប់ អវតក, វិធានផ្ទៃក្នុង , និងច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌរបស់កម្ពុជា។ និង ខ)គោលការណ៍អន្តរជាតិនានាដែលពាក់ព័ន្ធដែលក្នុងនោះរួមមានវិធាន និងយុត្តិសាស្ត្ររបស់តុលាការ*ពិសេស*អន្តរជាតិនានា ហើយនឹងគោលការណ៍នានាដែលលេចចេញមកពី ICCPR និង ECHR ។ ដូចដែលអង្គជំនុំជម្រះសាលាដំបូង បានកត់សំគាល់ហើយថា គ្មានប្រភពណាមួយក្នុងចំណោមប្រភពទាំងនេះ ដែលចែងអំពីសិទ្ធិដាច់ខាតក្នុងការកោះហៅសាក្សីនៅពេលសវនាការនោះឡើយ[15]។

៧. អង្គជំនុំជម្រះសាលាដំបូង បានកត់សំគាល់ថា ខ្លួនមានឆន្ទានុសិទ្ធិដ៏ទូលំទូលាយមួយ អនុលោមតាមវិធាន៨៧ នៃវិធានផ្ទៃក្នុង ដើម្បីពិនិត្យពិចារណាលើរាល់ភ័ស្តុតាងទាំងអស់ដែលអាចទទួលយកបានដែលមានការទាក់ទងនិងភវនីយភាព "អាស្រ័យទៅលើលក្ខណ្ឌតម្រូវឱ្យការជំនុំជម្រះក្តីដោយត្រឹមត្រូវ និងដោយឆាប់រហ័ស"[16]។ អង្គជំនុំជម្រះ បានធ្វើការកត់សំគាល់បន្ថែមទៀតថា គោលការណ៍នេះគឺត្រូវបានផ្តល់គុណវុឌ្ឍិដោយលក្ខណៈវិនិច្ឆ័យដែលចែងនៅក្នុងវិធាន៨៧(៣)នៃវិធានផ្ទៃក្នុង ការសម្រេចថា អង្គជំនុំជម្រះគួរតែពឹងផ្អែកលើលក្ខណៈវិនិច្ឆ័យទាំងនេះដើម្បីធ្វើការសម្រេចអំពីថា តើកំណត់ហេតុ

---

13 Ibid, at paras 31- 36.

14 Law on the Establishment of the Extraordinary Chambers, Article 33 new; see also **E138/1/7** Decision on Immediate Appeal Against the Trial Chamber's Order to Release the Accused Ieng Thirith, 13 December 2011, para. 17 (noting that the Article allows the use of international sources for "guidance" and "analogy").

15 **E96/7** Trial Chamber Statements Decision, para. 19.

16 **E96/7** Trial Chamber Statements Decision, para. 17.

ស្ដាប់ចម្លើយសាក្សីជាលាយលក្ខណ៍អក្សរ ឬប្រតិចារឹកទាំងឡាយអាចត្រូវបានទទួលយកដោយមិនមានការសួរដេញដោលនៅក្នុងតុលាការដែរ ឬទេ?។ អង្គជំនុំជម្រះបានបញ្ជាក់ថា ខ្លួនគួរតែប្រើប្រាស់ផងដែរនូវលក្ខណៈវិនិច្ឆ័យទាំងនេះ ដើម្បីវាយតម្លៃអំពីតម្លៃភស្តុតាងរបស់ហេតុស្ដាប់ចម្លើយអ្វីខ្លះដែលគួរតែភ្ជាប់ជាមួយនឹងកំណត់ហេតុស្ដាប់ចម្លើយសាក្សីនីមួយៗនោះ[17]។

៨. ក្នុងការពិចារណាអំពីការយកគោលការណ៍អន្តរជាតិនានាមកអនុវត្តនៅក្នុងក្របខណ្ឌរបស់ អវតក អង្គជំនុំជម្រះបានកត់សំគាល់ដោយមានការយល់ស្របលើសេចក្ដីប្រកាសមួយ របស់លោកចៅក្រម O-Gon Kwon នៅក្នុងករណីរឿងក្ដីរបស់ *Milosević* ដែលតាមពាក្យពេចន៍របស់អង្គជំនុំជម្រះបានសង្កេតឃើញថា “វិធីសាស្ត្រមួយដែលមានភាពបត់បែនជាងនេះ សម្រាប់ការទទួលយកនូវកំណត់ហេតុស្ដាប់ចម្លើយសាក្សី ជួយលើកកំពស់ដល់សមត្ថភាពរបស់អង្គជំនុំជម្រះសាលាដំបូងដើម្បីចាត់ចែងការជំនុំជម្រះក្ដីដែលមានខ្នាតដ៏ធំទូលាយមួយបានកាន់តែមានប្រសិទ្ធភាពថែមទៀត។ ថាវាគឺជាការអនុវត្តទូទៅជាធម្មតាក្នុងការ ដែលទទួលយកនូវកំណត់ហេតុស្ដាប់ចម្លើយសាក្សីជាលាយលក្ខណ៍អក្សរនៅក្នុងប្រព័ន្ធច្បាប់ស៊ីវិល និងថាចៅក្រមវិជ្ជាជីវៈនានាមានសមត្ថភាពអាចធ្វើការកំណត់អំពីស្ថានទម្ងន់សមស្របដែលត្រូវផ្ដល់ទៅលើភស្តុតាងនេះ”[18]។

៩. អង្គជំនុំជម្រះសាលាដំបូង បានរកឃើញថា ទាក់ទងអំពីការទទួលយកនូវកំណត់ហេតុស្ដាប់ចម្លើយសាក្សីជាជំនួសការផ្ដល់សក្ខីកម្មដោយផ្ទាល់មាត់ វិធាន និងយុត្តិសាស្ត្ររបស់តុលាការអន្តរជាតិ*ពិសេស* នានា “ដែលធ្វើឱ្យមានតុល្យភាពគ្នារវាងសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបាននូវការជំនុំជម្រះក្ដីដោយត្រឹមត្រូវ នឹងប្រសិទ្ធភាពនៃកិច្ចដំណើរការនីតិវិធី”[19]។ ការយកវិធានទាំងនេះមកពិចារណា អង្គជំនុំជម្រះបានសំរេចថា ក្នុងក្របខណ្ឌច្បាប់របស់ អវតក អង្គជំនុំជម្រះគួរតែដកចេញនូវភស្តុតាងដែលសំដៅបង្ហាញ “តឹកតាងអំពីអំពើ និងការប្រព្រឹត្តរបស់ជនជាប់ចោទដូចដែលបានចោទប្រកាន់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ” ថាកំពុងតែមិនស្របគ្នានឹងវិធាន៨៧(៣)(ឃ)នៃវិធានផ្ទៃក្នុងសម្រាប់ អវតក[20] លុះត្រាតែការអនុញ្ញាតត្រូវបានធ្វើឡើងសម្រាប់ការសួរដេញដោលដោយភាគីដែលមិនមែនជាដើមបណ្ដឹង[21]។

[17] **E96/7** Trial Chamber Statements Decision, para. 17.
[18] **E96/7** Trial Chamber Statements Decision, fn. 36, citing *Prosecutor v. Milosević*, Case No. IT-02-54-T, Decision on Prosecution’s Request to Have Written Statements Admitted Under Rule 92*bis*, Declaration of Judge O-Gon Kwon, 21 March 2002, para. 3.
[19] **E96/7** Trial Chamber Statements Decision para. 20.
[20] **E96/7** Trial Chamber Statements Decision, para. 22.
[21] **E96/7** Trial Chamber Statements Decision, para. 22.

១០. ដោយការប្រើប្រាស់បន្តទៅទៀតនូវការណែនាំដែលចេញមកពីប្រភពនានារបស់អន្តរជាតិ អង្គជំនុំជម្រះសាលាដំបូងបានផ្តល់ការយល់ព្រមលើការពិចារណាមួយចំនួន ដែលអាចគាំទ្រដល់ "ការផ្តល់ឲ្យនូវតម្លៃភស្តុតាងមួយចំនួន ដែលហេតុនេះ គឺជាការផ្តល់ស្ថានទម្ងន់ទៅលើភស្តុតាងដែលមានទម្រង់ជាកំណត់ហេតុស្តាប់ចម្លើយសាក្សី ឬប្រតិចារិក" [22]។ អង្គជំនុំជម្រះបានបញ្ជាក់ថា កត្តាផ្សេងៗដែលមិនគាំទ្រដល់តម្លៃភស្តុតាង និងស្ថានទម្ងន់ គឺអាចរួមមាន "ការពុំមានការផ្តល់សក្ខីកម្មដោយផ្ទាល់មាត់ និងឱកាសនៅក្នុងការតទល់គ្នា"[23] ក៏ដូចជាកត្តាផ្សេងៗដែលបានយកមកអនុវត្តដោយតុលាការអន្តរជាតិ *ពិសេស* នានាដែលគាំទ្រដល់ការអនុញ្ញាតឲ្យមានសួរដេញដោលដោយភាគីបដិបក្ស[24]។ អង្គជំនុំជម្រះសាលាដំបូងបានកត់សំគាល់ដោយសមរម្យថា ភស្តុតាងដែលបានដាក់ជូនតាមរយៈសក្ខីកម្មសាក្សីជាលាយលក្ខណ៍អក្សរតែឯងនោះ តោងតែត្រូវបានធ្វើការពិចារណានៅក្នុងបរិបទរបស់ភស្តុតាងដទៃទៀតដែលបានពឹងផ្អែកលើកនៅចុងក្រោយបំផុត ហើយថា "ការជឿជាក់ដែលផ្អែកលើកំណត់ហេតុស្តាប់ចម្លើយសាក្សីនានាតែមួយមុខគត់ ឬទៅលើកម្រិតដ៏សំខាន់ណាមួយនៃកំណត់ហេតុស្តាប់ចម្លើយសាក្សី ដែលមេធាវីការពារក្តីមិនបានផ្តល់នូវឱកាសឲ្យបានត្រឹមត្រូវឬគ្រប់គ្រាន់ដើម្បីធ្វើការតវ៉ាជំទាស់នោះ អាចជាការរំលោភទៅលើសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបាននូវការជំនុំជម្រះក្តីដោយត្រឹមត្រូវ" [25]។

១១. ការប្រើប្រាស់ការណែនាំការណែនាំដែលចេញមកពីប្រភពនានារបស់អន្តរជាតិ និងការសម្របការណែនាំទាំងនេះទៅនឹងបរិបទរបស់ អវតក គឺមិនគ្រាន់តែមានភាពត្រឹមត្រូវទាំងស្រុងតែប៉ុណ្ណោះទេ ក៏ប៉ុន្តែថែមទាំងមានសនិទានភាពដែលផ្តល់ឲ្យប្រភពផ្សេងៗគ្នា នៃកំណត់ហេតុស្តាប់ចម្លើយសាក្សីជាលាយលក្ខណ៍អក្សរ រវាងតុលាការអន្តរជាតិ*ពិសេស*នានា និង អវតក ទៀតផង។ ដោយយល់ឃើញថាកំណត់ហេតុស្តាប់ចម្លើយសាក្សីភាគច្រើនដែលត្រូវបានស្រង់នៅឯតុលាការអន្តរជាតិ*ពិសេស* នានាត្រូវបានប្រមូលចងក្រងដោយភាគីនានា ហើយរាល់កំណត់ហេតុស្តាប់ចម្លើយសាក្សីទាំងអស់ដែលនៅចំពោះមុខ អវតក ត្រូវបានស្រង់ដោយការិយាល័យសហចៅក្រមស៊ើបអង្កេតឬត្រូវបានពិនិត្យឡើងវិញដោយការិយាល័យសហចៅក្រមស៊ើបអង្កេតនេះ នឹងដាក់បញ្ចូលនៅក្នុងសំណុំរឿងដោយចាត់ទុកថាមានជាប់ទាក់ទង ឬអាចឲ្យជឿទុកចិត្តបាន[26]។ នីតិវិធីតាមប្រព័ន្ធច្បាប់ស៊ីវិលដែល មានជា

---

22 **E96/7** Trial Chamber Statements Decision, para. 24.
23 **E96/7** Trial Chamber Statements Decision, para. 25.
24 **E96/7** Trial Chamber Statements Decision, para. 25.
25 **E96/7** Trial Chamber Statements Decision, para. 21.
26 More than 63% of the statements included in the Revised Annexes 12 and 13 were taken by the OCIJ.

ធរមាននៅចំពោះមុខ អវតក មិនដូចគ្នាជានៅតុលាការអន្តរជាតិ*ពិសេស*នានាទេ គឺបានសង្កត់សារៈសំខាន់ធ្ងន់លើកំណត់ហេតុស្តាប់ចម្លើយសាក្សីជាលាយលក្សណ៍អក្សរ ដែលត្រូវបានប្រមូលចងក្រង និងពិនិត្យឡើងវិញដោយស្ថាប័នស៊ើបអង្កេតមួយរបស់តុលាការដែលគ្មានភាពលំអៀង[27]។ ការដែលបានយកមកអនុវត្តនូវវិធានរបស់តុលាការអន្តរជាតិ*ពិសេស*នានា *ដូចគ្នាបេះបិទគ្រប់ម៉ាត់ទាំងអស់* នៅ អវតក គឺមុខជាធ្វើឲ្យទស្សនៈទាននៃកិច្ចស៊ើបសួររបស់តុលាការក្លាយជាគ្មានន័យ ដែលនេះលក្ខណៈពិសេសនិងជាគន្លឹះមួយនៃនីតិវិធីតាមប្រព័ន្ធច្បាប់ស៊ីវិល ដែលផ្តល់នូវការការពារដ៏ទូលំទូលាយទៅឲ្យមេធាវីការពារក្តី (ដែលកិច្ចការពារទាំងនេះ គឺមិនមានឡើយនៅឯតុលាការ ICTY និងតុលាការ ICTR)។

១២. ហេតុដូច្នេះហើយ លក្ខខណ្ឌតម្រូវបន្ថែមទាក់ទងនឹងនីតិវិធីដែលបានតម្រូវនៅឯតុលាការអន្តរជាតិ*ពិសេស*នានា ដើម្បីធានានាឲ្យមានភាពត្រឹមត្រូវ និងភាពអាចឲ្យជឿទុកចិត្តបាន[28] នៃកំណត់ហេតុស្តាប់ចម្លើយនានានៅក្នុងតុលាការទាំងនោះដូចជា (សេចក្តីបញ្ជាក់អំពីលក្ខខណ្ឌតម្រូវផ្សេងៗនៃវិធាន ៩២*ស្ទួន*(ខ) និងអំពីការពិចារណាទាក់ទងទៅនឹងកំណត់ហេតុស្តាប់ចម្លើយនីមួយៗ យោងវិធាន៩២ *ស្ទួន*(គ) អំពីថាតើការសួរដេញដោលដោយភាគីបដិបក្សមានការចាំបាច់ដែរឬទេ?) ដូចនេះគឺសុទ្ធតែមានសារសំខាន់យ៉ាងតិចតួចជាមួយបញ្ហាការដែលមាននៅចំពោះមុខ អវតក។ ទោះជាយ៉ាងណាក៏ដោយ អង្គជំនុំជម្រះបានកំណត់ តក្កភាពសំខាន់ជាអាទិ៍នៃកត្តាមួយចំនួនក្នុងចំណោមកត្តាទាំងនោះអាចជាជំនួយនៅក្នុងការកំណត់អាងហេតុលើតម្លៃភរនីយភាព និង ទម្ងន់នៃភ័ស្តុតាងនានាដែលមាននៅក្នុងកំណត់ហេតុស្តាប់ចម្លើយសាក្សី គឺជាវិធីដែលល្អឥតខ្ចោះហើយត្រឹមត្រូវតាមច្បាប់មួយដែលគ្មានផ្លូវធ្វើឲ្យប៉ះពាល់ដល់សិទ្ធរបស់ជនជាប់ចោទឡើយ។

១៣. ដូចអង្គជំនុំជម្រះសាលាដំបូងបានធ្វើការកត់សំគាល់ មិនមានសិទ្ធិដាច់ខាតក្នុងការតទល់គ្នារបស់សាក្សីនៅចំពោះមុខ អវតក នោះទេ ការទទួលយកនូវភ័ស្តុតាងក្នុងទម្រង់ជាកំណត់ហេតុស្តាប់ចម្លើយសាក្សីជាលាយលក្សណ៍ គឺជាការអនុវត្តមួយដែលត្រូវបានគេទទួលយល់ព្រមនៅតុលាការអន្តរជាតិនានា ហើយ “ការកំរិតណាមួយចំពោះសិទ្ធិក្នុងការស្តាប់ចម្លើយសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញទាំងអស់ដែលបានស្នើសុំ គឺជាការចាំបាច់ដើម្បីរក្សាការពារសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបាន

---

[27] The Co-Prosecutors incorporate by reference E96 Co-Prosecutors' Rule 92 Submission Regarding the Admission of Written Witness Statements Before the Trial Chamber, 15 June 2011, paras. 31-32.

[28]

នូវការជំនុំជម្រះក្ដីដោយឆាប់រហ័ស"[29]។ វិធីសាស្ត្រដែលបានប្រកាន់យកដោយអង្គជំនុំជម្រះអនុលោមតាមវិធាន៨៧(៣)នៃវិធានផ្ទៃក្នុង ធ្វើឲ្យមានតុល្យភាពរវាង សិទ្ធិក្នុងការទទួលបាននូវការជំនុំជម្រះក្ដីដោយត្រឹមត្រូវរបស់ជនជាប់ចោទ និងគោលដៅនៃភាពឆាប់រហ័ស និងប្រសិទ្ធិភាពនៃកិច្ចដំណើរការនីតិវិធីដែលអនុញ្ញាតឲ្យទទួលយកនូវភ័ស្តុតាងសក្ខីកម្មជាលាយលក្សណ៍អក្សរ។

## ការអនុវត្តនូវវិធីសាកល្បងស្តីពី "អំពើ និងការប្រព្រឹត្តិរបស់ជនជាប់ចោទ"

១៤. ភាសានៃវិធាន៩២ស្ទួន(ក)របស់តុលាការ ICTY/ICTR ច្រានចោលការទទួលយកភ័ស្តុតាងស្តីពី "អំពើ និងការប្រព្រឹត្តិរបស់ជនជាប់ចោទ ដូចបានចោទប្រកាន់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ"។ អង្គជំនុំជម្រះនេះ បានអនុម័តយកការសាកល្បងនេះនៅក្នុងក្របខណ្ឌច្បាប់ អ.វ.ត.ក[30] ដោយបានសម្រេចថា កំណត់ហេតុដែលមានភ័ស្តុតាងពីអំពើ និងការប្រព្រឹត្តិរបស់ជនជាប់ចោទដូចបានចោទប្រកាន់ ត្រូវចាត់ទុកថា "មិនអនុញ្ញាតិនៅក្រោមច្បាប់" អនុលោមតាមវិធាន៨៧(៣)(ឃ) [31]។

១៥. មេធាវីការពារក្តី ខៀវ សំផន និង នួន ជា អំពាវនាវឲ្យអង្គជំនុំជម្រះសាលាដំបូងអនុម័តយកការបកស្រាយទូលំទូលាយនូវឃ្លា "អំពើ និងការប្រព្រឹត្តិរបស់ជនជាប់ចោទដូចបានចោទប្រកាន់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ" ដោយរួមបញ្ចូលទាំងភ័ស្តុតាងទាំងឡាយដែលមិនបាននិយាយពីជនជាប់ចោទ ប៉ុន្តែយោងទៅរកក្រុមដែលជនជាប់ចោទជាសមាជិក ព្រមទាំងភ័ស្តុតាងណាមួយទាក់ទិននឹងការប្រាស្រ័យទាក់ទង និងវចនាសម្ព័ន្ធរដ្ឋបាល[32]។ ដូចបង្ហាញជូនខាងក្រោម នេះគឺជាការស្នើមួយឲ្យអង្គជំនុំជម្រះងាកចេញពីការសម្រេចមុនៗរបស់ខ្លួន ដែលបញ្ហានេះទាំងមូលស្របគ្នានឹងយុត្តិសាស្ត្រដែលបានដោះស្រាយនិងកំណត់ក្នុងវិធាន៩២ *ស្ទួន*(ក)។

១៦. យុត្តិសាស្ត្ររបស់តុលាការ*ពិសេស*នានា ដែលថ្លែងពីការបកស្រាយឃ្លា "អំពើ និងការប្រព្រឹត្តិរបស់ជនជាប់ចោទ" បានពឹងផ្អែកនៅលើពាក្យពេចន៍ធម្មតានៃបទប្បញ្ញត្តិនោះ។ អនុលោមតាមយុត្តិសាស្ត្រនេះ

---

29 ឯកសារលេខ **E96/7** សេចក្តីសំរេចរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីកំណត់ហេតុស្តាប់ចម្លើយសាក្សី,កថាខណ្ឌទី១៨។

30 **E96/7** សេចក្តីសម្រេចលើកំណត់ហេតុរបស់អង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌទី២២។

31 **E96/7** សេចក្តីសម្រេចលើកំណត់ហេតុរបស់អង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌទី២២។ បន្ថែមលើលក្ខខណ្ឌតម្រូវនេះ កំណត់ហេតុត្រូវបានវាយតម្លៃដោយអង្គជំនុំជម្រះ ធៀបនឹងលក្ខណវិនិច្ឆ័យនៃភាពអាចទទួលយកបានដទៃទៀតនៅក្នុងវិធាន៨៧(៣)៖ កថាខណ្ឌទី២៣។

32 សូមមើល **E277** សេចក្តីសន្និដ្ឋានរបស់ ខៀវ សំផន ស្តីពីច្បាប់ជាធរមាន កថាខណ្ឌទី១៩, ៦២។ E208/5 ការជំទាស់របស់ ខៀវ សំផន, កថាខណ្ឌទី១៧-១៩។ E96/8/1 អញ្ញត្រកម្មរបស់ នួន ជា, កថាខណ្ឌទី២៧។

ជាជាងការក្រសោបយកនូវអំពើរបស់បុគ្គល ឬស្ថាប័នទាំងឡាយដែលបានចោទប្រកាន់ពីការពាក់ព័ន្ធជាមួយជនជាប់ចោទ ឃ្លានេះមានលក្ខណៈជាបុគ្គល ជារូបវ័ន្តចំពោះជនជាប់ចោទ ហើយត្រូវបានកម្រិតត្រឹមអំពើ និងការប្រព្រឹត្តិរបស់បុគ្គលនេះ[33] តែប៉ុណ្ណោះ។ អង្គជំនុំជម្រះសាលាដំបូងបានយល់ព្រមទទួលយកអភិក្រមនេះ ដោយបានលើកយោងនូវសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY ក្នុងរឿងក្តី *Haridinaj និងគូកន*, ដោយសម្រេចថា៖ "អំពើ និងការប្រព្រឹត្តិរបស់ជនជាប់ចោទ" ត្រូវបានគេយល់ថា ជាឃ្លាធម្មតាដែលគួរផ្តល់អត្ថន័យជាធម្មតារបស់វាថា៖ កម្ម(អំពើ) និងចរិយា (ការប្រព្រឹត្តិ) របស់ជនជាប់ចោទ រួមទាំងក្នុងករណីខកខានសមស្របផ្សេងៗទៀត[34]។ អង្គជំនុំជម្រះសាលាដំបូងក៏បានយោងទៅរកសេចក្តីសម្រេចខាងក្រោមនេះផងដែរ ដែលបានធ្វើឡើងដោយអង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY ក្នុងរឿងក្តី *Milosevic* ដូច្នេះថា៖ "ឃ្លាថា 'អំពើ និងការប្រព្រឹត្តិរបស់ជនជាប់ចោទ'... មិនគួរត្រូវបានគេពង្រីករហូតដល់មានការបកស្រាយបែបរវើរវាយឡើយ។ មិនមាននិយាយពីអំពើ និងការប្រព្រឹត្តិដោយសហចារី ដូចជនក្រោមបង្គាប់ដែលបានចោទប្រកាន់ ឬតាមការពិត អ្នកណាម្នាក់ផ្សេងទៀតក៏គ្មានដែរ។ បើសិនជាវិធានដែលបានលើកឡើងដោយមានចេតនាឲ្យគេពង្រីកបានរហូតដល់អំពើ និងការប្រព្រឹត្តិរបស់សហចារី ឬជននៅក្រោមបង្គាប់ដូចដែលគេបានចោទប្រកាន់ ម្ល៉េះវិធាននេះបានចែងដូច្នេះទៅហើយ"[35]។ សេចក្តីសម្រេចមួយចំនួនផ្សេងទៀតរបស់តុលាការ ICTY និង ICTR អះអាងឡើងវិញថា ឃ្លានេះមិនរាប់បញ្ចូលភ័ស្តុតាងនៃអំពើ និងការប្រព្រឹត្តិរបស់សហចារីរបស់ជនជាប់ចោទ និង/ឬ ជនក្រោមបង្គាប់របស់ជនជាប់ចោទទេ[36]។ តាមការពិត ដូចដែលតុលាការ ICTR បានសម្រេចនៅក្នុងរឿងក្តី *Ngirabataware,* ថា

---

[33] *រដ្ឋអាជ្ញា ទល់នឹង Tolimir*, សំណុំរឿងលេខ៖ IT-05-88-T/2-T សេចក្តីសម្រេចលើញត្តិរបស់រដ្ឋអាជ្ញា សុំឲ្យទទួលយកភ័ស្តុតាងជាលាយល័ក្ខណ៍អក្សរ អនុលោមតាមវិធាន៩២ស្ទួន និង៩៤ស្ទួន, ៧ កក្កដា ២០១០, កថាខណ្ឌទី៣០។ សូមមើលផងដែរ *រដ្ឋអាជ្ញា ទល់នឹង Muvunyi*, សំណុំរឿងលេខ៖ ICTR-2000-55A-T សេចក្តីសម្រេចលើញត្តិរបស់រដ្ឋអាជ្ញា សុំឲ្យទទួលយកសក្ខីកម្មរបស់សាក្សីជំនាញ (វិធាន៩២ស្ទួន នៃវិធាននេះ), ២៤ មីនា ២០០៥, កថាខណ្ឌទី១៦។

[34] E96/7 សេចក្តីសម្រេចលើកំណត់ហេតុរបស់អង្គជំនុំជម្រះសាលាដំបូង, កំណត់សំគាល់ជើងទំព័រ៣៩ លើកយោង *រដ្ឋអាជ្ញា ទល់នឹង Haradinaj និងគូកន.,* សំណុំរឿងលេខ៖ IT-04-84bis-PT, សេចក្តីសម្រេចលើញត្តិរបស់រដ្ឋអាជ្ញា សុំឲ្យទទួលយកប្រតិចារឹកនៃភ័ស្តុតាងជំនួសឲ្យសក្ខីកម្មផ្ទាល់មាត់ អនុលោមតាមវិធាន៩២ស្ទួន, ២២ កក្កដា ២០១១, កថាខណ្ឌទី២០។

[35] E96/7 សេចក្តីសម្រេចលើកំណត់ហេតុរបស់អង្គជំនុំជម្រះសាលាដំបូង, កំណត់សំគាល់ជើងទំព័រ៣៩ លើកយោង *រដ្ឋអាជ្ញា ទល់នឹង Milošević*, សំណុំរឿងលេខ៖ IT-02-54-T សេចក្តីសម្រេចលើសំណើរបស់រដ្ឋអាជ្ញា សុំឲ្យទទួលយកកំណត់ហេតុជាលាយល័ក្ខណ៍អក្សរតាមវិធាន៩២ស្ទួន, ២១ មីនា ២០០២, កថាខណ្ឌទី២២។

[36] *រដ្ឋអាជ្ញា ទល់នឹង Édouard Karemera និងគូកន.,* សំណុំរឿងលេខ៖ ICTR-98-44-T សេចក្តីសម្រេចលើញត្តិរបស់រដ្ឋអាជ្ញា សុំឲ្យទទួលយកភ័ស្តុតាងអំពីអំពើរំលោភសេពសន្ថវៈ និងបំពារបំពានផ្លូវភេទ អនុលោមតាមវិធាន៩២ស្ទួន នៃវិធាននេះ និងដីកាបង្គាប់ឲ្យ

យកល្អគេត្រូវបដិសេធចោល "ការបកស្រាយបែបរើរវើយ" ពីការសាកល្បងនៃអំពើ និងការប្រព្រឹត្តិនេះដោយហេតុថា "ការបកស្រាយទូលំទូលាយហួសហេតុពេកនៃវិធាន៩២ស្ទួន នឹងនាំឱ្យឥតប្រយោជន៍"[37]។

១៧. ដោយបានទទួលយកយុត្តិសាស្ត្រនេះ អង្គជំនុំជម្រះសាលាដំបូងក៏បានសម្រេចផងដែរថា ការមិនដាក់បញ្ចូលឃ្លានៃ "អំពើ និងការប្រព្រឹត្តិរបស់ជនជាប់ចោទ" គឺជាភ័ស្តុតាងនៃការព្រួយបារម្ភចំពោះបញ្ហាដូចជា "គោលនយោបាយ រចនាសម្ព័ន្ធនៃការប្រាស្រ័យទំនាក់ទំនង និងអត្ថិភាពនៃផែនការរួម"[38]។

១៨. អង្គជំនុំជម្រះបានយោងដោយមានការឯកភាពគ្នា[39] នូវការបង្ហាញច្បាស់លាស់មួយនៃការកំណត់ព្រំដែន ពីការសាកល្បងនៃ "អំពើ និងការប្រព្រឹត្តិ" ដែលបានបង្កើតដោយអង្គជំនុំជម្រះសាលាឧទ្ធរណ៍

---

កាត់បន្ថយបញ្ជីសាក្សីរបស់អយ្យការ, ១១ ធ្នូ ២០០៦, កថាខណ្ឌទី១០។ *រដ្ឋអាជ្ញា ទល់នឹង Goran Hadžić*, IT-04-75-T, សេចក្តីសម្រេចលើញត្តិចម្រុះរបស់រដ្ឋអាជ្ញា សុំឱ្យទទួលយកភ័ស្តុតាង អនុលោមតាមវិធាន៩២ស្ទួន និងញត្តិរបស់អយ្យការសុំឱ្យទទួលយកភ័ស្តុតាងរបស់ GH-139 អនុលោមតាមវិធាន៩២ស្ទួន, ២៤ មករា ២០១៣, កថាខណ្ឌទី១៥។ *រដ្ឋអាជ្ញា ទល់នឹង Goran Hadžić* , សេចក្តីសម្រេចលើញត្តិរបស់រដ្ឋអាជ្ញា សុំឱ្យទទួលយកភ័ស្តុតាងរបស់ GH-164 អនុលោមតាមវិធាន៩២ស្ទួន, ២២ មេសា ២០១៣, កថាខណ្ឌទី៦។ *រដ្ឋអាជ្ញា ទល់នឹង Naser Orić*, IT-03-68-T, សេចក្តីសម្រេចលើញត្តិរបស់មេធាវីការពារក្តី សុំឱ្យទទួលយកភ័ស្តុតាងរបស់សាក្សីម្នាក់ ក្នុងទម្រង់ជាកំណត់ហេតុជាលាយល័ក្ខណ៍អក្សរ អនុលោមតាមវិធាន៩២ស្ទួន, ៦ ធ្នូ ២០០៥, កថាខណ្ឌទី៣ ("អំពើ និងការប្រព្រឹត្តិរបស់ជនជាប់ចោទ" គួរផ្តល់ទៅតាមអត្ថន័យធម្មតារបស់វា មានន័យថា "កម្ម និងការប្រព្រឹត្តិរបស់ជនជាប់ចោទ" *ក្នុងន័យតឹងរ៉ឹងនិងចង្អៀត* មិនមែនពង្រីកទៅដល់អំពើ និងការប្រព្រឹត្តិរបស់អ្នកក្រោមបង្គាប់ ឬសហចារីទេ" (សេចក្តីយោងខាងក្នុងត្រូវបានលុបចេញ)។ *រដ្ឋអាជ្ញា ទល់នឹង Naser Orić*, IT-03-68-T, សេចក្តីសម្រេចលើញត្តិរបស់មេធាវីការពារក្តី សុំឱ្យទទួលយកកំណត់ហេតុរបស់សាក្សី Avdo Husejnović អនុលោមតាមវិធាន៩២ស្ទួន, ១៥ កញ្ញា ២០០៥, កថាខណ្ឌទី៣ (ឃ្លាថា "អំពើ និងការប្រព្រឹត្តិរបស់ជនជាប់ចោទដូចបានចោទប្រកាន់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ" ក្នុងវិធាន៩២ស្ទួន(ក) នៃវិធាននេះ គឺជាឃ្លាធម្មតា និងគួរផ្តល់ទៅតាមអត្ថន័យធម្មតារបស់វា មានន័យថា កម្ម និងឥរិយាបថរបស់ជនជាប់ចោទ")។ *រដ្ឋអាជ្ញា ទល់នឹង Vidoje Blagojević និង Dragan Jokić*, សំណុំរឿងលេខ៖ IT-02-60-T, សេចក្តីសម្រេចលើកទីមួយលើញត្តិរបស់រដ្ឋអាជ្ញា សុំឱ្យទទួលយកកំណត់ហេតុសាក្សី និងសក្ខីកម្មជាមុន អនុលោមតាមវិធាន៩២ស្ទួន, ១២ មិថុនា ២០០៣, កថាខណ្ឌទី១៧ ("គ្មានសាក្សីណាម្នាក់នៃវិធាន៩២ស្ទួន បាននិយាយដោយផ្ទាល់សំដៅទៅរកជនជាប់ចោទណាម្នាក់ទេ ដូច្នេះភ័ស្តុតាងដែលត្រូវទទួលយកតាមរយៈសាក្សីទាំងនេះ មិនសំដៅទៅរក "អំពើ និងការប្រព្រឹត្តិរបស់ជនជាប់ចោទដូចបានចោទប្រកាន់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះដោយផ្ទាល់ឡើយ")។

37 *រដ្ឋអាជ្ញា ទល់នឹង Ngirabataware*, ICTR-99-54-T, សេចក្តីសម្រេចលើញត្តិរបស់មេធាវីការពារក្តី សុំឱ្យទទួលយកកំណត់ហេតុជាលាយល័ក្ខណ៍អក្សរ, ១៤ ឧសភា ២០១២, កថាខណ្ឌទី១៥។

38 **E96/7** សេចក្តីសម្រេចលើកំណត់ហេតុរបស់អង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌទី២១។ សូមមើលផងដែរ *រដ្ឋអាជ្ញា ទល់នឹង Blagojevic និង Jokic*, សំណុំរឿងលេខ៖ IT-02-60-T សេចក្តីសម្រេចលើកទីមួយលើញត្តិរបស់រដ្ឋអាជ្ញា សុំឱ្យទទួលយកកំណត់ហេតុសាក្សី និងសក្ខីកម្មជាមុន អនុលោមតាមវិធាន៩២ស្ទួន, ១២ មិថុនា ២០០៣, កថាខណ្ឌទី១៧ ("គ្មានសាក្សីណាម្នាក់នៃវិធាន៩២ស្ទួន បាននិយាយដោយផ្ទាល់សំដៅទៅរកជនជាប់ចោទណាម្នាក់ទេ ដូច្នេះភ័ស្តុតាងដែលត្រូវទទួលយកតាមរយៈសាក្សីទាំងនេះ មិនសំដៅទៅរក "អំពើ និងការប្រព្រឹត្តិរបស់ជនជាប់ចោទដូចបានចោទប្រកាន់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះដោយផ្ទាល់ឡើយ")។

នៃតុលាការ ICTY ក្នុងរឿងក្តី *Galic*, ដែលសម្រេចថា វិធាន៩២ស្ទួន ច្រានចោលកំណត់ហេតុណាដែលនឹងបង្ហាញភ័ស្តុតាងពី អំពើ និងការប្រព្រឹត្តិណាមួយរបស់ជនជាប់ចោទ ដែលអយ្យការស្វែងរកដើម្បីកំណត់ពីគំរូនៃការទទួលខុសត្រូវដោយផ្ទាល់។

១៩. បើសិនជាជនជាប់ចោទត្រូវបានចោទថា ថាបានចូលរួមនៅក្នុងសហកម្មឧក្រិដ្ឋកម្មរួម (JCE) វិធាន៩២ ស្ទួន(ក) ច្រានចោលជាមុននូវការទទួលយកភ័ស្តុតាងស្តីពីអំពើ និងការប្រព្រឹត្តិរបស់ជនជាប់ចោទខ្លួនឯង ដោយអយ្យការត្រូវពឹងផ្អែកក្នុងការបង្ហាញឲ្យឃើញថាជនជាប់ចោទបានចូលរួមនៅក្នុងសហឧក្រិដ្ឋកម្មរួម នោះឬ "ថា គាត់បានរួមចំណែកជាមួយ ជនដែលបានប្រព្រឹត្តិឧក្រិដ្ឋកម្មពិតប្រាកដដែលបានចោទប្រកាន់ ដែលជាលក្ខខណ្ឌតម្រូវអំពីចេតនាចំពោះឧក្រិដ្ឋកម្មទាំងនោះ"[40]។ ដូច្នេះ បើសិនជាមានភាគីណាមួយអះអាងថា ភ័ស្តុតាងបញ្ជាក់ពីសកម្មភាពរបស់សមាជិកនៃក្រុម JCE ដែលមិនមែនជារបស់ជនជាប់ចោទ មានតម្លៃស្មើនឹង "អំពើ និងការប្រព្រឹត្តិរបស់ជនជាប់ចោទ" ដោយសារជនជាប់ចោទត្រូវបានចោទប្រកាន់លើមូលដ្ឋាននៃ JCE តុលាការ ICTY បានច្រានចោលការបកស្រាយបែបទូលំទូលាយដូច្នេះថានោះគឺជា "ការដាក់បន្ទុកចំពោះពាក្យ "អំពើ និងការប្រព្រឹត្តិ" ទៅនឹងខ្លឹមសារច្បាប់ដែលមិនស៊ីសង្វាក់គ្នា ជាមួយនឹងការបកស្រាយពាក្យពេចន៍របស់អង្គជំនុំជម្រះសាលាឧទ្ធរណ៍[41]។

២០. ដូចបានលើកយោងដោយអង្គជំនុំជម្រះនេះដែរ[42] ថាបើសិនជាជនជាប់ចោទត្រូវបានចោទប្រកាន់ថាជាអ្នកទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌដោយផ្អែកលើអំពើរបស់អ្នកដទៃ ភ័ស្តុតាងនៃ "អំពើ និងការប្រព្រឹត្តិ

---

[39] **E96/7** សេចក្តីសម្រេចលើកំណត់ហេតុរបស់អង្គជំនុំជម្រះសាលាដំបូង, កំណត់សំគាល់ជើងទំព័រ៣៩ លើកយោង *រដ្ឋអាជ្ញា ទល់នឹង Galić*, សំណុំរឿងលេខ៖ IT-98-29—AR73.2 សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍បន្ទាន់បង្ខំពាក់ព័ន្ធនឹងវិធាន៩២ស្ទួន(គ), ៧ មិថុនា ២០០២, កថាខណ្ឌទី១០។

[40] សូមមើល E96/7 សេចក្តីសម្រេចលើកំណត់ហេតុរបស់អង្គជំនុំជម្រះសាលាដំបូង, កំណត់សំគាល់ជើងទំព័រ៣៩។ *រដ្ឋអាជ្ញា ទល់នឹង Galić*, សំណុំរឿងលេខ៖ IT-98-29AR73.2 សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍បន្ទាន់បង្ខំពាក់ព័ន្ធនឹងវិធាន៩២ស្ទួន(គ), ៧ មិថុនា ២០០២, កថាខណ្ឌទី១០។ *រដ្ឋអាជ្ញា ទល់នឹង Goran Hadžić*, សេចក្តីសម្រេចលើញត្តិចម្រុះរបស់រដ្ឋអាជ្ញា សុំឲ្យទទួលយកភ័ស្តុតាងអនុលោមតាមវិធាន៩២ស្ទួន និងញត្តិរបស់អយ្យការសុំឲ្យទទួលយក ភ័ស្តុតាងរបស់ GH-139 អនុលោមតាមវិធាន៩២ស្ទួន, ២៤ មករា ២០១៣, កថាខណ្ឌទី១៦។ *រដ្ឋអាជ្ញា ទល់នឹង Goran Hadžić* , សេចក្តីសម្រេចលើញត្តិរបស់រដ្ឋអាជ្ញា សុំឲ្យទទួលយកភ័ស្តុតាងរបស់ GH-164 អនុលោមតាមវិធាន៩២ស្ទួន, ២២ មេសា ២០១៣, កថាខណ្ឌទី៧។

[41] *រដ្ឋអាជ្ញា ទល់នឹង Stanišić និង Simatović*, សេចក្តីសម្រេចលើញត្តិរបស់រដ្ឋអាជ្ញា សុំឲ្យទទួលយកភ័ស្តុតាងជាលាយល័ក្ខណ៍អក្សរ, ៧ តុលា ២០១០, កថាខណ្ឌទី៤២។

[42] សូមមើល E96/7 សេចក្តីសម្រេចលើកំណត់ហេតុរបស់អង្គជំនុំជម្រះសាលាដំបូង, កំណត់សំគាល់ជើងទំព័រ៣៩ លើកយោង *រដ្ឋអាជ្ញា ទល់នឹង Karadžić*, សំណុំរឿងលេខ៖ IT-95-5/18-PT, សេចក្តីសម្រេចលើញត្តិទីបីរបស់រដ្ឋអាជ្ញា សុំឲ្យទទួលយកកំណត់ហេតុនិង

របស់ជនដទៃទាំងនោះដែលបានប្រព្រឹត្តិបទឧក្រិដ្ឋដែលជនជាប់ចោទត្រូវបានចោទប្រកាន់ថា ជាអ្នកទទួលខុសត្រូវ" គឺអាចទទួលយកបាន ចំណែកឯភស្តុតាងនៃ "អំពើ និងការប្រព្រឹត្តិរបស់ជនជាប់ចោទ" ដែលកំណត់ពីការទទួលខុសត្រូវរបស់គាត់ចំពោះអំពើ និងការប្រព្រឹត្តិរបស់ជនដទៃទាំងនោះ" គឺមិនអាចទទួលយកបានទេ[43]។ លើសពីនេះ ភស្តុតាងទាក់ទងនឹងអំពើ និងការប្រព្រឹត្តិរបស់អ្នកដទៃដែលអាចអះអាងលើការកំណត់ពីស្ថានភាពផ្លូវចិត្តរបស់ជនជាប់ចោទ (ឧ. ចំណេះដឹងរបស់គាត់ត្រូវគ្នានឹងទម្រង់ទ្រង់ទ្រាយនៃការវាយប្រហារដ៏ទូលំទូលាយ និងជាប្រព័ន្ធ) គឺអាចទទួលយកបាន[44]។ បន្ថែមលើប្រភេទដូចដែលបានគូសបញ្ជាក់ឱ្យឃើញយ៉ាងច្បាស់នេះ ភស្តុតាងអំពីការខកខាន (កំហុសអកម្ម) (ដូចបានកត់សំគាល់ពីខាងលើ) និងភស្តុតាងដោះបន្ទុកដែលអាចមាន ក៏ត្រូវបានក្រសោមយកដាក់បញ្ចូលក្នុងឃ្លានោះដែរ[45]។

២១. ដូចបានបញ្ជាក់នៅក្នុងឧបសម្ព័ន្ធ ១២ និង១៣ ដែលបានកែសម្រួលឡើងវិញ នៃសេចក្តីសន្និដ្ឋាន ដោយបំពេញកិច្ចស្របទៅតាមសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង សហព្រះរាជអាជ្ញាបានកំណត់អត្តសញ្ញាណកំណត់ហេតុស្តាប់ចម្លើយចំនួន២២០ កំណត់ហេតុដែលមានភស្តុតាងបញ្ជាក់ពីអំពើ និងការប្រព្រឹត្តិរបស់ជនជាប់ចោទ ហើយអ្នកនិពន្ធកំណត់ហេតុទាំងនោះនៅមិនបានមកបំភ្លឺនៅចំពោះមុខអង្គជំនុំជម្រះនៅឡើយនៅពេលដាក់ឯកសារនោះ[46]។ អត្ថបទដែលពាក់ព័ន្ធនៅក្នុងកំណត់

---

ប្រតិចារឹកនៃភស្តុតាងជំនួសឱ្យសក្ខីកម្មផ្ទាល់មាត់ អនុលោមតាមវិធាន៩២ស្ទួន (សាក្សីសម្រាប់ទីក្រុង Municipality), ១៥ តុលា ២០០៩, កថាខណ្ឌទី៥។

[43] *រដ្ឋអាជ្ញា ទល់នឹង Karadžić*, សំណុំរឿងលេខ៖ IT-95-5/18-PT, សេចក្តីសម្រេចលើញត្តិទីបីរបស់រដ្ឋអាជ្ញា សុំឱ្យទទួលយកកំណត់ហេតុ និងប្រតិចារឹកនៃភស្តុតាងជំនួសឱ្យសក្ខីកម្មផ្ទាល់មាត់ អនុលោមតាមវិធាន៩២ស្ទួន (សាក្សីសម្រាប់ទីក្រុង Sarajevo), ១៥ តុលា ២០០៩, កថាខណ្ឌទី៥។ *រដ្ឋអាជ្ញា ទល់នឹង Goran Hadžić*, សេចក្តីសម្រេចលើញត្តិចម្រុះរបស់រដ្ឋអាជ្ញា សុំឱ្យទទួលយកភស្តុតាង អនុលោមតាមវិធាន៩២ស្ទួន និងញត្តិរបស់អយ្យការសុំឱ្យទទួលយក ភស្តុតាងរបស់ GH-139 អនុលោមតាមវិធាន៩២ស្ទួន, ២៤ មករា ២០១៣, កថាខណ្ឌទី១៥។ Hadzic, ២២ មេសា ២០១៣, កថាខណ្ឌទី៦។

[44] *រដ្ឋអាជ្ញា ទល់នឹង Galić*, សំណុំរឿងលេខ៖ IT-98-29AR73.2 សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍បន្ទាន់បង្គំពាក់ព័ន្ធនឹងវិធាន៩២ស្ទួន(គ), ៧ មិថុនា ២០០២, កថាខណ្ឌទី១១។ *រដ្ឋអាជ្ញា ទល់នឹង Galić*, សំណុំរឿងលេខ៖ IT-98-29-T សេចក្តីសម្រេចលើសំណើរបស់អយ្យការសុំឱ្យទទួលយកកំណត់ហេតុអនុលោមតាមវិធាន៩២ស្ទួន, ២៦ កក្កដា ២០០២, កថាខណ្ឌទី១៣។

[45] *រដ្ឋអាជ្ញា ទល់នឹង Nzabonimana*, សំណុំរឿងលេខ៖ ICTR-98-44-D-T សេចក្តីសម្រេចលើញត្តិសុំឱ្យទទួលយកប្រតិចារឹកពីរឿងក្តី *Karemera នឹងគូក* (វិធាន៩២ស្ទួន(ឃ) និង៨៩(គ) នៃវិធានស្តីពីនីតិវិធី និងភស្តុតាង, ១០ ឧសភា ២០១១, កថាខណ្ឌទី៣៤, ៣៧ ("យុត្តិសាស្ត្ររបស់តុលាការមិនបានធ្វើឱ្យឃើញខុសគ្នារវាងថាតើសម្ភារៈដែលបានស្នើឱ្យទទួលយកនឹងបង្ហាញ ឬមិនបង្ហាញភស្តុតាងអំពីអំពើ និងការប្រព្រឹត្តិរបស់ជនជាប់ចោទឬអត់នោះទេ")។ *រដ្ឋអាជ្ញា ទល់នឹង Galić*, សំណុំរឿងលេខ៖ IT-98-29—AR73.2 សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍បន្ទាន់បង្គំពាក់ព័ន្ធនឹងវិធាន៩២ស្ទួន(គ), ៧ មិថុនា ២០០២, កថាខណ្ឌទី១១។

[46] **E278** ឧបសម្ព័ន្ធ ១២ និង១៣ ដែលបានកែសម្រួលឡើងវិញ នៃសេចក្តីសន្និដ្ឋានរបស់ កសព, កថាខណ្ឌទី៤, ៣២។

ហេតុទាំងនោះត្រូវបានគូសបញ្ជាក់ដោយពណ៌ ហើយច្បាប់ចម្លងនៃកំណត់ហេតុដែលបានកែសម្រួលទាំងនោះ ក៏អាចឲ្យអង្គជំនុំជម្រះ និងគូភាគីរកបានហើយដែរ។ អាស្រ័យដោយការអនុម័តរបស់អង្គជំនុំជម្រះលើច្បាប់កោសលុប អភិក្រមនេះការពារសិទ្ធិរបស់ជនជាប់ចោទតាមរយៈការធានាថា ភ័ស្តុតាងអំពី អំពើ និងការប្រព្រឹត្តិរបស់ពួកគេ ត្រូវបានដកចេញពីកំណត់ហេតុដែលបានទទួលយក (វៀរលែងតែសាក្សីបានស្លាប់ឬមិនអាចរកបាន ដែលនៅក្នុងករណីណាក៏ដោយ ភ័ស្តុតាងគឺអាចទទួលយកបាន)[47]។

២២. មេធាវីការពារក្តី ខៀវ សំផន បានលើកឡើងថា "អង្គជំនុំជម្រះពុំគប្បីប្រកាន់យកវិធីសាស្ត្រវឹតត្បិតដែលកម្រិតត្រឹមតែការច្រានចោលនូវកំណត់ហេតុស្តាប់ចម្លើយ ដែលពាក់ព័ន្ធទៅនឹងអាកប្បកិរិយានៅក្នុងន័យដ៏តូចចង្អៀតនៃពាក្យពេជន៍នោះ របស់ជនចាប់ចោទ នោះឡើយ"[48] ដោយបានសំអាងថា គេត្រូវបកស្រាយពាក្យនោះដោយរួមបញ្ចូលនូវ "សេចក្តីថ្លែងណាមួយក៏ដោយដែលពាក់ព័ន្ធទៅនឹង៖ ១) រចនាសម្ព័ន្ធរដ្ឋបាល ២) ប្រព័ន្ធទំនាក់ទំនង ការងារ និង ៣) កំណត់ហេតុស្តាប់ចម្លើយ ដែលលើកឡើងអំពីអ្វីដែលដឹកាដំណោះស្រាយហៅជាទូទៅថា "មជ្ឈិម" (ពាក្យនេះសំដៅដល់គ្រប់អង្គភាពដែលធ្វើសេចក្តីសម្រេចទាំងអស់ របស់រដ្ឋភិបាលកម្ពុជាប្រជាធិបតេយ្យ)[49]។ យ៉ាងណាក៏ដោយ ដោយការនិយាយប្រាប់ដូច្នេះ ការលើកឡើងតែមួយគត់របស់ មេធាវីការពារក្តី ខៀវ សំផន ចំពោះ "ករណីយុត្តិសាស្ត្រដែលបានបង្កើតឡើង" ស្តីពីអំពើ និងការប្រព្រឹត្តរបស់ជនជាប់ចោទ[50] គឺសេចក្តីសម្រេចលើរឿងក្តី Milosevic ដែលអង្គជំនុំជម្រះនេះ បានយកមកពិចារណា (សម្រង់ខាងលើ) ហើយដែលមានការប្រុងប្រយ័ត្នចំពោះការពន្លាតវិធាន ៩២ស្ទួន[51] ។

២៣. មេធាវីការពារក្តី នួន ជា បានសំអាងស្រដៀងគ្នានេះដែរចំពោះការបកស្រាយដ៏ទូលំទូលាយមួយ ដែលបានដាក់ជូនថា អំពើ និងអាកប្បកិរិយារបស់ជនជាប់ចោទពាក់ព័ន្ធទៅលើសេចក្តីយោងណាមួយក៏ដោយចំពោះ "គណៈកម្មាធិការមជ្ឈិម អចិន្ត្រៃយ៍ ឬ យោធា" និងចំពោះ "អង្គការ មន្ទីរ៨៧០

[47] **E96/7** សេចក្តីសម្រេចលើកំណត់ហេតុរបស់អង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌទី៣២។

[48] **E277** ការដាក់ជូនរបស់ ខៀវ សំផន ស្តីពីច្បាប់អនុវត្ត, កថាខណ្ឌ ១៩។

[49] **E277** ការដាក់ជូនរបស់ ខៀវ សំផន ស្តីពីច្បាប់អនុវត្ត, កថាខណ្ឌ ២៦។ **E208/5** សេចក្តីជំទាស់របស់លោក ខៀវ សំផន, កថាខណ្ឌ ១៧-១៩។

[50] **E277** ការដាក់ជូនរបស់ ខៀវ សំផន ស្តីពីច្បាប់អនុវត្ត, កថាខណ្ឌ ១៩ និង កំណត់សម្គាល់ជើងទំព័រ លេខ២៥។

[51] **E277** ការដាក់ជូនរបស់ ខៀវ សំផន ស្តីពីច្បាប់អនុវត្ត, កំណត់សម្គាល់ជើងទំព័រ លេខ២៥ ដោយបានលើកឡើងពី *រដ្ឋអាជ្ញា ទល់នឹង Milosević*, សំណុំរឿងលេខ IT-02-54-T សេចក្តីសម្រេចលើសំណើរបស់អយ្យការស្នើសុំឲ្យទទួលយកសេចក្តីថ្លែងជាលាយលក្ខណ៍អក្សរ ដោយអនុលោមតាមវិធាន ៩២*ស្ទួន*, ២១ មីនា ២០០២, កថាខណ្ឌ ១៥។

គណៈមជ្ឈិម មេដឹកនាំជាន់ខ្ពស់ ក-១ ក-៣ ឬ ការហៅណាក៏ដោយដែលស្រដៀងគ្នា ក៏ដូចជាព័ត៌មានណាមួយក៏ដោយដែលបានទទួល ឬការបានដឹងឮដោយ ប៉ុល ពត[52]។ ដូចដែលបានបង្ហាញនៅខាងលើ ការណ៍នេះគឺមានភាពមិនដូចគ្នាយ៉ាងច្បាស់ក្រឡែត ជាមួយនឹងយុត្តិសាស្ត្រដែលបានដោះស្រាយ និងបានធ្វើការពន្លាតឃ្លាឃ្លោងឲ្យហួសពីអត្ថន័យដ៏សមហេតុផល និងឲ្យហួសពីនិយមន័យតាមផ្លូវច្បាប់របស់វាទៀតផង។

២៤. សហព្រះរាជអាជ្ញាយល់ស្របថា សេចក្ដីយោងជាក់លាក់ដ៏គ្រប់គ្រាន់ទាំងឡាយចំពោះជនជាប់ចោទក្នុងនាមជារូបវន្តបុគ្គល អាចគ្របដណ្ដប់លើ "អំពើ និងការប្រព្រឹត្តរបស់ជនជាប់ចោទ"។ ដូច្នេះ ឧទាហរណ៍ដែលមេធាវីការពារក្ដី នួន ជា បានផ្ដល់ជូនជាសេចក្ដីថ្លែងមួយពាក់ព័ន្ធនឹងប្រធានតំណាងសភាប្រជាជន គឺជាកម្មវត្ថុនៃការច្រានចោល ដោយសារគ្មានភ័ស្ដុតាងណាមួយដើម្បីជាសំអាងដែលថា មិនមានបុគ្គលដទៃទៀត បានកាន់កាប់តួនាទីនោះឡើយ[53]។ សហព្រះរាជអាជ្ញា បានអនុវត្តគោលការណ៍នេះ នៅក្នុងការបញ្ជាក់បន្ថែមអំពី អត្ថបទដែលទាក់ទងទៅនឹង អំពើ និងការប្រព្រឹត្តរបស់ជនជាប់ចោទនៅក្នុងកំណត់ហេតុស្ដាប់ចម្លើយសាក្សីដែលបានផ្ដល់ជូន។

២៥. យ៉ាងណាក៏ដោយ ការណ៍នេះមិនបានធ្វើយុត្តិកម្មលើការពន្លាត បន្ថែមឲ្យហួសពី គោលជំហរជាក់លាក់ណាមួយដែលនឹងធ្វើឲ្យ វិធានបែរទៅជាគ្មានប្រយោជន៍ នៅក្នុងគោលបំណង ធ្វើឲ្យប្រសើរឡើងនូវប្រសិទ្ធិភាពនៃសវនាការ និងធ្វើឲ្យមានការបំពានទៅលើវិធីសាស្ត្រដ៏ចង្អៀតដែល តុលាការ ICTY និង ICTR បានអនុម័តយកតាម[54] ហើយជាការសំខាន់បំផុតនោះ គឺការសម្រេច របស់អង្គជំនុំជម្រះនេះ។ ជាការពិត ផ្ទុយទៅនឹងការអះអាងរបស់មេធាវីការពារក្ដី នួន ជា នៅក្នុងរឿងក្ដី *Bagasora* តុលាការ ICTR បានច្រានចោលនូវភ័ស្ដុតាងស្ដីពី "ការប្រព្រឹត្តរបស់ បុគ្គលិកយោធាដែលគ្មានឈ្មោះ ថាជា អំពើ និងការប្រព្រឹត្តរបស់អ្នកនៅក្រោមបង្គាប់របស់ រដ្ឋមន្ត្រីការពារជាតិដែល

---

52 E96/8/1 អញ្ញត្រកម្មរបស់ នួន ជា, កថាខណ្ឌ ២៧។

53 E96/8/1 អញ្ញត្រកម្មរបស់ នួន ជា, កថាខណ្ឌ ២៧។ *សូមអាន រដ្ឋអាជ្ញា ទល់នឹង Blagojevic និង Jokic*, សំណុំរឿងលេខ IT-02-60-T, សេចក្ដីសម្រេចលើញត្តិរបស់រដ្ឋអាជ្ញា សុំឲ្យធ្វើវិសោធនកម្មលើបញ្ជីឈ្មោះសាក្សី និងសុំឲ្យទទួលយកភស្តុតាង ដោយអនុលោមតាមវិធាន ៩២*ស្ទួន*, ២៥ កញ្ញា ២០០៣, កថាខណ្ឌ ១៧។

54 *សូមអាន រដ្ឋអាជ្ញា ទល់នឹង Galić*, សំណុំរឿងលេខ IT-98-29AR73.2, សេចក្ដីសម្រេចលើបណ្ដឹងឧទ្ធរណ៍បន្ទាន់បង្ខំពាក់ព័ន្ធនឹងវិធាន ៩២ស្ទួន(គ), ៧ មិថុនា ២០០២, កថាខណ្ឌ ៩-១៣។ *រដ្ឋអាជ្ញា ទល់នឹង Édouard Karemera និងគូកន*, សំណុំរឿងលេខ ICTR-98-44-T, សេចក្ដីសម្រេចលើញត្តិរបស់អយ្យការ ស្នើសុំឲ្យទទួលយកភស្តុតាងស្ដីពីការរំលោភសេពសន្ថវៈ និងការបៀតបៀនផ្លូវភេទ ដោយអនុលោមតាមវិធាន ៩២*ស្ទួន* នៃវិធានផ្ទៃក្នុង និងសុំឲ្យចេញដីកាសម្រេចឲ្យកាត់បន្ថយបញ្ជីឈ្មោះសាក្សី របស់អយ្យការ, ១១ ធ្នូ ២០០៦, កថាខណ្ឌ ១០។

ជាចុងចោទ” [55] អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTR បានសម្រេចថា កំណត់ហេតុស្តាប់ចម្លើយ ដែលពាក់ព័ន្ធនានាមិនបានដាក់ទៅដើម្បីជាទឡ្ហីករណ៍ស្តីពី អំពើ និងការប្រព្រឹត្តរបស់ជនជាប់ចោទ ដូចដែលបានចោទប្រកាន់នោះឡើយ ហេតុដូច្នេះហើយ កំណត់ហេតុទាំងនោះអាចទទួលយកបានអនុលោមតាមវិធាន៩២*ស្ទួន* [56]។ ស្រដៀងគ្នានេះដែរ មេធាវីការពារក្តី នួន ជា បានបកស្រាយខុស ពីសេចក្តីសម្រេចក្នុងរឿងក្តី *Brdanin* ដែលមេធាវីការពារបានទាមទារឲ្យ ដកចេញនូវ “ភ័ស្តុតាងស្តីពី “ទាហាន” ដែលគ្មានឈ្មោះ ប្រឆាំងនឹងចុងចោទជាឧត្តមសេនីយ៍”[57]។ តាមអង្គហេតុពិត សេចក្តីថ្លែងរបស់សាក្សីពីរនាក់ក្នុង ចំណោមសាក្សីនានាដែលមាននៅក្នុងកថាខណ្ឌដែលបានលើកឡើង ត្រូវបានពិចារណាថាលែងមានការចាំបាច់ទៀតហើយ[58] ពីព្រោះគេបានដកវាចេញហើយ រីឯ ភ័ស្តុតាងដែលទាក់ទងទៅនឹងសាក្សីក្នុងក្រុមទីពីរវិញនោះ អង្គជំនុំជម្រះបានកត់សម្គាល់ថា “វិធានមិនបានហាម់ឃាត់ដាច់ខាតមិនឲ្យទទួលយក កំណត់ហេតុស្តាប់ចម្លើយ ដែលផ្តល់សក្ខីកម្មចំពោះអ្នកនៅក្រោមបង្គាប់ដែលត្រូវបានចោទប្រកាន់នោះឡើយ” ហើយអាចទទួលយក កំណត់ហេតុស្តាប់ចម្លើយទាំងនេះ ដោយអនុលោមតាមវិធាន៩២*ស្ទួន* [59]។

---

55 E96/8/1 អញ្ញត្រកម្មរបស់ នួន ជា, កំណត់សម្គាល់ជើងទំព័រ លេខ៥៤។

56 *រដ្ឋអាជ្ញា ទល់នឹង* Bagosora *និងគូកន*, សេចក្តីសម្រេចលើញត្តិរបស់រដ្ឋអាជ្ញា ស្នើសុំឲ្យទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សីដោយអនុលោមតាមវិធាន ៩២*ស្ទួន*, ៩ មីនា ២០០៤, កថាខណ្ឌ ២៥។

57 E96/8/1 អញ្ញត្រកម្មរបស់ នួន ជា, កំណត់សម្គាល់ជើងទំព័រ លេខ៥៤។

58 *រដ្ឋអាជ្ញា ទល់នឹង* Brdanin, សំណុំរឿងលេខ IT-99-36-T, សំណៅសាធារណៈនៃសេចក្តីសម្រេចសម្ងាត់ស្តីពីការទទួលយកសេចក្តី ថ្លែងតាមវិធាន ៩២ស្ទួន ចុះថ្ងៃទី១ ខែឧសភា ឆ្នាំ ២០០២, ២៣ ឧសភា ២០០២, កថាខណ្ឌ ៦។

59 *រដ្ឋអាជ្ញា ទល់នឹង* Brdanin, សំណុំរឿងលេខ IT-99-36-T, សំណៅសាធារណៈនៃសេចក្តីសម្រេចសម្ងាត់ស្តីពីការទទួលយក សេចក្តីថ្លែងតាមវិធាន ៩២ស្ទួន, សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍បន្ទាន់បង្ខំពាក់ព័ន្ធនឹងវិធាន ៩២ស្ទួន(គ) ចុះថ្ងៃទី១ ខែឧសភា ឆ្នាំ ២០០២, ២៣ ឧសភា ២០០២, កថាខណ្ឌ ២៤-២៦។ មេធាវីការពារក្តី នួន ជា លើកឡើងនូវប្រភពច្បាប់ពីរផ្សេងទៀតសម្រាប់ការបកស្រាយយ៉ាងទូលំទូលាយរបស់ខ្លួនស្តីពី “អំពើ និង អាកប្បកិរិយា”។ ទីមួយ *រដ្ឋអាជ្ញា ទល់នឹង* Popovic *និងគូកន*, គឺអាចសម្គាល់បានយ៉ាងច្បាស់លាស់ថាប្លែកគ្នាពីសេចក្តីថ្លែងដែលសហព្រះរាជអាជ្ញាបានដាក់ជូន។ នៅក្នុងរឿងក្តី *Popovic* អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា ភស្តុតាងពាក់ព័ន្ធនឹង<u>ការប្រជុំមួយដ៏ជាក់លាក់ដែលគេបានចោទប្រកាន់ថាជនជាប់ចោទថាបានចូលរួម</u> ហើយដូច្នេះ “ដោយមិនបានដាក់ឈ្មោះគាត់ សាក្សីបានរៀបរាប់ពីព្រឹត្តិកាណ៍មួយដែលនៅក្នុងនោះ Popovic បានចូលរួម”។ ទាក់ទងទៅនឹងសេចក្តីសម្រេចទីពីរគឺ *រដ្ឋអាជ្ញា ទល់នឹង Karemera*, សហព្រះរាជអាជ្ញាសូមជូនសេចក្តីសន្និដ្ឋានថា សេចក្តីសម្រេចនោះមិនត្រូវគ្នាទៅនឹងសេចក្តីសម្រេចដែលគ្រប់គ្រងលើអង្គជំនុំជម្រះសាលាឧទ្ធរណ៍ នៅក្នុងរឿងក្តី *Galić* នោះឡើយ ហើយនៅក្នុងករណីណាក៏ដោយ វាមិនអាចអនុវត្តបានចំពោះវិធីសាស្ត្រដែលអង្គជំនុំជម្រះនេះបានទទួលធ្វើតាមនោះទេ។ នៅក្នុងរឿងក្តី *Karemera* តុលាការបានរកឃើញថាសេចក្តីយោងនានាចំពោះប្រភេទនៃបុគ្គល ដូចជា “បុគ្គលិកលក្ខណៈជាក់លាក់មួយចំនួនរបស់រដ្ឋាភិបាល និង គណៈបក្ស MRND” ជាដើមបានយកទៅធ្វើជា អំពើ និង អាកប្បកិរិយារបស់ជនជាប់ចោទ។ ជាថ្មីម្តងទៀត ការបកស្រាយបែបដូច្នេះដែលផ្ទុយទៅនឹងការបកស្រាយប្រយោគ “អំពើ និង អាកប្បកិរិយារបស់ជនជាប់ចោទ” ដែលអង្គជំនុំជម្រះនានានៃតុលាការ*ចំពោះកិច្ច (ad hoc)* បានទទួល យក

២៦. ដើម្បីអនុវត្តតាមភាសារបស់អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY នោះការបកស្រាយដែលមេធាវីការពារក្តីបានស្នើឡើង គឺ "បានធ្វើឱ្យការប្រើប្រាស់ដ៏ពិតប្រាកដនូវវិធាន ៩២ស្ទួន(ក) នៅសល់តែទទេ" ឡើយ ហើយ "មិនមានភាពរលូនជាមួយនឹងគោលបំណង ព្រមទាំងពាក្យពេជន៍នៃវិធាននោះ" ថែមទៀតផង[60]។ សហព្រះរាជអាជ្ញា សូមជូនសេចក្តីសន្និដ្ឋានថា អង្គជំនុំជម្រះសាលាដំបូងត្រូវធ្វើការបញ្ជាក់អះអាងអំពីការដែលខ្លួនព្រមទទួលយកការសាកល្បងដ៏ត្រឹមត្រូវតាមផ្លូវច្បាប់ ហើយត្រូវបដិសេធចោល នូវការដាក់ជូន និងសេចក្តីជំទាស់នានាពីសំណាក់មេធាវីការពារក្តី ដោយមានមូលដ្ឋាននៅលើរឿងទាំងនោះ។

### ៣. ថាតើភ័ស្តុតាងទាំងនោះដោះស្រាយបញ្ហាស្នូល ឬអំពើអ្នកនៅក្រោមបង្គាប់ឬទេ

២៧. ដូចបានធ្វើការកត់សំគាល់នៅក្នុងវាក្យខណ្ឌ II.១ ខាងលើ មេធាវីការពារក្តីបានតវ៉ាថា អង្គជំនុំជម្រះត្រូវអនុវត្តឱ្យបានតឹងរ៉ឹងចំពោះលក្ខខណ្ឌតម្រូវទាំងអស់នៃវិធាន៩២ស្ទួន របស់តុលាការ ICTY/ ICTR រួមទាំងកាតព្វកិច្ចក្នុងការពិចារណាឡើងវិញ ទាក់ទងនឹងកំណត់ហេតុនិមួយៗ ថាតើម្ចាស់កំណត់ហេតុទាំងនោះ គួរកោះហៅឱ្យមកប្រឈមនឹងការសួរដេញដោលសាក្សីរបស់ភាគីបដិបក្ខ (ទោះបីជាកំណត់ហេតុនោះមិនសំដៅទៅរកអំពើ និងការប្រព្រឹត្តិរបស់ជនជាប់ចោទក៏ដោយ)។ ដូចបានបង្ហាញជូនក្នុងវាក្យខណ្ឌ II.១ និង II.២ អភិក្រមរបស់អង្គជំនុំជម្រះនៅក្នុងការមិនធ្វើអាហារ័ណនូវផ្នែកនេះនៃវិធាន បានឆ្លុះបញ្ចាំងយ៉ាងសមស្របនូវភាពខុសគ្នារវាងនីតិវិធីរបស់តុលាការ*ពិសេស*នានា និងនីតិវិធីក្នុងប្រព័ន្ធច្បាប់រដ្ឋប្បវេណីរបស់ អ.វ.ត.ក ហើយស៊ីសង្វាក់គ្នានឹងលក្ខខណ្ឌតម្រូវស្តីពីសិទ្ធិក្នុងការទទួលបានសវនាការមួយដែលត្រឹមត្រូវ។ ដូច្នេះសេចក្តីសន្និដ្ឋានរបស់មេធាវីការពារក្តី គួរត្រូវបានបដិសេធចោល។

២៨. ដើម្បីឱ្យមានលក្ខណៈពេញលេញ សហព្រះរាជអាជ្ញាកត់សំគាល់ថាក្នុងករណីណាក៏ដោយ មេធាវីការពារក្តីបានធ្វើការបកស្រាយដោយមិនត្រឹមត្រូវអំពីវិសាលភាពនៃការពិចារណា ដែលនឹងមានឥទ្ធិពលទៅដល់ការដេញដោលសាក្សីរបស់ភាគីបដិបក្ខតាមវិធាន៩២ស្ទួន(គ)។ ក្នុងសេចក្តីសម្រេចនៃរឿងក្តី *Galić* ដ៏មានឥទ្ធិពល អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY បានសម្រេចថា សន្តាន

---

ដែលអង្គជំនុំជម្រះនេះបានធ្វើការលើកឡើងនោះ នឹងធ្វើឱ្យនីតិវិធីនៃវិធាន ៩២*ស្ទួន* មិនមានប្រសិទ្ធិភាពយ៉ាងជាក់ស្តែងពិតប្រាកដ។ *រដ្ឋអាជ្ញា ទល់នឹង Popovic និងគូកន*, សំណុំរឿងលេខ IT-05-88-T, សេចក្តីសម្រេចលើញត្តិ*សម្ងាត់*របស់អយ្យការ ស្នើសុំឱ្យទទួលយកភស្តុតាងជាលាយលក្ខណ៍អក្សរ ជាជំនួសឱ្យសក្ខីកម្ម*ដោយផ្ទាល់មាត់ (Viva Voce)* ដោយអនុលោមតាមវិធាន ៩២*ស្ទួន*, ១២ កញ្ញា ២00៦, កថាខណ្ឌ ៥៧។ *រដ្ឋអាជ្ញា ទល់នឹង Karemera និងគូកន*, សេចក្តីសម្រេចលើញត្តិរបស់រដ្ឋអាជ្ញា ស្នើសុំឱ្យទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សីពី Joseph Serugendo, ១៥ ធ្នូ ២00៦, កថាខណ្ឌ ៩។

60 *រដ្ឋអាជ្ញា ទល់នឹង Galić*, សំណុំរឿងលេខ IT-98-29AR73.2, សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍បន្ទាន់បង្ខំពាក់ព័ន្ធនឹងវិធាន ៩២ស្ទួន(គ), ៧ មិថុនា ២00២, កថាខណ្ឌ ៩។

(ភាពជិតស្និទ្ធទៅនឹងជនជាប់ចោទនៃបុគ្គលណាម្នាក់ ដែលអំពើរបស់បុគ្គលត្រូវបានរៀបរាប់នៅក្នុងកំណត់ហេតុ (មិនថាជាអ្នកក្រោមបង្គាប់ ឬជនណាម្នាក់ផ្សេងឡើយ ទាក់ទងនឹងអំពើដែលជនជាប់ចោទត្រូវបានចោទប្រកាន់ចំពោះការទទួលខុសត្រូវ) គឺជាការពិចារណាដែលពាក់ព័ន្ធនៅក្នុងការប្រើឆន្ទានុសិទ្ធិ ដើម្បីបង្គាប់ឲ្យមានការសួរដេញដោលសាក្សីរបស់ភាគីបដិបក្ខ។ បើសិនជាភ័ស្តុតាងជាស្នូលចំពោះករណីចោទប្រកាន់ និងប្រសិនបើជននោះជៀក ជាមួយនឹងជនជាប់ចោទ តុលាការ *ពិសេស* អាចសម្រេចថា អ្នកបង្កើតកំណត់ហេតុគួរត្រូវបានកោះហៅឲ្យមកផ្តល់សក្ខីកម្មដោយបុគ្គលរូបនោះផ្ទាល់[61]។ ដូច្នេះ តាមវិធានរបស់តុលាការ ICTY/ICTR វាជាបន្ទុករបស់ភាគីជំទាស់ក្នុងការបង្ហាញឲ្យឃើញថា សម្រាប់កំណត់ហេតុនិមួយៗ ហេតុអ្វីបានជាភ័ស្តុតាងនោះជាសន្តានទៅនឹងជនជាប់ចោទ ឬមានសារសំខាន់ជាស្នូលទៅដល់រឿងក្តី និងថាហេតុអ្វីបានជាអង្គជំនុំជម្រះសាលាដំបូងគួរតែប្រើឆន្ទានុសិទ្ធិរបស់ខ្លួន ដើម្បីផ្តល់ឱកាសដល់គូភាគីនានាដើម្បីសួរដេញដោលសាក្សីរូបនោះ។

២៩. ទាំងមេធាវីការពារក្តី ខៀវ សំផន និងទាំងមេធាវីការពារក្តី នួន ជា សន្និដ្ឋានថា ភ័ស្តុតាងដែលពាក់ព័ន្ធទៅនឹងប្រធានបទទូលំទូលាយដូចជា រចនាសម្ព័ន្ធរដ្ឋបាល យោធា និងការប្រាស្រ័យទំនាក់ទំនងរបស់ បកក ឬបញ្ហាផ្សេងទៀតដែលកំពុងតែមានទំនាស់ ពុំគួរទទួលយកឡើយនៅក្នុងពេលដែលមិនមានការសួរដេញដោលសាក្សីរបស់ភាគីបដិបក្ខ[62]។ អំណះអំណាងណាមួយដែលថា ភ័ស្តុតាង *ណាមួយ* ដែលពាក់ព័ន្ធនឹងបញ្ហាទូលំទូលាយដូច្នេះចាំបាច់ត្រូវតែមានតម្លៃស្មើនឹង ភ័ស្តុតាងនៃអំពើ និងការប្រព្រឹត្តិរបស់អ្នកនៅក្រោមបង្គាប់ផ្ទាល់របស់ជនជាប់ចោទ ឬបញ្ហាផ្សេងៗសំខាន់ជាស្នូល ដែលឱកាសក្នុងការដេញដោលក្នុងពេលសវនាការត្រូវតែបានផ្តល់ឲ្យ គឺវាហួសពីលក្ខខណ្ឌតម្រូវដែលមានចែងនៅក្នុងវិធាន៨២ស្ទួន។ ដូចអង្គជំនុំជម្រះសាលាដំបូង បានធ្វើការកត់សំគាល់យ៉ាងត្រឹមត្រូវថា ក្របខណ្ឌច្បាប់ និងយុត្តិសាស្ត្ររបស់តុលាការ*ពិសេស*នានាហាក់ដូចជាមិនច្រានចោលភ័ស្តុតាងពាក់ព័ន្ធនឹង "គោលនយោបាយទូទៅ រចនាសម្ព័ន្ធនៃការប្រាស្រ័យទំនាក់ទំនង និងអត្ថិភាពនៃផែនការឧក្រិដ្ឋកម្មរួម"[63]ទេ។ អាស្រ័យហេតុនេះ សូម្បីតែវិធាន៨២ស្ទួន(គ) អាចអនុវត្តបាននៅចំពោះមុខ អ.វ.ត.ក ក៏ដោយ (ដែលអាស្រ័យដោយការសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង គឺគេមិនអាច) ក៏មេធាវីការពារក្តីគួរតែបរាជ័យក្នុងការបំពេញនូវបន្ទុករបស់ខ្លួនដោយសារ៖ ក) ការដាក់

---

[61] *វដ្តអាជ្ញា ទល់នឹង* Galic, 'សាលដីកាលើបណ្តឹងឧទ្ធរណ៍បន្ទាន់បង្គំពាក់ព័ន្ធនឹងវិធាន៩២ស្ទួន(គ)', ៧ មិថុនា ២០០២, ត្រង់កថាខណ្ឌទី១៣។

[62] **E277** សេចក្តីសន្និដ្ឋានរបស់ ខៀវ សំផន ស្តីពីច្បាប់ជាធរមាន, ត្រង់កថាខណ្ឌទី២៦។ **E208/5** សេចក្តីជំទាស់របស់ ខៀវ សំផន, ត្រង់កថាខណ្ឌទី១៩ និង **E223/2/8** សេចក្តីជំទាស់របស់ នួន ជា, ២៦ មេសា ២០១៣, ត្រង់កថាខណ្ឌទី៣៤-៣៩។

[63] **E96/7** សេចក្តីសម្រេចលើកំណត់ហេតុ, ត្រង់កថាខណ្ឌទី២១។

ការជំទាស់មានន័យទូលំទូលាយហួសហេតុ និង ខ) ការខកខានមិនបានបង្ហាញពីកំណត់ហេតុនិមួយៗ ថាហេតុអ្វីបានជាអង្គជំនុំជម្រះត្រូវប្រើឆន្ទានុសិទ្ធិរបស់ខ្លួនដើម្បីកោះហៅសាក្សីនោះ។

៣០. សហព្រះរាជអាជ្ញាសន្និដ្ឋានថាគ្រប់កំណត់ហេតុទាំងអស់ដែលបានដាក់ជូន អាចនឹងបង្ហាញពីបញ្ហាដែលបានអនុញ្ញាត ដូចជាព្រឹត្តិការណ៍ស្តីពីមូលដ្ឋានឧក្រិដ្ឋកម្ម សាវតាប្រវត្តិសាស្ត្រ/សាវតាយោធា/សាវតានយោបាយ រចនាសម្ព័ន្ធទូទៅ និងការប្រាស្រ័យទំនាក់ទំនង ផលប៉ះពាល់នៃបទឧក្រិដ្ឋទៅលើជនរងគ្រោះ និងធាតុផ្សំគ្របដណ្តប់ជាទូទៅ (*chapeau*) ចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ អាស្រ័យដោយហេតុថា កំណត់ហេតុមួយចំនួនមានកំណត់ អាចនឹងមានចំណែកណាមួយស្របទៅតាមលក្ខណវិនិច្ឆ័យដ៏តឹងរ៉ឹងនៃវិធាន៩២ស្ទួន(គ)នោះ ការទទួលយកកំណត់ទាំងនេះដោយគ្មានការសួរដេញដោល ក៏មិនបានច្រានចោលជាមុននៅ អ.វ.ត.ក នេះដែរ អាស្រ័យដោយ៖ ក) ភាពជឿទុកចិត្តបានចំពោះកំណត់ហេតុទាំងនោះ / ការពិតដែលកំណត់ហេតុមួយចំនួនធំ ត្រូវបានប្រមូលទាំងស្រុង និងដោយឯករាជ្យរបស់សហព្រះរាជអាជ្ញា និង ខ) ការការពារដែលមានជាប់មកជាមួយក្នុងគុណវុឌ្ឍិរបស់អង្គជំនុំជម្រះ ដើម្បីកាត់បន្ថយនូវតម្លៃភស្តុតាងដែលមានចំពោះកំណត់ហេតុដែលបានទទួលយកដោយពុំចាំបាច់មានការសួរដេញដោលរបស់ភាគីបដិបក្ខ។

៣១. ក្រុមមេធាវីការពារក្តីរបស់ ខៀវ សំផន លើកឡើងថាកំណត់ហេតុស្តាប់ចម្លើយសាក្សីដែលទាក់ទងទៅនឹងទីតាំងឧក្រិដ្ឋកម្មនានាដែលស្ថិតនៅក្រៅវិសាលភាពនៃសំណុំរឿងលេខ00២/0១ គឺមិនអាចទទួលយកបានឡើយ នៅក្នុងសវនាការជំនុំជម្រះក្តីនេះ។ ក្រុមមេធាវីការពារក្តីបានអះអាងដោយមានចម្ងល់ថា ដោយសារបានសម្រេច ឲ្យមានការបំបែកកិច្ចដំណើរការនីតិវិធីនៃសំណុំរឿងនេះ អង្គជំនុំជម្រះបានកំណត់ *តាមព្រឹត្តិន័យ* ថា ខ្លួន "ពុំមានយុត្តាធិការ" ដើម្បីធ្វើការពិចារណាលើភស្តុតាងពាក់ព័ន្ធនឹងទីតាំងឧក្រិដ្ឋកម្មនានា ដែលមិនដាក់បញ្ចូលនៅក្នុងសវនាការនេះនោះទេ[64]។ ក្រុមមេធាវីការពារក្តីថែមទាំងបានលើកឡើងទៀតថា នោះគឺជាលើកទីមួយហើយដែលសហព្រះរាជអាជ្ញា បានទទូចសុំឲ្យ ដាក់បញ្ចូលនូវគោលនយោបាយសហកម្មឧក្រិដ្ឋកម្មរួមចំនួនប្រាំ ដែលបានចោទប្រកាន់នៅក្នុងដីកាដំណោះស្រាយដែលជាប់ទាក់ទងទៅនឹងភស្តុតាងអំពីការវាយប្រហារជាទ្រង់ទ្រាយធំ និងជាប្រព័ន្ធប្រឆាំងនឹងប្រជាជនស៊ីវិលរបស់កម្ពុជា[65]។ នួន ជា ក៏បានលើកឡើងដែរថា ទីតាំងឧក្រិដ្ឋកម្មនានាដែលជាប់ពាក់ព័ន្ធដែលស្ថិត នៅក្រៅវិសាលភាពនៃសំណុំរឿងលេខ00២/0១ គឺមិនអាចទទួលយកបានទេ

[64] ជំទាស់របស់ខៀវ សំផន, កថាខណ្ឌ ៣៤-៣៥។

[65] ជំទាស់របស់ខៀវ សំផន, កថាខណ្ឌ ៣៩។ គួរកត់សំគាល់ថា អត្ថបទខ្លីដែលបានដកស្រង់សំដីដោយមេធាវីរបស់ ខៀវ សំផន មិនបានគាំទ្រដល់ការពោលអះអាងរបស់ពួកគេឡើយ។ ក្នុងនោះមានសេចក្តីសង្កេតរបស់សហព្រះរាជអាជ្ញាថា បន្ទាប់ពីការបំបែកកិច្ចដំណើរការនីតិវិធីនៃសំណុំរឿង, សកម្មភាពឧក្រិដ្ឋនានាដែលកើតឡើងពីគោលនយោបាយទាំងប្រាំនោះនឹងត្រូវបានលប់ចេញពីសវនាការ មិនមែនអត្ថិភាពនៃគោលនយោបាយនោះទេ។

និងបានពោលអះអាងថែមទៀតថា អង្គជំនុំជម្រះបានដកចេញពីការពិចារណា សម្រាប់សវនាការជំនុំជម្រះបច្ចុប្បន្ននេះ នូវគោលនយោបាយណាមួយចំនួនដែលមិនជាប់ពាក់ព័ន្ធគ្នាជាមួយនឹងទីតាំងឧក្រិដ្ឋកម្មជាក់លាក់នានា ដែលបានលើកឡើងនៅក្នុងសំណុំរឿងលេខ០០២/០១[66]។

៣២. ទី១ សហព្រះរាជអាជ្ញា សូមធ្វើការកត់សំគាល់ថា ក្រុមមេធាវីការពារក្តីរបស់ នួន ជា កាលពីមុនធ្លាប់បានសម្រេចចិត្តធ្វើសារណាដែលផ្ទុយគ្នាម្តង ទាក់ទងនឹងចម្លើយនានាដែលពាក់ព័ន្ធនឹងទីតាំងឧក្រិដ្ឋកម្មដែលមិនស្ថិតនៅក្នុងវិសាលភាពនៃសំណុំរឿងលេខ០០២/០១ ។ នៅក្នុងអញ្ញត្រកម្មបឋមរបស់ខ្លួនដែលត្រូវបានដាក់បញ្ចូលដោយយោង នៅក្នុងការដាក់សារណារបស់ខ្លួនថ្មីៗបំផុតនេះ[67] ក្រុមមេធាវីការពាររបស់ នួន ជា បានទទួលយល់ព្រមថាចម្លើយដែលទាក់ទងនឹងទីតាំងឧក្រិដ្ឋកម្មនានាដែលពាក់ព័ន្ធនឹងទីតាំងឧក្រិដ្ឋកម្មហើយដែលស្ថិតនៅក្រៅវិសាលភាពនៃសំណុំរឿងលេខ០០២/០១ គឺ "ទំនងជាអាចទទួលយកបានដោយមិនបាច់មានការសួរដេញដោលដោយភាគីបដិបក្ស"...[ដើម្បីគោលបំណងបង្ហាញភ័ស្តុតាង] អំពីអត្ថិភាពនៃការវាយប្រហារទូលំទូលាយ និងជាប្រព័ន្ធ"[68]។

៣៣. ទីពីរ ការអះអាងរបស់ក្រុមមេធាវីការពាររបស់ នួន ជា ដូចជា អំពីការលុបចោលនូវគោលនយោបាយជាក់លាក់ខ្លះពីក្នុងសវនាការនេះ គឺមានកំហុស ។ ដូចដែលក្រុមមេធាវីការពារក្តីរបស់ ខៀវ សំផន បានទទួលស្គាល់ថា តាមពិត អង្គជំនុំជម្រះសាលាដំបូងបានដាក់បញ្ចូលនៅក្នុងសវនាការនេះនូវការសួរដេញដោលមួយទៅលើគោលនយោបាយទាំងប្រាំរបស់ បកក ដែលបានរៀបរាប់នៅក្នុងដីកាដំណោះស្រាយ [69]។ ការកម្រិត ដែលទាក់ទងទៅនឹងគោលនយោបាយនានាដែលមិនជាប់ទាក់ទងដោយផ្ទាល់ទៅនឹងទីតាំងឧក្រិដ្ឋកម្មនានានៅក្នុងសំណុំរឿងលេខ០០២/០១ គឺថា អង្គជំនុំជម្រះនឹងពិចារណាអំពីការរីកចំរើន និងអំពីអត្ថិភាពនៃគោលនយោបាយទាំងនោះ ប៉ុន្តែនឹងមិនចូលទៅដល់ពិចារណាលំអិត

[66] ការជំទាស់របស់ នួន ជា ចុះថ្ងៃទី២៦ មេសា ២០១៣, កថាខណ្ឌទី ២១-២៣។

[67] ការជំទាស់របស់ នួន ជា ចុះថ្ងៃទី២៦ មេសា ២០១៣, កថាខណ្ឌទី ៦។

[68] ការជំទាស់បឋមរបស់ នួន ជា ចុះថ្ងៃទី២៦ មេសា ២០១៣, កថាខណ្ឌទី៣៨។

[69] ការជំទាស់របស់ ខៀវ សំផន, កថាខណ្ឌទី៣១។ឯកសារលេខ E124/7.3 បញ្ជីកថាខណ្ឌ និងផ្នែកនានានៃដីកាដំណោះស្រាយដែលទាក់ទងនឹងសំណុំរឿងលេខ០០២/០១ ដែលត្រូវបានកែប្រែបន្ថែមទៅលើសេចក្តីសម្រេចរបស់អង្គជំនុំជម្រះ ស្តីពីបញ្ហាកាយសម្បទា និងសតិបញ្ញាស្មារតីរបស់ អៀង ធីរិទ្ធ ក្នុងការចូលរួមសវនាការ (ឯកសារ E138) និងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើរបស់សហព្រះរាជអាជ្ញាសុំឲ្យដាក់បញ្ចូលនូវទីតាំងឧក្រិដ្ឋកម្មបន្ថែមនៅក្នុងវិសាលភាពនៃការជំនុំជម្រះនៅក្នុងសំណុំរឿងលេខ 002/01 (ឯកសារ E163), កថាខណ្ឌទី១(vi)។

អំពីការអនុវត្តទេ[70]។ ដូចដែលអង្គជំនុំជម្រះបានថ្លែងនៅពេលធ្វើការបញ្ជាក់បំភ្លឺអំពីវិសាលភាពនៃសំណុំរឿងលេខ00២/0១ ថា "ខ្លួននឹងផ្ដល់ការពិចារណាទៅលើតួនាទី និងការទទួលខុសត្រូវរបស់ជនជាប់ចោទទាក់ទងទៅនឹងរាល់គោលនយោបាយទាំងអស់ ដែលជាប់ពាក់ព័ន្ធនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះទាំងមូល" ដោយកម្រិត "ការពិចារណាទាក់ទងនឹងអង្គហេតុដោយលំអិត" របស់ខ្លួនត្រឹមតែគោលនយោបាយនានាដែលជាប់ទាក់ទងគ្នាយ៉ាងជាក់លាក់ ទៅនឹងទីតាំងឧក្រិដ្ឋកម្មនានាដែលបានដាក់បញ្ចូលនៅក្នុងសំណុំរឿងលេខ00២/0១ តែប៉ុណ្ណោះ[71]។ ទីបី ការទាមទាររបស់ក្រុមមេធាវីការពារក្ដី ខៀវ សំផន ដែលថា អង្គជំនុំជម្រះបានប្រគល់ឲ្យខ្លួនឯងនូវយុត្តាធិការទាក់ទងនឹងឧក្រិដ្ឋកម្ម ដែលនៅក្រៅពីវិសាលភាពនៃសំណុំរឿងលេខ00២/0១ គឺច្បាស់ណាស់ថា គ្មានអង្គសេចក្ដី។ នៅពេលដែលអង្គជំនុំជម្រះបានសម្រេចថា ខ្លួននឹងមិនចេញសាលក្រមលើទីតាំងឧក្រិដ្ឋកម្មបន្ថែមទាំងនេះ នៅក្នុងដំណាក់កាលនៃការជំនុំជម្រះមួយនេះនោះទេ អង្គជំនុំជម្រះបានទទួលយកនូវភ័ស្តុតាងអំពីឧក្រិដ្ឋកម្មនានាដែលបានប្រព្រឹត្តនៅទូទាំងប្រទេសកម្ពុជាទាំងមូល ធ្វើជាផ្នែកនៃការពិចារណារបស់ខ្លួនស្ដីពីរចនាសម្ព័ន្ធនៃសិទ្ធិអំណាច និងគោលនយោបាយរបស់ បកក។

៣៤. ទីបួន ផ្ទុយពីការលើកឡើងរបស់ក្រុមមេធាវីការពារក្ដីរបស់ ខៀវ សំផន សហព្រះរាជអាជ្ញាបានសង្កត់ធ្ងន់អំពីបន្ទុក ក្នុងការបង្ហាញភ័ស្តុតាងរបស់ខ្លួនដែលទាក់ទងទៅនឹងទាំងគោលនយោបាយទាំងប្រាំនៅក្នុងដីកាដំណោះស្រាយ និងទាំងអត្ថិភាពនៃការវាយប្រហារដ៏ទូលំទូលាយ និងជាប្រព័ន្ធប្រឆាំងនឹងប្រជាជនស៊ីវិលនៃប្រទេសកម្ពុជាទាំងមូល ចាប់តាំងពីដំណាក់កាលដំបូងបង្អស់នៃការជំនុំជម្រះក្ដីមក[72]។ លើសពីនេះ កថាខណ្ឌនានានៃដីកាដំណោះស្រាយដែលត្រូវបានដាក់បញ្ចូលនៅក្នុងការ

---

70 ឯកសារលេខ E141 ចម្លើយតបទៅនឹងបញ្ហាផ្សេងៗដែលបានលើកឡើងដោយភាគីនានានៅមុនពេលជំនុំជម្រះក្ដី និងការកំណត់កាលវិភាគសំរាប់ការប្រជុំមិនផ្លូវការជាមួយមន្ត្រីជាន់ខ្ពស់តទួលបន្ទុកផ្នែកច្បាប់ កាលពីថ្ងៃទី១៨ វិច្ឆិកា ២0១១, ថ្ងៃទី១៧ វិច្ឆិកា ២0១១, ត្រង់ទំព័រ២។

71 ឯកសារលេខ E124/7 សេចក្ដីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាសុំឲ្យពិចារណាឡើងវិញអំពីលក្ខខណ្ឌនានានៃដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីនិងសំណើសុំពាក់ព័ន្ធនានារបស់អង្គជំនុំជម្រះសាលាដំបូង(ឯកសារ E124/2) ព្រមទាំងឧបសម្ព័ន្ធចុះថ្ងៃទី១៨ តុលា ២0១១, កថាខណ្ឌទី១១។

72 សូមអានឧទាហរណ៍ដូចជា សេចក្ដីសន្និដ្ឋានដែលធ្វើឡើងដោយជំនួយការជាន់ខ្ពស់របស់សហព្រះរាជអាជ្ញា លោក Tarik Abdulhak កាលពីថ្ងៃទី១៣ មីនា ២0១២: ឯកសារលេខ **E1/47.1** ប្រតិចារិក, ត្រង់ទំព័រទី ៥៤-៥៥:១៦ "បញ្ហាបន្ថែមមួយដែលទាក់ទងបញ្ហាស្ដីពីការជាប់ទាក់ទងគ្នា, តាមពិតទៅ គឺជាភស្តុតាងអំពីធាតុផ្សំខាងបរិបទនៃឧក្រិដ្ឋកម្មនានា។ ដូចនេះ វិធីសាស្ត្រក្នុងការដាក់ទុកមួយឡែកសិនរបស់លោកប្រធាននៅក្នុង --រួមបញ្ចូលនៅក្នុងធាតុផ្សំសំរាប់

ជំនុំជម្រះនេះ ធ្វើឲ្យឃើញយ៉ាងជាក់ស្តែងអំពីការតភ្ជាប់ទំនាក់ទំនងរវាងអត្ថិភាពនៃគោលនយោបាយទាំងប្រាំ និង ការរកឃើញអំពីការវាយប្រហារមួយដ៏ទូលំទូលាយ និងជាប្រព័ន្ធ[73]។

៣៥. ការទទួលយកនូវ កំណត់ហេតុស្តាប់ចម្លើយមួយចំនួនតូច និងដែលអាចគ្រប់គ្រងបាន សម្រាប់ទីតាំងឧក្រិដ្ឋកម្មនីមួយៗនៃសំណុំរឿងលេខ00២ ដែលនៅក្រៅពីវិសាលភាពនៃសំណុំរឿងលេខ00២/0១ គឺជាការត្រឹមត្រូវផង និងមានចាំបាច់ផង។ កំណត់ហេតុស្តាប់ចម្លើយនានារបស់បុគ្គលដែលបានធ្វើជាសាក្សីផ្តល់ភ័ស្តុតាងអំពីការប្រព្រឹត្តឧក្រិដ្ឋកម្មផ្សេងៗ ក្នុងការដែលបានជួយបង្ហាញបន្ថែមពីគោលនយោបាយទាំងឡាយដូចដែលបានរៀបរាប់នៅក្នុងដីកាដំណោះស្រាយឲ្យ រិតតែច្បាស់ពីធាតុផ្សំនៃភ័ស្តុតាងអំពី*អត្ថិភាព*នៃគោលនយោបាយទាំងនោះ។ កំណត់ហេតុស្តាប់ចម្លើយទាំងនោះ បានធ្វើឲ្យភ័ស្តុតាងដទៃទៀតនៅក្នុងសំណុំរឿងមានភាពស៊ីសង្វាក់គ្នាទៅវិញទៅមក (ដូចជា កំណត់ហេតុដែលជាសក្ខីកម្មរបស់សាក្សី និងអ្នកជំនាញដែលនៅរស់, ឯកសារនានានៅក្នុងសហសម័យរបស់ បកក និងកំណត់ហេតុស្តាប់ចម្លើយនានារបស់ជនជាប់ចោទ) និងជួយក្នុងការបង្ហាញការពិត។ ជាងនេះទៅទៀត កំណត់ហេតុចស្តាប់ម្លើយទាំងនេះនឹងជួយដល់ សហព្រះរាជអាជ្ញា ក្នុងការបំពេញឲ្យបានគ្រប់គ្រាន់ការបង្ហាញភ័ស្តុតាងដាក់បន្ទុករបស់ខ្លួន ដែលទាក់ទងទៅនឹងលក្ខខណ្ឌតម្រូវក្នុងពេលចាប់ផ្តើមដំបូងនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ជាកត្តាមួយដែលអង្គជំនុំជម្រះបានចាត់ទុកថា ជាការបន្ធូរបន្ថយដែលគាំទ្រដល់ការទទួលយក ហើយដែលជាការប្រើប្រាស់មួយដែលកាលពីមុន នួន ជា ធ្លាប់បានទទួលយល់ព្រម[74]។

៣៦. ដូចដែលសហព្រះរាជអាជ្ញា បានពន្យល់នៅក្នុងការដាក់សេចក្តីសន្និដ្ឋានរបស់ខ្លួនដែលអមដោយឧបសម្ព័ន្ធទី១២ និង១៣ ដែលបានពិនិត្យឡើងវិញរួច កំណត់ហេតុស្តាប់ចម្លើយនានាដែលបានដាក់សម្រាប់

---

ការជំនុំជម្រះនេះដែលទាក់ទងទៅនឹងរបប តាមពិតទៅ. <u>យើងគឺមានបន្ទុកក្នុងការបង្ហាញភស្តុតាង អំពីឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដែលថាមានការវាយប្រហារដោយទូលំទូលាយនិងជាប្រព័ន្ធដែលបទល្មើសទាំងអស់នេះបានប្រព្រឹត្តឡើង</u>។ ធាតុទាំងអស់នេះហើយដែលយើងបង្ហាញឲ្យឃើញនៅក្នុងកថាខណ្ឌ១៣៥២ដីកាបញ្ជូនរឿងទៅជំនុំជម្រះលើកឡើងថាការវាយប្រហារដោយប្រព័ន្ធ និងដោយទូទៅធ្វើឡើងដោយ--ចំពោះប្រជាជនកម្ពុជា។ ការលើកឡើងរបស់មេធាវី អៀង សារី គឺខ្ញុំសូមបញ្ជាក់ថា<u>យើងមិនអាចដកចេញនូវសហកម្មឧក្រិដ្ឋកម្មរួមនោះទេ។ ដែលថាឧក្រិដ្ឋកម្មនេះធ្វើឡើងគោលដៅចំពោះ</u> ប្រជាជនកម្ពុជា ហើយដែលបានធ្វើឡើងនិងប្រព្រឹត្តឡើងនៅក្នុងរយៈកាលដែលមានចែងនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ។

[73] ឯកសារលេខ **D427** ដីកាដំណោះស្រាយ, ចុះថ្ងៃទី១៥កញ្ញា ២០១០, ត្រង់កថាខណ្ឌទី ១៣៥០ ១៣៦១។

[74] សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌទី២៤(ខ)។ អញ្ញត្រកម្មបឋមរបស់ នួន ជា, កថាខណ្ឌទី៣៨។

ទីតាំងទាំងនេះ គឺគ្រាន់តែជាគំរូតំណាងមួយនៃកំណត់ហេតុស្តាប់ចម្លើយសាក្សីដែលជាភ័ស្តុតាងដែលមានសម្រាប់ទីតាំងនីមួយៗ[75]។ ក្រុមមេធាវីការពារក្តី បានទទួលសិទ្ធិអាចចូលទៅពិនិត្យមើលកំណត់ហេតុស្តាប់ចម្លើយទាំងនេះភាគច្រើនបាន ចាប់តាំងពីពេលដែលកំណត់ហេតុស្តាប់ចម្លើយទាំងនេះត្រូវបានដាក់បញ្ចូលនៅក្នុងសំណុំរឿងតាំងពីយូរ ដែលមានរយៈពេលលើសពីបីឆ្នាំ[76] ។ នៅក្នុងកាលៈទេសៈទាំងនេះ ការដែលអង្គជំនុំជម្រះសាលាដំបូងទទួលយកនូវកំណត់ហេតុស្តាប់ចម្លើយទាំងនេះ គឺមិនមែនជាតំណាងឲ្យបន្ទុកដែលមិនសមហេតុសមផលមួយទៅលើមេធាវីការពារក្តី ឬជនជាប់ចោទនោះឡើយ។

### ៥. សេចក្តីជំទាស់ជាទូទៅចំពោះលក្ខណៈមិនត្រួតកម្លាំងគ្នានៃភ័ស្តុតាង

៣៧. មេធាវីការពារក្តី នួន ជា អះអាងថា ប្រភេទកំណត់មួយចំនួនដែលទាក់ទងទៅនឹងទីតាំងឧក្រិដ្ឋកម្មនៃសំណុំរឿង 00២ មិនអាចទទួលយកបានទេ ដោយសារវាមិនបន្ថែមកម្លាំងទៅលើភ័ស្តុតាងជាសក្ខីកម្មដែលអង្គជំនុំជម្រះបានស្តាប់សវនាការរួចហើយនៅក្នុងការជំនុំជម្រះនេះ។ ជាការសង្កេតបឋម សហព្រះរាជអាជ្ញាសន្និដ្ឋានថា ចរិកលក្ខណៈនៃការបន្ថែមកម្លាំងនៃកំណត់ហេតុសាក្សី គួរបានវាយតម្លៃដោយប្រៀបធៀបទាំងភ័ស្តុតាងសក្ខីកម្ម និងភ័ស្តុតាងឯកសារនៅចំពោះមុខអង្គជំនុំជម្រះ[77]។ អនុវាក្យខណ្ឌខាងក្រោមនេះ បង្ហាញឲ្យឃើញពីកំណត់ហេតុដែលបានផ្តល់ជូនបំពេញទៅតាមលក្ខខណ្ឌតម្រូវនេះ។

---

75 ឯកសារលេខE278 សេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញាលើអំពីឧបសម្ព័ន្ធទី១២ និង១៣ ដែលបានពិនិត្យកែសម្រួលឡើងវិញ ក្នុងបញ្ជីឯកសារសម្រាប់សវនាការរបស់ខ្លួន អនុលោតាមវិធាន៨0(៣)ចុះថ្ងៃទី៩ មេសា ២០១៣, កថាខណ្ឌទី២៧(ខ), ២៨ និង ២៩។

76 ការលើកលែងតែមួយគត់ចំពោះករណីនេះ គឺកំណត់ហេតុស្តាប់ចម្លើយសាក្សីចំនួន១៧ដែលបានដាក់នៅក្នុងសំណុំរឿងនៅក្នុងពេលជំនុំជម្រះ, ដែលក្នុងនោះមានកំណត់ហេតុពីរត្រូវបានអង្គជំនុំជម្រះទទួលយករួចហើយនៅក្នុងបរិបទជាសក្ខីកម្មផ្ទាល់របស់សាក្សីរស់, ហើយកំណត់ហេតុចំនួន១៥ នៃកំណត់ហេតុទាំងនេះត្រូវបានស្រង់ដោយសហចៅក្រមស៊ើបអង្កេតនៅក្នុងសំណុំរឿងលេខ00៣ និង00៤។ សូមអានឯកសារលេខ E278 សេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញាអំពីឧបសម្ព័ន្ធទី១២ និង១៣ ដែលបានពិនិត្យកែសំរួលឡើងវិញ ក្នុងបញ្ជីឯកសារសំរាប់សវនាការរបស់ខ្លួន អនុលោតាមវិធាន៨0(៣), ចុះថ្ងៃទី៩ មេសា ២០១៣, កថាខណ្ឌទី២៧។

77 វិធាន៨២ស្ទួន(ក)(i) ចែងថា លក្ខណវិនិច្ឆ័យដែលបានកំណត់នៅក្នុងបទប្បញ្ញត្តិនោះ មិនរៀបរាប់អស់ទេ។

៣៨. ***ការប្រព្រឹត្តិចំពោះពុទ្ធសាសនិកជន*** - អង្គជំនុំជម្រះបានស្តាប់ភ័ស្តុតាងសក្ខីកម្មយ៉ាងច្រើនសន្ធឹកសន្ធាប់ទាក់ទងនឹងការធ្វើទុក្ខបុកម្នេញពុទ្ធសាសនិកជន។ ភ័ស្តុតាងនេះបញ្ជាក់អះអាងពីការហាមឃាត់របស់ បកក ចំពោះសាសនាព្រះពុទ្ធ[78] និងរួមទាំងសេចក្តីរៀបរាប់អំពីចាប់ផ្សឹកដោយបង្ខំ[79] និងការសម្លាប់ព្រះសង្ឃ[80]។ សាក្សីក៏បានរៀបរាប់ផងដែរអំពីការបំផ្លិចបំផ្លាញវត្តអារាម[81] និងការប្រែក្លាយទៅជាទីកន្លែងមិនមែនសម្រាប់គោលបំណងសាសនា ដូចជាចង្រុក[82] ទ្រុងជ្រូក[83] និងកន្លែងឃុំឃាំងមនុស្ស[84] ឬកន្លែងប្រជុំ[85]។ សាក្សីបានផ្តល់សក្ខីកម្មថា អវត្តមាននៃព្រះសង្ឃ និងការប្រើប្រាស់សម្រាប់វិស័យសាសនានៃវត្តអារាម មានន័យថា ជាចុងបញ្ចប់នៃព្រះពុទ្ធសាសនានៅក្នុងប្រទេសកម្ពុជា[86]។ អត្ថិភាពនៃគោលនយោបាយរបស់ បកក នៅក្នុងការគៀបសង្កត់ទៅលើសាសនាព្រះពុទ្ធ ត្រូវបានបញ្ជាក់អះអាងដោយសាក្សីជំនាញសាស្ត្រាចារ្យ David Chandler[87]។

៣៩. សក្ខីកម្មទាំងនេះស៊ីសង្វាក់គ្នានឹងភ័ស្តុតាងឯកសារនៅចំពោះមុខអង្គជំនុំជម្រះរួមទាំង៖ សារាចរណ៍ការបោះពុម្ពផ្សាយ និងសេចក្តីថ្លែងការណ៍នានារបស់មេដឹកនាំ បកក ដែលពិភាក្សាអំពីការបោះបង់ចោលព្រះពុទ្ធសាសនា ការកំណត់អត្តសញ្ញាណអតីតព្រះសង្ឃ ជាផ្នែកនៃ "អនុធន" ដែលទំនងបំផុតនឹងក្លាយជាខ្មាំងរបស់ បកក និងការបញ្ជាក់ថា ព្រះពុទ្ធសាសនាមានវិសមិត្តភាពជាមួយនឹង

---

[78] **E1/88.1** ប្រតិចារឹក, យុន គីម (YUN Kim), ១៩ មិថុនា ២០១២, ត្រង់ ERN 00819664; **E1/90.1** ប្រតិចារឹក, ខៀវ នៅ (KHIEV Neou), ២១ មិថុនា ២០១២, ត្រង់ ERN 00820798-9; **E1/90.1**។

[79] **E1/89.1** ប្រតិចារឹក, យុន គីម (YUN Kim), ២០ មិថុនា ២០១២, ត្រង់ ERN 00820191; **E1/90.1** ប្រតិចារឹក, ខៀវ នៅ (KHIEV Neou), ២១ មិថុនា ២០១២, ត្រង់ ERN 00820796; **E1/182.1** ប្រតិចារឹក, ឈូក រិន (CHHOUK Rin), ២៣ មេសា ២០១៣, ត្រង់ ERN 00904589-90; **E1/185.1** ប្រតិចារឹក, ស សារិន (SAR Sarin), ២៩ មេសា ២០១៣, ត្រង់ ERN 00906500; សូមមើលផងដែរ **E1/115.1**, ប្រតិចារឹក, អែម អឿន (EM Oeun), ២៧ សីហា ២០១២, ត្រង់ ERN 00842899។

[80] **E1/51.1** ប្រតិចារឹក, កាំង ហ្គេកអ៊ាវ ហៅ ឌុច, ២០ មីនា ២០១២ ត្រង់ ERN 00793000, 00793004-5។

[81] **E1/113.1**, ប្រតិចារឹក, អែម អឿន (EM Oeun), ២៣ សីហា ២០១២, ត្រង់ ERN 00841924។

[82] **E1/88.1** ប្រតិចារឹក, យុន គីម (YUN Kim), ១៩ មិថុនា ២០១២, ត្រង់ ERN 00819666។

[83] **E1/105.1** ប្រតិចារឹក, អ៊ុង ថុងហឿង (ONG Thong Hoeung), ៩ សីហា ២០១២, ត្រង់ ERN 00835358។

[84] **E1/185.1** ប្រតិចារឹក, ស សារិន (SAR Sarin), ២៩ មេសា ២០១៣, ត្រង់ ERN 00906500។

[85] **E1/88.1** ប្រតិចារឹក, យុន គីម (YUN Kim), ១៩ មិថុនា ២០១២, ត្រង់ ERN 00819666; **E1/148.1** ប្រតិចារឹក, ពេជ ស្រីផល, ៥ ធ្នូ ២០១២ ត្រង់ ERN 00868144; **E1/152.1** ប្រតិចារឹក, ១២ ធ្នូ ២០១២, Denise Affonço, ត្រង់ ERN 00871237, 00871241, 00871244, 00871264-5។

[86] **E1/88.1** ប្រតិចារឹក, យុន គីម (YUN Kim), ១៩ មិថុនា ២០១២, ត្រង់ ERN 00819665-6; **E1/90.1** ប្រតិចារឹក, ខៀវ នៅ (KHIEV Neou), ២១ មិថុនា ២០១២, ត្រង់ ERN 00820798-9។

[87] **E1/93.**1, ប្រតិចារឹក, David Chandler, ២០ មិថុនា ២០១២, ត្រង់ ERN 00827310, 00827418-9។

បដិវត្តន៍[88]។ ភ័ស្តុតាងនេះ ត្រូវបានធ្វើបមាណីកម្មបន្ថែមទៀតដោយអ្នកសិក្សាស្រាវជ្រាវជាន់ខ្ពស់ដែលរៀបរាប់អំពីសេចក្តីសម្រេចរបស់មេដឹកនាំ បកក ក្នុងការផ្សឹកព្រះសង្ឃទាំងអស់ និងអំពីនៃការធ្វើបាបរបស់ពួកគេ[89]។

៤០. ***ប្រព្រឹត្តកម្មលើពួកចាម*** - ភ័ស្តុតាងដែលមាននៅក្នុងកំណត់ហេតុស្តាប់ចម្លើយសាក្សីដែលបានផ្តល់ដោយសហព្រះរាជអាជ្ញា ក៏បានបញ្ជាក់បន្ថែមទៅលើសក្ខីកម្មនានាដែលរៀបរាប់អំពីគោល នយោបាយរបស់ បកក ស្តីពីការកំណត់ទុកជាមុនថាប្រជាជនចាមគឺជា "ពួកខ្មាំង" នៃរបប[90]។ សាក្សីជំនាញ លោកសាស្ត្រាចារ្យ David Chandler បានផ្តល់សក្ខីកម្មថា គោលនយោបាយនេះត្រូវបានចាត់ទុកថាជាការចាំបាច់សម្រាប់ "autonomous systematic communities" ដែលបានគំរាមកំហែងទៅលើទស្សនៈវិស័យរបស់ បកក ទៅលើប្រទេសកម្ពុជា[91]។ នៅក្នុងមតិរបស់អ្នកជំនាញនេះ ពួកចាមគឺត្រូវបាន "ត្រូវបានសម្លាប់ដោយមិនចាំបាច់សួរ"[92]។ សាក្សីនានាក៏បាន រៀបរាប់ផងដែរអំពីការធ្វើបាបទៅលើពួកចាម រួមទាំង កាលៈទេសៈនានាដែលពួកចាមត្រូវបាន បង្ខំឱ្យផ្លាស់ប្តូរទៅលំនៅ[93] និងបង្ខំឱ្យលះបង់សាសនារបស់ពួកគេចោល[94] ឱ្យទទួលទានសាច់ ជ្រូក[95] និងឱ្យ

---

[88] **E3/99** ការបោះពុម្ពផ្សាយរបស់ បកក ដែលមានចំណងជើងថា "ការតាមដានការអនុវត្តខ្សែនយោបាយ ក្នុងការប្រមូលកម្លាំងរណសិរ្សជាតិប្រជាធិបតេយ្យរបស់បក្ស ("Follow-up of implementation of the political line in mobilizing the National Democratic Front Forces of the Party) (ឯកសារលេខ ៦)", ២២ កញ្ញា ១៩៧៥ ត្រង់ ERN 00244275; **E3/135** *ទង់បដិវត្តន៍*, ច្បាប់ចេញផ្សាយ ៦, មិថុនា ១៩៧៧ ត្រង់ ERN 00142907; **E3/2306** Slavko Stanic, របាយការណ៍សារព័ត៌មានអន្តរជាតិដែលមានចំណងជើងថា "ចំណាប់អារម្មណ៍របស់អ្នកសារព័ត៌មាន Yugoslav ក្នុងពេលបំពេញទស្សនកិច្ច" (Tanjug in Serbo-Croat), ២៩ មេសា ១៩៧៨ ត្រង់ ERN 00010086។

[89] **E3/1593** Ben Kiernan, *របប ប៉ុល ពត*, ១៩៩៦ ត្រង់ ERN 00678522; **E3/2818** Ian Harris, *ព្រះពុទ្ធសាសនាក្នុងរបប ប៉ុល ពត*, ២០ មករា ២០០៨, ជាពិសេស ជាឧទាហរណ៍ ត្រង់ ERN 00703985-90, ការផ្សឹកព្រះសង្ឃ, ERN 00703990-2, ការរៀបការដោយបង្ខំរបស់ព្រះសង្ឃ, និង ERN 00703994, ការសម្លាប់ព្រះសង្ឃ។ សូមមើលផងដែរ ERN 00704021-5 សម្រាប់ការប្រើវត្តអារាមមិនមែនក្នុងគោលបំណងសាសនា។

[90] សេចក្តីជំទាស់ទាំងនេះរបស់ ខៀវ សំផន មាននៅក្នុងឧបសម្ព័ន្ធដូតទៅ គឺ៖ ក) ឧបសម្ព័ន្ធ **E208/5.2** - សេចក្តីជំទាស់ទៅនឹងកំណត់ហេតុស្តាប់ចម្លើយ នៅក្នុងឧបសម្ព័ន្ធ ១ (ឯកសារ E208.1) ពាក់ព័ន្ធនឹងការជម្លៀសប្រជាជនដោយបង្ខំ ដំណាក់កាលទី១។

[91] **E208/5**, សេចក្តីជំទាស់របស់លោក ខៀវ សំផន, កថាខណ្ឌ ៣៥ - ទាក់ទងទៅនឹងឧបសម្ព័ន្ធ ៨, ១០-១១ និង ១៣-១៦ នៃ E96/8។

[92] **E208/5**, សេចក្តីជំទាស់របស់លោក ខៀវ សំផន, កថាខណ្ឌ ២៣ - ទាក់ទងទៅនឹងឧបសម្ព័ន្ធ ៣ នៃ E96/8។

[93] **E208/5**, សេចក្តីជំទាស់របស់លោក ខៀវ សំផន, កថាខណ្ឌ ២៤-២៦ - ទាក់ទងទៅនឹងឧបសម្ព័ន្ធ ៤ ដល់ ៧ នៃ E96/8។

[94] **E208/5**, សេចក្តីជំទាស់របស់លោក ខៀវ សំផន, ២៦ មេសា ២០១៣, កថាខណ្ឌ ៩, ១០ និង ១២។

[95] **E1/45.1**, ប្រតិចារិករបស់អង្គជំនុំជម្រះសាលាដំបូង, ១៦ កុម្ភៈ ២០១២ (ភាពអាចទទួលយកបាននៃឯកសារដែលបានលើកយោងក្នុងកំណត់សំគាល់ជើងទំព័រនៃដីកាដំណោះស្រាយ ទាក់ទងនឹងរចនាសម្ព័ន្ធ និងការប្រាស្រ័យទំនាក់ទំនង)។

ធ្វើពលកម្ម[96]។ ទូរលេខរបស់ បកក បញ្ជាក់ថា ពួកចាមត្រូវបានគេចាត់ទុកថាជា ខ្មាំងនៃរបប[97] និងត្រូវបានបង្ខំឱ្យផ្លាស់ទីលំនៅទៅកាន់ភូមិភាគឧត្តរ[98]។ របាយការណ៍មួយរបស់ បកក នៅខែឧសភា ឆ្នាំ១៩៧៧ បញ្ជាក់ថាគេបានយក "វិធានការពិសេស" ដើម្បីធ្វើការកំណត់ អត្តសញ្ញាណពួកចាម "ដើម្បីបោសសម្អាត" ចលនារបស់ពួកគេ[99]។ ការស្រាវជ្រាវរបស់អ្នកមានវិជ្ជាជ្រៅជ្រះ ក៏បានអះអាង អំពីភ័ស្តុតាងស្តីពីការសម្លាប់ពួកចាមដោយ បានគិតទុកជាមុននេះ ផងដែរ[100]។

៤១. ***ប្រព្រឹត្តកម្មលើពួកវៀតណាម*** - កំណត់ហេតុនានាដែលសាក្សីបានផ្តល់ឱ្យ ក៏ជាការត្រួតភ័ស្តុតាង ថែមលើសក្ខីកម្ម ស្តីពីការកំណត់គោលដៅជាប្រព័ន្ធរបស់ កកក ទៅលើពួកវៀតណាម។ លោក សាស្ត្រាចារ្យ David Chandler បានផ្តល់សក្ខីកម្មថា បកក បានបង្កើតគោលនយោបាយមួយស្តីពី ការកំចាត់ពួកវៀតណាមទាំងអស់ចោល[101]។ សាក្សីអង្គហេតុនានាធ្លាប់បានបញ្ជាក់ពីការបិទស្លាក ពួកវៀតណាមថាជា "យួន"[102] ហើយបានផ្តល់សក្ខីកម្មថា សេចក្តីសម្រេចក្នុងការចាប់ខ្លួន ជនជាតិ វៀតណាម គឺចេញមកពីមជ្ឈិមបក្ស[103]។ គោលនយោបាយរបស់ បកក ស្តីពីការកំណត់ គោលដៅ

---

[96] **E1/46.1**, ប្រតិចារឹករបស់អង្គជំនុំជម្រះសាលាដំបូង, ១២ មីនា ២០១២, **E1/47.1**, ប្រតិចារឹករបស់អង្គជំនុំជម្រះសាលាដំបូង, ១៤ មីនា ២០១២ និង **E1/49.1** ប្រតិចារឹករបស់អង្គជំនុំជម្រះសាលាដំបូង, ១៥ មីនា ២០១២ (ភាពអាចទទួលយកបាននៃឯកសាររបស់ កសព ក្នុង ឯកសារលេខ A6-A11 និង A14-A20 តាមឯកសារលេខ E109/4 និងឯកសាររបស់ភាគីផ្សេងៗដទៃទៀត)។

[97] **E1/46.1**, ប្រតិចារឹករបស់អង្គជំនុំជម្រះសាលាដំបូង, ១២ មីនា ២០១២, **E1/47.1**, ប្រតិចារឹករបស់អង្គជំនុំជម្រះសាលាដំបូង, ១៤ មីនា ២០១២ និង **E1/49.1** ប្រតិចារឹករបស់អង្គជំនុំជម្រះសាលាដំបូង, ១៥ មីនា ២០១២ (ភាពអាចទទួលយកបាននៃឯកសាររបស់ កសព ក្នុង ឯកសារលេខ A6-A11 និង A14-A20 តាមឯកសារលេខ E109/4 និងឯកសាររបស់ភាគីផ្សេងៗដទៃទៀត)។

[98] *See* **E114/1**, ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹង "ការជំទាស់របស់ អៀង សារី ទៅនឹងភាពអាចទទួលយកបាន នូវប្រភេទ ឯកសារមួយចំនួន", ១៦ កញ្ញា ២០១១។ **E131/19,** ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញាទៅនឹងការជំទាស់នឹងបញ្ជីឯកសារសម្រាប់សវនាការ វគ្គដំបូង, ២ ធ្នូ ២០១១។ **E158**, សេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា ស្របតាមវិធាន ៩២ ទាក់ទិននឹងស្ទូចនាករអំពីការជឿទុកចិត្ត ចំពោះឯកសារចំនួន៩៧៨ ដែលជាប់ពាក់ព័ន្ធនឹងសាក្សី និងអ្នកជំនាញដែលអាចកោះហៅសម្រាប់សវនាការបឋមដំបូង, ២៣ ធ្នូ ២០១១។

[99] **E1/161.1**, ប្រតិចារឹករបស់អង្គជំនុំជម្រះសាលាដំបូង, ២១ មករា ២០១៣, ត្រង់ 11:17 to 11:45 និង 14:00 to 14:18។ **E3/2653, D196.2**, Book by YSA Osman entitled "The Cham Rebellion: Survivors' Stories from the Villages", 2006.

[100] **E1/162.1**, ប្រតិចារឹករបស់អង្គជំនុំជម្រះសាលាដំបូង, ២២ មករា ២០១៣, ត្រង់ 13:43 និងពី 13:51 – 14:09។ **E185/1**, Trial Chamber Decision on Objections to Documents Proposed to Be Put Before the Chamber in Co-Prosecutors' Annexes A6-A11 and A14-A20 and by the Other Parties, 3 December 2012; **E185/1.3**, Annex C: Documents Proposed by the Co-Prosecutors, at ENG ERN 00884514

[101] **E1/34.1**, ប្រតិចារឹករបស់អង្គជំនុំជម្រះសាលាដំបូង, ២៦ មករា ២០១២, ត្រង់ 15:05-15:15។ **E96/7**, Trial Chamber Decision on Co-Prosecutors' Rule 92 Submission Regarding the Admission of Witness Statements and Other Documents Before the Trial Chamber, 20 June 2012, end of para 32.

[102] **E1/34.1**, ប្រតិចារឹករបស់អង្គជំនុំជម្រះសាលាដំបូង, ២៦ មករា ២០១២, ត្រង់ 15:05-15:15។ Unofficial translation from French; objection to D230/2/3.1.643a, b (see Annex 208/5.4, at ERN 00898610).

[103] **E223/2/2.1**: ឯកសារដែលមានលេខ២-១៤ និង១៦; **E223/2/2.5**: ឯកសារ១-៣, ១៤, ១៨, ២០ និង៣៧។ Unofficial translation from French. Annex **E208/5.4**, objection to D230/2/3.1.643a, b, at ERN 00898610.

ទៅលើជនជាតិវៀតណាម ក៏ត្រូវបានបង្ហាញភ័ស្តុតាងដោយសារាចរណែនាំនានារបស់ បកក ផងដែរ ដែលបាននិយាយថាមានការចាំបាច់ដើម្បី "សម្អាត" ជនជាតិវៀតណាមដើម្បី "ដើម្បីធ្វើឱ្យសង្គមស្អាតស្អំ"[104] ហើយនិងរបាយការណ៍នានាស្តីពីការសម្លាប់រង្គាលទៅ លើពួកប្រជាជនស៊ីវិលវៀតណាម[105]។ បញ្ជីឈ្មោះអ្នកទោសនៅស-២១ ដែលបានកែសម្រួល ឡើងវិញ បញ្ជាក់ថាមានពួកវៀតណាមរាប់រយនាក់ត្រូវបានចាប់ខ្លួន និងសម្លាប់ចោលនៅតាមមន្ទីរ សន្តិសុខ[106]។ របាយការណ៍សហកាលតាមសារព័ត៌មាននានា បានរៀបរាប់អំពីអំពើឧក្រិដ្ឋនានា ដែលពួកកងកម្លាំងនៃកម្ពុជាប្រជាធិបតេយ្យបានប្រព្រឹត្ត នៅក្នុងអំឡុងពេលនៃការលុកលុយចូល ទៅក្នុងប្រទេសវៀតណាម[107]។

៤២. ***អាពាហ៍ពិពាហ៍ដោយបង្ខំ*** - កំណត់ហេតុនានាដែលសាក្សីបានផ្តល់ឱ្យ ក៏ជាការត្រួតភ័ស្តុតាងថែមលើសក្ខីកម្ម ដែលបានស្តាប់នៅពេលសវនាការលើភ័ស្តុតាងរបស់ប្រជាជនដែលត្រូវបានគេ បង្ខំឱ្យរៀបអាពាហ៍ពិពាហ៍ជាមួយនឹងបុគ្គលដែលខ្លួនមិនបានស្រឡាញ់ ឬទើបតែនឹងបានជួប មួយភ្លែត[108]។ សាក្សីជំនាញ លោក Philip Short ក៏បានរៀបរាប់ផងដែរអំពីការដែលបក្សមិន អនុញ្ញាតឱ្យមាន "romantic attachments" រវាងគូស្វាមីភរិយា ហើយនិងគោលនយោបាយស្តីពី ការរៀបអាពាហ៍ពិពាហ៍របស់ពួកយោធាខ្មែរក្រហមជាមួយនឹងនារីក្មេងៗដើម្បីបង្កើនប្រជាជន[109]។ លើសពីនេះ អង្គជំនុំ

---

[104] ឧបសម្ព័ន្ធ **E208/5.5**, ការជំទាស់ទៅនឹងកំណត់ហេតុ D25/29, ត្រង់ ERN 00898611-12។ កំណត់ហេតុនេះគួរអាចរួមគ្នាជាមួយនឹងកំណត់ហេតុ D125/123។

[105] ការបកប្រែក្រៅផ្លូវការពីភាសាដើមបារាំង។

[106] ក្នុងឧបសម្ព័ន្ធ **E208/5.2**: ការជំទាស់នឹងកំណត់ហេតុ D232/40, ត្រង់ ERN 00898437; D125/93, ត្រង់ ERN 00898439; D40/8, ត្រង់ ERN 00898441; D232/89, ត្រង់ ERN 00898443; D277/2, ត្រង់ ERN 00898448; D166/110, ត្រង់ ERN 00898450; D246/7, ត្រង់ ERN 00898471; D232/70, ត្រង់ ERN 00898477; D125/177, ត្រង់ ERN 00898484; D232/64, ត្រង់ ERN 00898517; D296/2, ត្រង់ ERN 0089851; ក្នុងឧបសម្ព័ន្ធ **E208/5.3:** D232/79, ត្រង់ ERN 00898526-29; D232/74, ត្រង់ ERN 00898547; ក្នុងឧបសម្ព័ន្ធ **E208/5.6**: លឿង ប៊ុន្នី D246/11, ត្រង់ ERN 00898656; ទូន លន D232/19, ត្រង់ ERN 00898676។

[107] ក្នុង **E208/5.2**: D232/54, ត្រង់ ERN 00898446; D166/125, ត្រង់ ERN 00898456; D166/117, ត្រង់ ERN 00898458; D166/73, E3/509, ត្រង់ ERN 00898459; D232/48, ត្រង់ ERN 00898487: D232/12, ត្រង់ ERN 00898512; ក្នុងឧបសម្ព័ន្ធ **E208/5.3**: D125/104, ត្រង់ ERN 00898538; ក្នុងឧបសម្ព័ន្ធ **E208/5.6**: D234/9 និង E3/428, ត្រង់ ERN 00898673។

[108] D234/9, E3/428, ក្នុងឧបសម្ព័ន្ធ **E208/5.6** ត្រង់ ERN 00898673។

[109] ជាឧទាហរណ៍ ក្នុងឧបសម្ព័ន្ធ **E208/5.2**: D166/35, ត្រង់ ERN 00898426, D125/171, ត្រង់ ERN 00898427-28; D125/71, ត្រង់ ERN 00898431; D166/123, ត្រង់ ERN 00898432; D166/41, ត្រង់ ERN 00898443; D296/9, ត្រង់ ERN 00898444; D232/44, ត្រង់ ERN 00898449; D277/3, ត្រង់ ERN 00898451; D125/86, ត្រង់ ERN 00898456; D125/68, ត្រង់ ERN 00898468; D125/92, ត្រង់ ERN 00898476; D40/15, ត្រង់ ERN 00898481; D232/42, ត្រង់ ERN 00898488; D125/91, ត្រង់ ERN 00898494; D246/16, ត្រង់ ERN 00898498; D166/82, ត្រង់ ERN 00898515; ក្នុងឧបសម្ព័ន្ធ **E208/5.3**: D125/154,

ជម្រះធ្លាប់បានស្តាប់ភស្តុតាងជាសក្ខីកម្មពាក់ព័ន្ធនឹងការអនុញ្ញាតឲ្យមានការ រៀបអាពាហ៍ពិពាហ៍ដោយបង្ខំពីសំណាក់រដ្ឋអំណាច បកក[110] ហើយនិងការដាក់ទណ្ឌកម្មយ៉ាង ធ្ងន់ធ្ងរចំពោះពួកដែលបានប្រកែក[111]។ ភស្តុតាងនេះគឺត្រូវបានបញ្ជាក់បន្ថែមដោយសារាចរណែនាំ របស់ បកក ដែលបង្ហាញថារដ្ឋអំណាចក្នុងការធ្វើសេចក្តីសម្រេចពាក់ព័ន្ធនឹងបញ្ហាស្តីពីការកសាង គ្រួសារ គឺស្ថិតនៅលើបក្ស[112]។ ភស្តុតាងជាទម្រង់នៃការស្រាវជ្រាវរបស់អ្នកមានវិជ្ជាជ្រៅជ្រះ បាន បញ្ជាក់ថា អាពាហ៍ពិពាហ៍ដោយបង្ខំមានគោលបំណងដើម្បីបង្កើនប្រជាជន[113] ដែលជាញឹកញាប់ អាពាហ៍ពិពាហ៍ត្រូវបានធ្វើឡើងរវាងបុគ្គលដែលមិនធ្លាប់បានជួបគ្នាទាល់តែសោះ[114] ហើយអ្នក ដែលជំទាស់ត្រូវបានគេគំរាមថា ឬត្រូវបានធ្វើទណ្ឌកម្ម ចាប់រំលោភសេពសន្ថវៈ ឬសម្លាប់ចោល យ៉ាងជាក់ស្តែង[115]។

៤៣. ***ការដ្ឋាន និង មន្ទីរសន្តិសុខ*** - មេធាវីការពារក្តី នួន ជា បានអះអាងថា ដោយមកពីមានភាពផ្សេងពីគ្នារវាងការដ្ឋាន សហករណ៍ និង មន្ទីរសន្តិសុខនានា នោះអង្គជំនុំជម្រះត្រូវបដិសេធចោលនូវការសន្មតដំបូង ដែលថាកំណត់ហេតុដែលសាក្សីបានផ្តល់ឲ្យ បានបញ្ជាក់ បន្ថែមទៅលើសក្ខីកម្មនានាដែលបានស្តាប់រហូតមកដល់ពេលនេះ[116]។ ការដាក់ស្នើជូននេះមិនបាន អើពើដល់ចរិកលក្ខណៈពិតប្រាកដនៃរឿងក្តីនេះ ព្រមទាំងភស្តុតាងនៅចំពោះមុខអង្គជំនុំជម្រះ នេះទេ។ បញ្ហាមួយក្នុងចំណោម

---

ត្រង់ ERN 00898533; ក្នុងឧបសម្ព័ន្ធ **E208/5.6**: D166/100, ត្រង់ ERN 00898650; D25/28, ត្រង់ ERN 00898652; D125/170, ត្រង់ ERN 00898655។

[110] ជាឧទាហរណ៍ ដើមបណ្តឹងរដ្ឋប្បវេណី សាក្សី និងអ្នកជំនាញខាងក្រោម បានពិភាក្សាពីធាតុផ្សំនៃចេតនារើសអើងប្រឆាំងនឹងប្រជាជន ១៧ មេសា និង/ឬ អតីតមន្ត្រីនៃសាធារណរដ្ឋខ្មែរ៖ Denise Affonço, ជុំ សុខា, ឡាយ បូនី, ពេជ ស្រីផល, François Ponchaud, Philip Short, ខឹម ងន, សុខ ឈិន, អ៊ុង ឆាត់ និង ស៊ុំ ជា។

[111] សូមមើល ជាឧទាហរណ៍ ក្នុងឧបសម្ព័ន្ធ **E208/5.6**: D125/170, ត្រង់ ERN 00898655 ដែលមេធាវីការពារក្តីដាក់បញ្ចូលទៅក្នុងចំណែកនៃសម្រង់ដែលពាក់ព័ន្ធ ទាក់ទងនឹងការជម្លៀសនិងហេតុផលដែលផ្តល់ជូនប្រជាជនជាយុត្តិកម្មចំពោះការជម្លៀស។ ក្នុងចំណោមបញ្ហាផ្សេងទៀត ចំណុចដូចគ្នានេះក៏អនុវត្តចំពោះសម្រង់ពីកំណត់ហេតុ D166/100 (**E208/5.6**, ត្រង់ ERN 00898650), និងចំពោះកំណត់ហេតុ D125/71, (**E208/5.2** ត្រង់ ERN 00898431) ផងដែរ។

[112] **E96/7** សេចក្តីសម្រេចស្តីពីភាពអាចទទួលយកបាននៃកំណត់ហេតុស្តាប់ចម្លើយសាក្សី, ត្រង់កថាខណ្ឌទី២៥។

[113] ជាឧទាហរណ៍ សូមមើលឧបសម្ព័ន្ធ **E208/5.2**, ការជំទាស់ទៅនឹងកំណត់ហេតុ D125/174, ត្រង់ ERN 00898428-30។

[114] ជាឧទាហរណ៍ សូមមើលឧបសម្ព័ន្ធ **E208/5.3**: ការជំទាស់ទៅនឹងកំណត់ហេតុ D125/169, ត្រង់ ERN 00898524, D166/181, ត្រង់ ERN 00898529; និង ឧបសម្ព័ន្ធ **E208/5.6**: ការជំទាស់ទៅនឹងកំណត់ហេតុ D246/14, ត្រង់ ERN 00898650។

[115] ឧបសម្ព័ន្ធ **E208/5.2**: ការជំទាស់ទៅនឹងកំណត់ហេតុ D166/42, ត្រង់ ERN 00898509; D166/79, ត្រង់ ERN 00898514; ឧបសម្ព័ន្ធ **E208/5.3**: ការជំទាស់ទៅនឹងកំណត់ហេតុ D125/102, ត្រង់ ERN 00898531 និង D125/129, ត្រង់ ERN 00898539។

[116] ឧបសម្ព័ន្ធ **E208/5.2**: ការជំទាស់ទៅនឹងកំណត់ហេតុ D40/3, ត្រង់ ERN 00898460, D232/77, ត្រង់ ERN 00898475 និង D277/10, ត្រង់ ERN 00898502 (ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ ត្រូវបានកំណត់ពេលមកផ្តល់សក្ខីកម្មអំពីការឈឺចាប់របស់គាត់)។

បញ្ហានានាដែលមាននៅក្នុងរឿងក្ដីនេះ គឺអត្ថិភាពនៃគោល នយោបាយរបស់ បកក ស្ដីពីការបង្ខាំងប្រជាជនរបស់ប្រទេសជាតិឲ្យនៅក្នុងតែការដ្ឋាន និង សហករណ៍ ហើយនិងការដាក់អ្នកទាំងនោះឲ្យស្ថិតនៅក្រោមពលកម្មដោយបង្ខំ និងការធ្វើបាប ដទៃទៀត[117]។ ស្រដៀងគ្នានេះដែរ រឿងក្ដីនេះពាក់ព័ន្ធនឹងគោលនយោបាយមួយស្ដីពីការអប់រំ ឡើងវិញដល់សមាសភាពមិនល្អ និងការកម្ទេចពួកខ្មាំងដែលត្រូវបានអនុវត្តនៅក្នុងមន្ទីរសន្តិសុខ នានានៅពាសពេញប្រទេសកម្ពុជា[118]។ អង្គជំនុំជម្រះធ្លាប់បានស្ដាប់ភ័ស្តុតាងជាសក្ខីកម្មស្ដីពីចរឹក លក្ខណៈនៃគោលនយោបាយទាំងនេះដែលត្រូវបានបង្កើតឡើងដើម្បីប្រមូលផ្ដុំអំណាច។

៤៤. លោកសាស្ត្រាចារ្យ David Chandler បានផ្ដល់សក្ខីកម្មថា ពលកម្មដោយបង្ខំត្រូវបានអនុវត្តនៅតាមសហករណ៍ និងតាមការដ្ឋាននានា នៅពាសពេញប្រទេសកម្ពុជា ទៅតាមគោលនយោបាយរួមមួយ[119]។ នួន ជា ខ្លួនឯង បានផ្ដល់សក្ខីកម្មថា មូលហេតុមួយក្នុងចំណោមមូលហេតុនានា សម្រាប់ធ្វើការជម្លៀសទីក្រុងភ្នំពេញ គឺដើម្បីរៀបចំប្រជាជនឲ្យទៅតាមសហករណ៍[120]។ សាក្សីជំនាញ លោក Philip Short បានដាក់ស្លាកឲ្យកម្ពុជាប្រជាធិបតេយ្យ ថាជា "រដ្ឋនៃទាសករ" ដែលនៅក្នុងនោះសហករណ៍ និងការដ្ឋាននីមួយៗ គឺជាផ្នែកនៃគោលនយោបាយមួយស្ដីពីការ ដកហូតនូវគ្រប់សិទ្ធិនិងសេរីភាពទាំងអស់របស់ប្រជាជន[121]។ ក្រោយមក គាត់បានផ្ដល់សក្ខីកម្ម ថា ទោះបីជាមានកម្រិតនៃការប្រែប្រួលក៏ដោយ ក៏គោលនយោបាយរបស់ បកក ដូចៗគ្នាត្រូវ បានអនុវត្តនៅគ្រប់ផ្នែកទាំងអស់នៃប្រទេសជាតិ[122]។ គាត់បានរៀបរាប់ថា ស-២១ និង ស្ថាប័ន ដែលរួមគ្នានានានៅតាមស្រុកទាំង

---

[117] ឧបសម្ព័ន្ធ **E208/5.2**: ការជំទាស់ទៅនឹងកំណត់ហេតុ D125/57, ត្រង់ ERN 00898482។

[118] ឧបសម្ព័ន្ធ **E208/5.6**: ការជំទាស់ទៅនឹងកំណត់ហេតុ D125/76, ត្រង់ ERN 00898646, D232/7, ត្រង់ ERN 00898647, D232/87, ត្រង់ ERN 00898653 និង D125/69, ត្រង់ ERN 00898654។

[119] **E1/93.1**, ប្រតិចារឹក, David Chandler, ២០ កក្កដា ២០១២, ត្រង់លេខ ERN 00827400។

[120] **E1/21.1**, ប្រតិចារឹក, នួន ជា, ១៣ ធ្នូ ២០១១, ត្រង់លេខ ERN 00767199។

[121] ជាឧទាហរណ៍ សូមមើល ការជំទាស់ទៅនឹងកំណត់ហេតុ D232/87 ក្នុងឧបសម្ព័ន្ធ **E208/5.6**, ត្រង់ ERN 00898653: មេធាវីការពារក្ដីជំទាស់ទៅនឹងសម្រង់មួយចំនួនធំនៃកំណត់ហេតុដែលជាប់ពាក់ព័ន្ធនឹងសាវតាប្រវត្តិសាស្ត្រ រួមទាំងការជម្លៀសភូមិនានាក្នុងឆ្នាំ១៩៧៣ នៃស្រុក ២០ដែលបានរំដោះ ព្រមទាំងការជម្លៀសក្រុងកំពង់ឆ្នាំងនៅថ្ងៃទី១៧ ខែមសា ឆ្នាំ១៩៧៥។ ស្រដៀងគ្នានេះ មេធាវីការពារក្ដីស្នើសុំឲ្យច្រានចោលសម្រង់ពីកំណត់ហេតុ D125/69 (ឧបសម្ព័ន្ធ **E208/5.6**, ត្រង់ ERN 00898654) ដែលមានភ័ស្តុតាងអំពីការជម្លៀសព្រៃនប់ ដោយបង្ខំ ព្រមទាំងការជម្លៀសនៅក្នុងឆ្នាំ១៩៧៥។

[122] ជាឧទាហរណ៍ សូមមើល ការជំទាស់ទៅនឹងកំណត់ហេតុ D232/87 ក្នុងឧបសម្ព័ន្ធ **E208/5.6**, ត្រង់ ERN 00898653: មេធាវីការពារក្ដីជំទាស់ទៅនឹងសម្រង់មួយចំនួនធំនៃកំណត់ហេតុដែលជាប់ពាក់ព័ន្ធនឹងសាវតាប្រវត្តិសាស្ត្រ រួមទាំងការជម្លៀសភូមិនានាក្នុងឆ្នាំ១៩៧៣ នៃស្រុក ២០ដែលបានរំដោះ ព្រមទាំងការជម្លៀសក្រុងកំពង់ឆ្នាំងនៅថ្ងៃទី១៧ ខែមសា ឆ្នាំ១៩៧៥។ ស្រដៀងគ្នានេះ មេធាវីការពារក្ដីស្នើសុំឲ្យច្រានចោល

ឡាយ គឺជាផ្នែកនៃបណ្ដាញរបស់មន្ទីរ ទទួលបន្ទុកក្នុងការអនុវត្ត គោលនយោបាយស្ដីពីការអប់រំឡើងវិញ និងការកម្ទេចពួកខ្មាំង[123]។ ភ័ស្តុតាងជាឯកសារយ៉ាងច្រើនហូរហៀបានបញ្ជាក់អំពីអត្ថិភាពនៃគោលនយោបាយ និងការផ្សព្វផ្សាយនូវគោលនយោបាយ ទាំងនេះ[124]។ កំណត់ហេតុនានាដែលកំពុងត្រូវបានផ្ដល់ជូនដោយសហព្រះរាជអាជ្ញា បានជួយ បង្ហាញអំពីអត្ថិភាព និងប្រសិទ្ធិភាពនៃគោលនយោបាយដែលត្រូវបានបង្កើតឡើងដើម្បីប្រមូលផ្ដុំ អំណាច។ អង្គហេតុពិតដែលថា ទីកន្លែងទាំងនោះត្រូវបានដំណើរការទៅតាមកម្រិតខុសៗគ្នានៃ រចនាសម្ព័ន្ធរដ្ឋអំណាចរបស់ បកក គឺគ្រាន់តែបានបង្ហាញអំពីចរិកលក្ខណៈដ៏ទូលំទូលាយ និងជាប្រព័ន្ធនៃសហឧក្រិដ្ឋកម្មរួម (JCE)។

៤៥. មេធាវីការពារក្ដី ខៀវ សំផន បានដាក់ឧបសម្ពន្ធចំនួន ៥(ប្រាំ) ដែលមានផ្ទុកទៅដោយការ ជំទាស់ផ្សេងៗទៅនឹងសេចក្ដីថ្លែងមួយចំនួនដែលបានដាក់ដោយសហព្រះរាជអាជ្ញា <u>នៅមុនពេល</u>ការកែសម្រួលឡើងវិញនូវឧបសម្ពន្ធលេខ ១២ និង ១៣ - គឺការដាក់ឯកសារលេខ E208 នៅថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១២, ឯកសារលេខ E208/2 នៅថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០១២ និង ឯកសារលេខ E96/8 នៅថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១២។ អាស្រ័យហេតុដូច្នេះ ការជំទាស់ទាំងនេះ ទាក់ទងទៅនឹងតារាងដែលបានជំនួសនានា ដោយឧបសម្ពន្ធដែលបានកែសម្រួលឡើងវិញ លេខ ១២ និង ១៣[125]។ សូម្បីតែនៅពេលដែលកំពុងប្រើប្រាស់នូវឧបសម្ពន្ធដែលផុតសម័យនោះក៏ ដោយ ក៏មេធាវីការពារក្ដី

---

សម្រង់ពីកំណត់ហេតុ D125/69 (ឧបសម្ព័ន្ធ **E208/5.6**, ត្រង់ ERN 00898654) ដែលមានភ័ស្តុតាងអំពីការជម្លៀសព្រៃទប់ ដោយបង្ខំ ព្រមទាំងការជម្លៀសនៅក្នុងឆ្នាំ១៩៧៥។

[123] **E1/191.1**, ប្រតិចារឹក, ៨ ឧសភា ២០១៣, Philp Short, ត្រង់លេខ ERN 00910728។

[124] ជាឧទាហរណ៍ សូមមើល ការជំទាស់ទៅនឹងកំណត់ហេតុ D232/87 ក្នុងឧបសម្ព័ន្ធ **E208/5.6**, ត្រង់ ERN 00898653: មេធាវីការពារក្ដីជំទាស់ទៅនឹងសម្រង់មួយចំនួនធំនៃកំណត់ហេតុដែលជាប់ពាក់ព័ន្ធនឹងសាវតាប្រវត្តិសាស្ត្រ រួមទាំងការជម្លៀសភូមិនានាក្នុងឆ្នាំ១៩៧៣ នៃស្រុក២០ដែលបានរំដោះ ព្រមទាំងការជម្លៀសក្រុងកំពង់ឆ្នាំងនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។ ស្រដៀងគ្នានេះ មេធាវីការពារក្ដីស្នើសុំឲ្យច្រានចោលសម្រង់ពីកំណត់ហេតុ D125/69 (ឧបសម្ព័ន្ធ **E208/5.6**, ត្រង់ ERN 00898654) ដែលមានភ័ស្តុតាងអំពីការជម្លៀសព្រៃទប់ ដោយបង្ខំ ព្រមទាំងការជម្លៀសនៅក្នុងឆ្នាំ១៩៧៥។

[125] សេចក្ដីជំទាស់ទាំងនេះរបស់ ខៀវ សំផន មាននៅក្នុងឧបសម្ពន្ធដូចតទៅ គឺ៖ ក) ឧបសម្ពន្ធ **E208/5.2** - សេចក្ដីជំទាស់ទៅនឹងកំណត់ហេតុស្ដាប់ចម្លើយ នៅក្នុងឧបសម្ព័ន្ធ ១ (ឯកសារ E208.1) ពាក់ព័ន្ធនឹងការជម្លៀសប្រជាជនដោយបង្ខំ ដំណាក់កាលទី១។ ខ) ឧបសម្ពន្ធ **208/5.6** - សេចក្ដីជំទាស់ទៅនឹងកំណត់ហេតុស្ដាប់ចម្លើយ នៅក្នុងឧបសម្ព័ន្ធ ១ (ឯកសារ E208.2) ពាក់ព័ន្ធនឹងការជម្លៀសប្រជាជនដោយបង្ខំ ដែលបានកើតឡើងនៅមុន ឬ នៅពេលជាមួយគ្នានឹង ដំណាក់កាលទី១។ គ) ឧបសម្ពន្ធ **208/5.3** - សេចក្ដីជំទាស់ទៅនឹងកំណត់ហេតុស្ដាប់ ចម្លើយ នៅក្នុងឧបសម្ព័ន្ធ ១ (ឯកសារ E208/2.1) ពាក់ព័ន្ធនឹងកាជម្លៀសប្រជាជនដោយបង្ខំ ដំណាក់កាលទី២។ ឃ) ឧបសម្ពន្ធ **208/5.4** - សេចក្ដីជំទាស់ទៅនឹងកំណត់ហេតុស្ដាប់ចម្លើយ នៅក្នុងឧបសម្ព័ន្ធ ១ (ឯកសារ E96/8.10) ពាក់ព័ន្ធនឹងគោលនយោបាយរបស់ បកក ស្ដីពីការជម្លៀសប្រជាជនដោយបង្ខំ។ និង គ) ឧបសម្ពន្ធ **208/5.5** - សេចក្ដីជំទាស់ទៅនឹងកំណត់ហេតុស្ដាប់ចម្លើយ នៅក្នុងឧបសម្ព័ន្ធ ១ (ឯកសារ E96/8.13) ពាក់ព័ន្ធនឹងគោលនយោបាយរបស់ បកក ស្ដីពីក្រុមគោលដៅជាក់លាក់។

ខៀវ សំផន ថ្លែងថាខ្លួនមិនបានបង្ហាញនូវការជំទាស់ជាក់លាក់ ពាក់ព័ន្ធនឹង សេចក្តីថ្លែងជាលាយលក្ខណ៍អក្សរជាច្រើននោះទេ ពីព្រោះ៖ ក) សេចក្តីថ្លែងជាលាយលក្ខណ៍ អក្សរមួយចំនួនត្រូវបានចោទប្រកាន់ថាឋិតនៅក្រៅវិសាលភាពនៃសំណុំរឿង 00២/0១[126], ខ) សហព្រះរាជអាជ្ញាខកខានមិនបានធ្វើការជ្រើសរើសសង្កាត់នៃអត្ថបទដែលទាក់ទងទៅនឹង អំពើ និង អាកប្បកិរិយា របស់ជនជាប់ចោទ[127] និង គ) ប្រភេទនៃសេចក្តីថ្លែងជាក់លាក់មួយចំនួន ទាក់ទងទៅនឹងធាតុផ្សំសំខាន់ៗនៃរឿងក្តីរបស់អយ្យការ ឬទាក់ទងទៅនឹង អំពើ និង អាកប្បកិរិយា របស់ជនជាប់ចោទ ហើយហេតុដូច្នេះ គេមិនអាចទទួលយកដោយមិនមានការតាំងសំនួរដេញ ដោលទៅលើម្ចាស់អត្ថបទរបស់ភាគីបដិបក្ខបាននោះទេ[128]។

៤៦. ការប្រើប្រាស់ឧសម្ព័ន្ធដែលបានជំនួសនានា ពីសំណាក់មេធាវីការពារក្តី ខៀវ សំផន ធ្វើឲ្យការជំទាស់ជាច្រើនរបស់ពួកខ្លួនឲ្យទៅជាលែងមានការចាំបាច់ (ឧទា. កាលណាការជំទាស់នោះ ទាក់ទងទៅ នឹងសេចក្តីថ្លែងដែលមិនមានដាក់បញ្ចូលនៅក្នុងឧបសម្ព័ន្ធដែលបានកែសម្រួលឡើង វិញ) ឬមួយក៏មិនមានសុពលភាព (ឧទា. ពីព្រោះមេធាវីការពារក្តីខកខានមិនបានយកមក ពិចារណានូវការកោសលុបដែលបានដាក់ស្នើ ដែលសហព្រះរាជអាជ្ញាបានធ្វើឡើង ដើម្បីដកចេញ នូវភ័ស្តុតាងស្តីពីអង្គហេតុ និង អាកប្បកិរិយារបស់ជនសង្ស័យ)។ គេត្រូវបដិសេធចោលនូវការ ជំទាស់ដែលនៅសេសសល់នានា ពីព្រោះការជំទាស់ទាំងនេះបានលើកឡើងពីវិធីសាស្ត្រ ដែលមិន ត្រូវគ្នាទៅនឹងសេចក្តីសម្រេចរបស់ អង្គជំនុំជម្រះសាលាដំបូងលើការទទួលយកកំណត់ហេតុស្តាប់ ចម្លើយសាក្សី។

៤៧. មេធាវីការពារក្តីបានអះអាងថា ខ្លួនត្រូវបានបង្ខំឲ្យថ្លែងយ៉ាងជាក់លាក់ពីការជំទាស់របស់ខ្លួន ដោយមានមូលដ្ឋាននៅលើតារាងដែលបានជំនួសនានា ពីព្រោះសហព្រះរាជអាជ្ញាខកខានមិនបានធ្វើឲ្យ ត្រូវទៅតាម "កាលបរិច្ឆេទកំណត់" ក្នុងការដាក់ឧបសម្ព័ន្ធដែលបានកែសម្រួលឡើងវិញនេះ[129]។ សហព្រះរាជអាជ្ញាបានកត់សម្គាល់ថា គេមិនបានដាក់កាលបរិច្ឆេទកំណត់ណាមួយសម្រាប់ការ កែសម្រួលឡើងវិញនូវឧបសម្ព័ន្ធលេខ ១២ និង ១៣ នេះទេ។ ផ្ទុយទៅវិញ ជាការឆ្លើយតបទៅនឹង សំណើពី

[126] **E208/5**, សេចក្តីជំទាស់របស់លោក ខៀវ សំផន, កថាខណ្ឌ ៣៥ - ទាក់ទងទៅនឹងឧបសម្ព័ន្ធ ៨, ១០-១១ និង ១៣-១៦ នៃ E96/8។

[127] **E208/5**, សេចក្តីជំទាស់របស់លោក ខៀវ សំផន, កថាខណ្ឌ ២៣ - ទាក់ទងទៅនឹងឧបសម្ព័ន្ធ ៣ នៃ E96/8។

[128] **E208/5**, សេចក្តីជំទាស់របស់លោក ខៀវ សំផន, កថាខណ្ឌ ២៤-២៦ - ទាក់ទងទៅនឹងឧបសម្ព័ន្ធ ៤ ដល់ ៧ នៃ E96/8។

[129] **E208/5**, សេចក្តីជំទាស់របស់លោក ខៀវ សំផន, ២៦ មេសា ២០១៣, កថាខណ្ឌ ៩, ១០ និង ១២។

អង្គជំនុំជម្រះសាលាដំបូង ឲ្យពិចារណាលើគំរូជាតំណាងដែលបានដាក់ស្នើ[130] ដែលមាន ភ័ស្តុតាងយ៉ាងច្រើននោះ សហព្រះរាជអាជ្ញាបានចាត់ការធ្វើការងារនេះ ដែលបានកាត់បន្ថយនូវ ចំនួនកំណត់ហេតុ និងពាក្យបណ្តឹងដែលដាក់ជូនពីមុន បានចំនួនប្រមាណជាជាង ៤០ ភាគរយ។ ការងារនេះ ក៏មានជាប់ទាក់ទិនផងដែរទៅនឹងការធ្វើឲ្យមានការលេចច្បាស់ឡើងនៅក្នុង កំណត់ហេតុដែលបានអានពិនិត្យឡើងវិញ ឲ្យឃើញពីគ្រប់សង្កាត់អត្ថបទទាំងអស់ ដែលមានផ្ទុក ទៅដោយភស្តុតាងស្តីពីអំពើ និងអាកប្បកិរិយារបស់ជនសង្ស័យ[131]។ ចាប់តាំងពីថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១២ សហព្រះរាជអាជ្ញាបានផ្តល់ជូនយ៉ាងទៀងទាត់នូវការធ្វើឲ្យទាន់សម័យនៃគំរោងការនេះ ដោយបានជម្រាបជាព័ត៌មានអំពីគំរោងការរបស់ខ្លួន អំពីវិសាលភាពនៃការកាត់បន្ថយដ៏សមគួរ និង អំពីកាលបរិច្ឆេទដែលបញ្ជាក់ពីការបញ្ចប់គំរោងការ ជូនដល់អង្គជំនុំជម្រះ និងភាគីនានា[132]។

៤៨. សហព្រះរាជអាជ្ញាសូមជូនសេចក្តីសន្និដ្ឋានថា មេធាវីការពារក្តីមានឱកាសយ៉ាងបរិបូណ៌ដើម្បីធ្វើការបញ្ជូនការជំទាស់ណាមួយក៏ដោយដែលខ្លួនបានត្រៀមរៀបចំរួចជាស្រេចនោះ ទៅនឹងឧបសម្ព័ន្ធ ដែលបានកែសម្រួលឡើងវិញនេះ។ វាជាការបើកចំហរផងដែរដល់មេធាវីការពារក្តី ខៀវ សំផន ក្នុងការស្វែងរកនូវការព្យារពេលដ៏សមស្រប ដើម្បីធ្វើឲ្យឧបសម្ព័ន្ធរបស់ខ្លួនមានភាពទាន់សម័យ។ គាត់បានជ្រើសរើសយក ការមិនធ្វើដូច្នេះទេ។ មេធាវីការពារក្តី នួន ជា ដែលមានគោលជំហរ ដូចគ្នានេះដែរ បានដាក់តារាងនានាដែលមានផ្ទុកទៅដោយការជំទាស់ផ្សេងៗទៅនឹងឧបសម្ព័ន្ធ ដែលបានពិនិត្យសារឡើងវិញ លេខ ១២ និង ១៣ ដោយមិនបាន សូម្បីតែដាក់សំណើសុំពន្យារ ពេលអ្វីមួយនោះផង។

៤៩. គេត្រូវកត់សម្គាល់ថា ដំបូងឡើយ ឧបសម្ព័ន្ធលេខ ១២ និង ១៣ ត្រូវបានសហព្រះរាជអាជ្ញា ដាក់ជូនជាផ្នែកមួយនៃ បញ្ជីឯកសារតាមវិធាន៨០ កាលពីថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១១។ នៅថ្ងៃទី ១៩ ខែ

[130] **E223/2**, អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពី៖ សវនាការដេញដោលលើឯកសារនាពេលខាងមុខ និងចម្លើយតបទៅនឹងអនុស្សរណៈរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីពាក់ព័ន្ធនឹងសំណើរបស់ អង្គជំនុំជម្រះសាលាដំបូងស្នើសុំកំណត់អត្តសញ្ញាណនៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីសម្រាប់ប្រើប្រាស់នៅសវនាការ (ឯកសារ E208/4) និងសំណើរបស់មេធាវីការពារជនជាប់ចោទ ខៀវ សំផន ស្នើសុំកែតម្រូវបញ្ជីភស្តុតាងគាំទ្រ (ឯកសារ E223), ១៩ តុលា ២០១២, កថាខណ្ឌ ៧។

[131] **E278**, សេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា អំពីឧបសម្ព័ន្ធទី ១២ និងទី ១៣ ដែលបានកែសម្រួលឡើងវិញ ក្នុងបញ្ជីឯកសារសម្រាប់សវនាការរបស់ខ្លួន អនុលោមតាមវិធាន៨០(៣), ៩ មេសា ២០១៣, កថាខណ្ឌ ៤ និង ៣២។

[132] សូមអានអ៊ីមែលរបស់លោក វីលាម ស្មីត ផ្ញើជូន Susan Lamb និង ភាគីនានា នៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១២, ថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១២, ថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៣ (ដោយបានបញ្ជាក់ថា "ដោយមកពីមានការផ្លាស់ប្តូរកាលវិភាគសវនាការនាពេលថ្មីៗនេះ សហព្រះរាជអាជ្ញា ចាំបាច់ត្រូវផ្អាកការងារមួយចំនួនលើគំរោងការនេះ ដើម្បីធ្វើការរៀបចំជាបន្ទាន់នូវការបង្ហាញឯកសារ (និង សាក្សីជំនួសផ្សេងៗទៀត)"), ១៤ កុម្ភៈ ២០១៣។

តុលា ឆ្នាំ២០១២ អង្គជំនុំជម្រះសាលាដំបូងបានដាក់ថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៣ ជា កាលបរិច្ឆេទកំណត់ សម្រាប់ឲ្យមេធាវីការពារក្តីដាក់ការជំទាស់របស់ខ្លួន ទៅនឹងសេចក្តីថ្លែង ទាំងនេះ។ ដូច្នេះ មេធាវីការពារក្តី ខៀវ សំផន ធ្លាប់បានទទួលការជូនដំណឹងអំពីសេចក្តីថ្លែង ទាំងនោះរបស់សហព្រះរាជអាជ្ញា មានរយៈពេលចំនួនពីរឆ្នាំ មកហើយៗ ធ្លាប់បានដឹងអំពីកាល បរិច្ឆេទកំណត់សម្រាប់ដាក់ការជំទាស់របស់ខ្លួន មានរយៈពេលចំនួនជាងប្រាំមួយខែ មកហើយៗក៏ធ្លាប់បានដឹងអំពីគំរោងការកាត់បន្ថយនៅលើឧបសម្ព័ន្ធនានារបស់សហព្រះរាជអាជ្ញា ចាប់តាំងពីខែ វិច្ឆិកា ឆ្នាំ២០១២ មកផងដែរ។ ទោះបីជាមានរឿងបែបនេះហើយក៏ដោយ ក៏ពួកគាត់ទំនងជា មិនបានធ្វើការព្យាយាមអ្វីណាមួយឡើយ ដើម្បីដាក់ជូននូវសេចក្តីជំទាស់ដែលពាក់ព័ន្ធ តែផ្ទុយទៅ វិញបែរជាដាក់ជូននូវឧបសម្ព័ន្ធមួយកម្រងដែលនៅក្នុងនោះមានការជំទាស់ជាច្រើន ជាង ៦៥% នៃការជំទាស់ទាំងនោះគឺសុទ្ធតែមិនមានសុពលភាព ឬមួយក៏ លែងជាការចាំបាច់ទៀតហើយ ខណៈដែលមានការដាក់តែស្តង់ផ្នែកច្បាប់ដែលមានលក្ខណៈខុសឆ្គងទាំងស្រុង។ សកម្មភាពរបស់ មេធាវីការពារក្តី ខៀវ សំផន បានបង្ហាញពីការមិនមានអំពើដោយសុទ្ធចិត្ត ដែលអង្គជំនុំជម្រះមិនត្រូវអត់ឱនឲ្យបានឡើយ។

៥០. ប្រភេទផ្សេងៗគ្នានៃការជំទាស់ដែលបានធ្វើឡើងដោយមេធាវីការពារក្តី ខៀវ សំផន គឺមានទាក់ទងទៅនឹងផ្នែកតូចៗនីមួយៗដូចខាងក្រោមនេះ។

## *ការជំទាស់ទៅនឹងសេចក្តីថ្លែងដែលមិនមាននៅក្នុងឧបសម្ព័ន្ធដែលបានពិនិត្យសារថ្មីឡើងវិញ*

៥១. ការជំទាស់សរុបចំនួន ៧៩ មាននៅក្នុងការដាក់ជូនរបស់មេធាវីការពារក្តី ខៀវ សំផន ដែលទាក់ទងទៅនឹងសេចក្តីថ្លែងចំនួន ៨២ ដែលមិនមានចុះជាបញ្ជីនៅក្នុងឧបសម្ព័ន្ធដែលបានកែសម្រួល ឡើងវិញលេខ ១២ និង ១៣។ ការជំទាស់ទាំងអស់នេះគឺ លែងជាការចាំបាច់ទៀតហើយ។ ដើម្បីជាការងាយស្រួល ការជំទាស់ទាំងនេះមាននៅក្នុងបញ្ជី ត្រង់ផ្នែក I នៃឧបសម្ព័ន្ធ ក។

## *ការជំទាស់ដែលមិនបានថ្លែងបញ្ជាក់*

៥២. មេធាវីការពារក្តី ខកខានមិនបានបញ្ជាក់ឲ្យបានជាក់លាក់អំពីថាតើការជំទាស់ណាមួយទាក់ទងទៅនឹងសេចក្តីថ្លែងទាំងប្រាំបួននោះ ដែលខ្លួនទំនងជាយកមកធ្វើជាបញ្ហានោះទេ។ ដោយហេតុថា អង្គជំនុំជម្រះសាលាដំបូង មិនអាចស្ទង់មើលបានអំពីមូលដ្ឋាននៃការជំទាស់របស់មេធាវីការពារក្តី ទៅនឹង

សេចក្តីថ្លែងទាំងនោះបាន ដូច្នោះ ការជំទាស់ទាំងនោះគឺត្រូវចាត់ទុកថាមិនមាន សុពលភាពទេ។ ឯកសារទាំងនេះ មាននៅក្នុងបញ្ជី ត្រង់ផ្នែក II នៃឧបសម្ពន្ធ ក។

## *ការជំទាស់ទៅនឹងឯកសារដែលបានទទួលយករួចហើយ*

៥៣. កំណត់ហេតុស្តាប់ចម្លើយចំនួនដប់មួយដែលមេធាវីការពារក្តីបានជំទាស់ បានមកពីបុគ្គលដែល ធ្លាប់បានផ្តល់សក្ខីកម្មនៅក្នុងសវនាការនេះ នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង។ ដូច្នេះ កំណត់ហេតុទាំងនោះ ត្រូវបានទទួលយករួចជាស្រេចហើយ[133]។ កំណត់ហេតុទាំងនេះ មាននៅក្នុង បញ្ជី ត្រង់ផ្នែក III នៃឧបសម្ពន្ធ ក។

៥៤. ឯកសារលេខ E208/5.3 ដែលជាឧបសម្ពន្ធរបស់មេធាវីការពារក្តី ខៀវ សំផន មានផ្ទុកទៅដោយការជំទាស់ចំនួនប្រាំមួយទៅនឹងសេចក្តីថ្លែងដែលជាសម្រង់ចេញពីសៀវភៅ អ្នកបះបោរជាជន ជាតិចាម (*The Cham Rebellion)*[134] ដែលសង្កាត់អត្ថបទនានាត្រូវបានអ្នកនិពន្ធសៀវភៅនេះ បញ្ជាក់យថាភាពរួចហើយ។ ការជំទាស់ទាំងនេះគឺមិនមានសុពលភាពទេមកពីសៀវភៅមួយក្បាល នោះត្រូវបានអង្គជំនុំជម្រះសាលាដំបូងធ្លាប់បានទទួលយករួចហើយ ដោយថា វាមានការទាក់ទងគ្នា និងគួរឱ្យទុកចិត្តបាន[135]។ សម្រង់ទាំងនេះ មាននៅក្នុងបញ្ជី ត្រង់ផ្នែក IV នៃឧបសម្ពន្ធ ក។

## *សាក្សីដែលបានទទួលមរណភាព*

---

[133] សូមអាន **E1/57.1** ប្រតិចារឹក, ២ មេសា ២០១២, ភាសាអង់គ្លេស ត្រង់ទំព័រទី ៨៩-៩០, ម៉ោង ១៤:៤៣ ដែលសាក្សីនានាមានបំណងចង់ផ្តល់សក្ខីកម្ម នោះអង្គជំនុំជម្រះបានសម្រេចថាគេត្រូវដាក់កំណត់ហេតុពីមុនៗរបស់ពួកគាត់នៅចំពោះមុខអង្គជំនុំជម្រះ។ **E96/7**, សេចក្តីសម្រេចរបស់អង្គជំនុំជម្រះ, កថាខណ្ឌ ២ ដែលបានចែងថា "ទាក់ទងនឹងសាក្សី ឬដើមបណ្តឹងរដ្ឋប្បវេណីដែលត្រូវកោះហៅឱ្យចូលបង្ហាញខ្លួននៅពេលសវនាការ អង្គជំនុំជម្រះបានបង្ហាញពីមុនថា កំណត់ហេតុស្តាប់ចម្លើយពីមុនៗទាំងអស់ អាចដាក់នៅចំពោះមុខអង្គជំនុំជម្រះ ហើយភាគីនានាមានឱកាសសួរដេញដោលបុគ្គលទាំងនោះ ស្តីពីចំណុចខុសគ្នាពាក់ព័ន្ធផ្សេងៗដែលត្រូវបានចោទប្រកាន់ រវាងកំណត់ហេតុជាខ្សែអាត់សម្លេង និងកំណត់ហេតុស្តាប់ចម្លើយជាសំណេរពីមុន នៅពេលដែលបុគ្គលទាំងនោះត្រូវបានកោះហៅឱ្យផ្តល់សក្ខីកម្មនៅចំពោះមុខអង្គ ជំនុំជម្រះ", និង កថាខណ្ឌ ២៦ បានចែងថា "មានការផ្តល់ជូននូវការការពារបន្ថែមទៀត ដោយហេតុថា សាក្សីដែលត្រូវបានកោះហៅឱ្យមកផ្តល់ភស្តុតាងនៅសវនាការ អាចត្រូវបានសួរដេញដោលដោយអង្គជំនុំជម្រះ ឬគ្រប់ភាគីទៅលើខ្លឹមសារនៃកំណត់ហេតុពីមុនរបស់ពួកគាត់"។

[134] **E3/2653, D196.2**, សៀវភៅនិពន្ធដោយ អ៊ីសា អូស្មាន់ មានចំណងជើងថា៖ "អ្នកបះបោរជាជនជាតិចាមៈ រឿងរ៉ាវរបស់អ្នករស់រានមានជីវិតពីភូមិនានា - The Cham Rebellion: Survivors' Stories from the Villages", ឆ្នាំ២០០៦។

[135] **E185/1**, សេចក្តីសម្រេចលើការជំទាស់ទៅនឹងឯកសារដែលបានស្នើដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងនៅក្នុងឧបសម្ព័ន្ធ A6-A11 និង A14-A20 របស់សហព្រះរាជអាជ្ញា និងឯកសារដែលបានស្នើឡើងដោយភាគីផ្សេងទៀត, ៣ ធ្នូ ២០១២។ **E185/1.3**, ឧបសម្ពន្ធ គៈ ឯកសារដែលបានស្នើឡើងដោយសហព្រះរាជអាជ្ញា, ភាសាអង់គ្លេស ត្រង់លេខ ERN 00884514។

៥៥. ផ្នែក ឃ នៃឧបសម្ពន្ធដែលបានកែសម្រួលឡើងវិញ លេខ ១២ របស់សហព្រះរាជអាជ្ញា មានចុះជាបញ្ជីឈ្មោះបុគ្គលនានាដែលបានទទួលមរណភាព ឬមួយក៏ លែងផ្តល់សក្ខីកម្មបានទៀតហើយ។ នៅក្នុងបញ្ជីនេះ មេធាវីការពារក្តីបានជំទាស់ទៅនឹងសេចក្តីថ្លែងរបស់បុគ្គលចំនួនបួនរូប រួមទាំង ប៉ុល ពត ផង។ ទាំងអស់នេះ មាននៅក្នុងបញ្ជី ត្រង់ផ្នែក V នៃឧបសម្ពន្ធ ក។

៥៦. ដូចដែលបានកត់សម្គាល់នៅក្នុងការដាក់ជូននូវឧបសម្ពន្ធដែលបានកែសម្រួលឡើងវិញ លេខ ១២ និង ១៣ របស់សហព្រះរាជអាជ្ញា ដូច្នោះដែរ អង្គជំនុំជម្រះសាលាដំបូងធ្លាប់បានអនុម័តយកនូវ វិធានអន្តរជាតិនានា ដោយអនុលោមតាមវិធាននោះ សេចក្តីថ្លែង ឬ ប្រតិចារឹកនៃសក្ខីកម្មរបស់ បុគ្គលដែលបានទទួលមរណភាព ឬ របស់សាក្សីដែលមិនអាចមានលទ្ធភាព ណាមួយក៏ដោយ គឺសុទ្ធតែអាចទទួលបានទាំងអស់ រួមទាំង កាលណាវាមានផ្ទុកទៅដោយភស្តុតាងស្តីពី អំពើ និងអាកប្បកិរិយារបស់ជនសង្ស័យផង[136]។

៥៧. សហព្រះរាជអាជ្ញាយល់ស្របថា គេអាចដាក់សេចក្តីថ្លែងរបស់ ប៉ុល ពត ចូលទៅក្នុងប្រភេទមួយផ្សេងពីកំណត់ហេតុស្តាប់ចម្លើយសាក្សី។ សេចក្តីថ្លែងទាំងនោះមិនមែនជាកំណត់ហេតុនៅក្នុងទម្រង់នៃការស្តាប់ចម្លើយសាក្សីដែលធ្វើឡើងដោយអ្នកស៊ើបអង្កេតរបស់អង្គជំនុំជម្រះ ឬដោយអ្នកស្រាវជ្រាវខាងក្រៅនោះទេ។ យ៉ាងណាក៏ដោយ សេចក្តីថ្លែងទាំងនោះមានការជាប់ទាក់ទង និងមានផ្ទុកទៅដោយភស្តុតាងជាភវនីយហេតុ ដោយហេតុថាសេចក្តីថ្លែងទាំងនោះមានដើមកំណើត ចេញមកពីមេដឹកនាំជាន់ខ្ពស់មួយរូបនៃ បកក និងមានជាប់ទាក់ទងទៅនឹងបញ្ហានានា ដូចជា គោលនយោបាយ និងប្រវត្តិ បកក ជាដើម។ សហព្រះរាជអាជ្ញា សូមឲ្យ អង្គជំនុំជម្រះ ទទួលយកសេចក្តីថ្លែងទាំងនេះ ដោយអនុលោមទៅតាមការអនុវត្តជាធម្មតានៃវិធាន ៨៧(៣) ឬមួយក៏ ចាត់ទុកថាជា សេចក្តីថ្លែងរបស់បុគ្គលដែលបានទទួលមរណភាព។

៥៨. សហព្រះរាជអាជ្ញាសូមជូនសេចក្តីសន្និដ្ឋានថា ដើម្បីជាផលប្រយោជន៍នៃយុត្តិធម៌ សូមឲ្យអង្គជំនុំជម្រះទទួលយកគ្រប់កំណត់ហេតុរបស់បុគ្គលដែលបានទទួលមរណភាពទាំងអស់។ ដោយហេតុថា ការកន្លងទៅនៃពេលវេលា ចាប់ពីព្រឹត្តិការណ៍ផ្សេងៗដែលជាប្រធានបទនៃសវនាការនេះមក គេរំពឹងថាមានសាក្សីជាច្រើន រួមទាំង អ្នកដែលបានផ្តល់ចម្លើយនៅក្នុងអំឡុងពេលនៃកិច្ចស៊ើបសួរ ផង ប្រែក្លាយទៅជាលែងមានលទ្ធភាពតទៅទៀតហើយ។ ដោយមិនរាប់បញ្ចូលនូវកំណត់ហេតុរបស់

[136] **E96/7**, សេចក្តីសម្រេចលើសំណើសុំរបស់សហព្រះរាជ្ញា អនុលោមតាមវិធាន ៩២ ពាក់ព័ន្ធនឹងការទទួលយកកំណត់ហេតុស្តាប់ចម្លើយ សាក្សី និងឯកសារនានានៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង, ២០ មិថុនា ២០១២, ត្រង់ចុងបញ្ចប់នៃកថាខណ្ឌ ៣២។

ពួកគាត់ នោះមុខជានឹងមានការដកហូតចេញពីអង្គជំនុំជម្រះនូវឯកសារពាក់ព័ន្ធ ព្រមទាំងធ្វើឱ្យខូចប្រយោជន៍ដល់ការបញ្ជាក់ការពិតនៅក្នុងរឿងក្ដីនេះជាក់ជាមិនខាន។ សហព្រះរាជអាជ្ញា បានកត់សម្គាល់ឃើញថា សេចក្ដីសម្រេចរបស់អង្គជំនុំជម្រះដែលថា អង្គហេតុដែលម្ចាស់នៃ សេចក្ដីថ្លែងណាមួយដែលមិនត្រូវបានគេដាក់ឱ្យនៅក្រោមការតាំងសំនួរដេញដោល មុខជាអាចនឹងមានការប៉ះពាល់ដល់ទម្ងន់ដែលបានដាក់នៅលើសេចក្ដីថ្លែងនោះ ជាមិនខានឡើយ។ សហព្រះរាជអាជ្ញា សូមជូនសេចក្ដីសន្និដ្ឋានថា គោលការណ៍នេះបានធានាយ៉ាងគ្រប់គ្រាន់ដល់សិទ្ធិរបស់ជន ជាប់ចោទទាក់ទងទៅនឹងសេចក្ដីថ្លែងនានារបស់សាក្សីដែលបានទទួលមរណភាព។

## *<u>ការជំទាស់នៅក្នុងឧបសម្ព័ន្ធ E208/5.4 និង E208/5.5 គឺមានលក្ខណៈទូលំទូលាយ និង មិនមានភាពជាក់លាក់</u>*

៥៩. ខណៈដែលឧបសម្ព័ន្ធ E208/5.2, E208/5.3 និង E208/5.6 របស់ ខៀវ សំផន មានផ្ទុកទៅដោយការជំទាស់ទៅនឹងសង្កាត់ដ៏ជាក់លាក់នៃអត្ថបទ ដែលមាននៅក្នុងកំណត់ហេតុស្ដាប់ចម្លើយសាក្សី និងនៅក្នុងពាក្យបណ្ដឹងនោះ ឧបសម្ព័ន្ធ E208/5.4 និង E208/5.5 គឺមិនមានធ្វើសេចក្ដីយោង ណាមួយទៅដល់សង្កាត់ដ៏ជាក់លាក់នៃអត្ថបទនោះទេ ហើយមានផ្ទុកទៅដោយការជំទាស់ដែល មានលក្ខណៈទូលំទូលាយ ដែលត្រូវបានថ្លែងយ៉ាងជាក់លាក់នៅលើមូលដ្ឋានមួយនៃសេចក្ដីសង្ខេប ដែលមិនពេញលេញនៃកំណត់ហេតុរបស់សាក្សី។ ការណ៍នេះ បណ្ដាលឱ្យការជំទាស់ទាំងនោះ មានលក្ខណៈទូលំទូលាយ ហើយមិនអាចឱ្យគេធ្វើការវាយតម្លៃបានទៅលើ ភាពទាក់ទងគ្នា និង សុពលភាព របស់វាបានឡើយ។

៦០. តាមរយៈឧទាហរណ៍ នៅក្នុងឧបសម្ព័ន្ធ E208/5.4 មេធាវីការពារក្ដីបានសង្ខេបសេចក្ដីថ្លែងមួយរបស់ដើមបណ្ដឹង ដូចតទៅ៖ “បណ្ដឹង - ក្រោយថ្ងៃរំដោះបួន-ប្រាំថ្ងៃ នៅតាមផ្លូវជាតិលេខ១ ពួកខ្មែរក្រហមបានប្រើប្រដាប់បំពងសម្លេង ធ្វើការប្រកាសសុំឱ្យពួកអ្នកចម្រៀង និង ហ្វូងទាហាន ដែលមានឋានន្តរសក្ដិចាប់ពី អនុសេនីយ៍ត្រី រហូតដល់ វរសេនីយ៍ឯក ឱ្យប្រមូលផ្ដុំនៅច្បារអំពៅ ក្រោមលេសថាយកពួកទាំងនោះទៅធ្វើការនៅភ្នំពេញ។ ពួកទាំងនោះស្លាប់ទាំងអស់”[137]។ មេធាវីការពារក្ដីបានជំទាស់ទៅនឹងបណ្ដឹងនេះដោយមានទឡ្ហីករណ៍ដូចតទៅ៖ “ចម្លើយចេញក្រៅក្របខណ្ឌនៃការជំនុំជម្រះ

[137] ការបកប្រែក្រៅផ្លូវការពីភាសាបារាំង: សេចក្ដីជំទាស់ទៅនឹងឯកសារ D230/2/3.1.643a, b (សូមអាន ឧបសម្ព័ន្ធ 208/5.4 ត្រង់លេខ ERN 00898610)។

ក្ដី ដូចបានកំណត់ដោយអង្គជំនុំជម្រះនៅក្នុងឯកសារ លេខ E124/7 និង E124/7.3 (កថាខណ្ឌ ២៨-៤១)"[138]។ ទីមួយ ការជំទាស់នេះទំនងជាមានមូលដ្ឋាននៅលើការមាន ជំពាក់ជំពិនដោយខុសឆ្គងដែលថា ការជម្រៀសទីក្រុងភ្នំពេញ និ ការចាប់ខ្លួន/ការសម្លាប់ ពួកទាហានខ្មែរសាធារណៈរដ្ឋ គឺនៅក្រៅវិសាលភាពនៃសំណុំរឿង ០០២/០១។ ទីពីរ ការជំទាស់ នេះមិនមានភាពជាក់លាក់ទេ - វាខកខានមិនបានពន្យល់អំពីថាតើអង្គហេតុជាក់លាក់ណាមួយ ដែលមេធាវីការពារក្ដីយកធ្វើជាបញ្ហានោះឡើយ ហើយនិង ទីបី ការជំទាស់នេះបានរំលងចោលនូវ ភ័ស្តុតាងពាក់ព័ន្ធដែលមាននៅក្នុងបណ្ដឹងនោះ រួមទាំង លក្ខខណ្ឌអមនុស្សធម៌ដែលពួកអ្នកជម្លៀស បានទទួលរងនោះផង។

៦១. ឧទាហរណ៍ទីពីរបង្ហាញពីកង្វះនៃភាពជាក់លាក់នេះ ទាក់ទងនឹងកំណត់ហេតុទាំងឡាយដែលគេអះអាងថា មានផ្ទុកនូវអំពើ និងការប្រព្រឹត្តិរបស់ជនជាប់ចោទ។ នៅក្នុងឧបសម្ព័ន្ធ E208/5.5 មេធាវីការពារក្ដីជំទាស់នឹងកំណត់ហេតុ D25/29[139]។ ម្ចាស់កំណត់ហេតុនេះធ្លាប់ជាប់ឃុំនៅមន្ទីរសន្តិសុខក្រាំង តាចាន់ រៀបរាប់ពីមុខងាររបស់គុកនេះ លក្ខខណ្ឌចំពោះអ្នកទោស ការធ្វើទារុណកម្ម និងអំពើរំលោភសេពសន្ថវៈដែលបានធ្វើមកលើអ្នកទោស ព្រមទាំងការកាប់សម្លាប់អ្នកទោស បន្ទាប់ពីបានទទួលសំបុត្រពីស្រុក។ សាក្សីបាននិយាយថា តា ម៉ុក ជាលេខាភូមិភាគនិរតី បានចុះមកមើលមន្ទីរសន្តិសុខនេះ។ មេធាវីការពារក្ដីជំទាស់នឹងកំណត់ហេតុនេះ ដោយសំអាងថា ភ័ស្តុតាងនោះពីអំពើ និងការប្រព្រឹត្តិរបស់ជនជាប់ចោទមិនអាចទទួលយកបានឡើយ វៀរលែងតែមេធាវីការពារក្ដីត្រូវបានផ្ដល់ឱកាសឲ្យសួរដេញដោលសាក្សីរបស់ភាគីបដិបក្ខទៅលើម្ចាស់នៃកំណត់ហេតុនោះ[140]។ សម្រាប់អង្គជំនុំជម្រះ ឬគូភាគីមិនអាចកំណត់បានថាតើ ផ្នែកត្រង់ណានៃកំណត់ហេតុដែលមេធាវីការពារក្ដីអះអាងថាមានការពាក់ព័ន្ធនឹងអំពើនិងការប្រព្រឹត្តិរបស់ជនជាប់ចោទនោះឡើយ។ កំណត់ហេតុនេះពុំមានភ័ស្តុតាងពីអំពើ និងការប្រព្រឹត្តិរបស់ជនជាប់ចោទណាម្នាក់ទេ។ បើមិនដូច្នោះ វាជាកំណត់ហេតុដែលជាប់ពាក់ព័ន្ធ និងមានតម្លៃភស្តុតាងដោយសារវាផ្ទុកនូវភ័ស្តុតាងអំពីគោលនយោបាយរបស់ បកក ទាក់ទងនឹងជនដែលគេសង្ស័យថាខ្មាំង របទានសម្ព័ន្ធនៃការប្រាស្រ័យទំនាក់ទំនង និងអត្ថិភាពនៃការវាយប្រហារដ៏ទូលំទូលាយ និងជាប្រព័ន្ធប្រឆាំងនឹងប្រជាជនស៊ីវិល។

---

[138] ការបកប្រែក្រៅផ្លូវការពីភាសាបារាំង។ ឧបសម្ពន្ធ **E208/5.4**, សេចក្ដីជំទាស់ទៅនឹងឯកសារ D230/2/3.1.643a, b, ត្រង់លេខ ERN 00898610)។

[139] ឧបសម្ព័ន្ធ **E208/5.5**, ការជំទាស់ទៅនឹងកំណត់ហេតុ D25/29, ត្រង់ ERN 00898611-12។ កំណត់ហេតុនេះគួរអាចរួមគ្នាជាមួយនឹងកំណត់ហេតុ D125/123។

[140] ការបកប្រែក្រៅផ្លូវការពីភាសាដើមបារាំង។

៦២. អាស្រ័យហេតុនេះ អង្គជំនុំជម្រះច្រានចោលការជំទាស់ដែលមាននៅក្នុងឧបសម្ព័ន្ធ E208/5.4 និង E208/5.5 របស់ ខៀវ សំផន ថាមានភាពស្រពិចស្រពិល និងមានកង្វះនូវភាពជាក់លាក់ និង/ឬ បានពឹងផ្អែកលើលក្ខណវិនិច្ឆ័យផ្អែកច្បាប់ដែលខុស។

*__ការជំទាស់ផ្អែកលើការសាកល្បងផ្អែកច្បាប់ដែលខុស__*

*__និងការបកស្រាយមិនត្រឹមត្រូវពីវិសាលភាពនៃសវនាការ__*

៦៣. មានការជំទាស់សរុបចំនួន១១៥ទៀតដែលត្រូវដោះស្រាយ ពេលដែលការជំទាស់ដែលបានបង្ហាញជូនក្នុងវាក្យខណ្ឌខាងលើត្រូវបានដោះស្រាយ។ នៅក្នុងក្រុមនេះ ការជំទាស់ចំនួន២៤ដែលជាប់ទាក់ទងនឹងកំណត់ហេតុដែលមេធាវីការពារក្តីអះអាងថា មានភ័ស្តុតាងពីអំពើ និងការប្រព្រឹត្តិរបស់ជនជាប់ចោទ។ ដូចបានពិភាក្សានៅក្នុងវាក្យខណ្ឌ II.2 មេធាវីការពារក្តី ខៀវ សំផន បានតវ៉ាចំពោះការផ្តល់និយមន័យទូលំទូលាយមិនត្រឹមត្រូវនៃឃ្លាប្រយោគនេះ។ ជាការសំខាន់ មេធាវីការពារក្តីអះអាងថា ចំណែកដែលមានពាក្យថា "អង្គការ" "ខាងលើ" និង "ថ្នាក់លើ" ឬ ការរៀបរាប់ពីការបញ្ជាដែលបានចេញដោយកម្មាភិបាល បកក ថ្នាក់ក្រោម មានតម្លៃស្មើនឹងភ័ស្តុតាងនៃអំពើ និងការប្រព្រឹត្តិរបស់ជនជាប់ចោទ។ ការជំទាស់ដូច្នេះ គឺផ្ទុយនឹងនិមយន័យច្បាប់នៃពាក្យថា "អំពើ និងការប្រព្រឹត្តិរបស់ជនជាប់ចោទ ដូចបានចោទប្រកាន់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ" ដូចដែលបានថ្លែងប្រកាសដោយតុលាការ*ពិសេស*នេះ និងដែលបានអនុម័តទទួលយកដោយអង្គជំនុំជម្រះសាលាដំបូង។

៦៤. ក្នុងចំនួនកំណត់ហេតុ២៤ដូចបានយោងខាងលើ មានកំណត់ហេតុចំនួន១៥ មិនមានផ្ទុកនូវភ័ស្តុតាងណាមួយពីអំពើ និងការប្រព្រឹត្តិរបស់ជនជាប់ចោទ ទៅតាមការសាកល្បងផ្អែកច្បាប់ដែលត្រឹមត្រូវនោះទេ នេះបើតាមគេយល់[141]។ ការជំទាស់ចំនួន៩ ដែលនៅសល់ទាក់ទងនឹងកំណត់ហេតុដែលមានអំពើ និងការប្រព្រឹត្តិរបស់ជនជាប់ចោទ ត្រូវបានកោសលុបដោយសហព្រះរាជអាជ្ញា។ យ៉ាងណាមិញ

[141] ក្នុងឧបសម្ព័ន្ធ **E208/5.2**: ការជំទាស់នឹងកំណត់ហេតុ D232/40, ត្រង់ ERN 00898437; D125/93, ត្រង់ ERN 00898439; D40/8, ត្រង់ ERN 00898441; D232/89, ត្រង់ ERN 00898443; D277/2, ត្រង់ ERN 00898448; D166/110, ត្រង់ ERN 00898450; D246/7, ត្រង់ ERN 00898471; D232/70, ត្រង់ ERN 00898477; D125/177, ត្រង់ ERN 00898484; D232/64, ត្រង់ ERN 00898517; D296/2, ត្រង់ ERN 0089851; ក្នុងឧបសម្ព័ន្ធ **E208/5.3:** D232/79, ត្រង់ ERN 00898526-29; D232/74, ត្រង់ ERN 00898547; ក្នុងឧបសម្ព័ន្ធ **E208/5.6**: លឿង ប៊ុន្នី D246/11, ត្រង់ ERN 00898656; ទួន លន D232/19, ត្រង់ ERN 00898676។

មេធាវីការពារក្តីជំទាស់ទៅនឹងចំណែកនានា ដែលហួសពីផ្នែកដែលបានកោសលុបទាំងនោះ ដោយសារតែពួកគេបានអនុវត្តការសាកល្បងផ្នែកច្បាប់ដែលខុស[142]។

៦៥. មានឧទាហរណ៍ចំនួនពីរនៃការជំទាស់របស់មេធាវីការពារក្តី ខៀវ សំផន ដែលបង្ហាញពីការអនុវត្តនូវការសាកល្បងផ្នែកច្បាប់ដែលខុស ដូចខាងក្រោម៖

ក. នៅក្នុងឧបសម្ព័ន្ធ E208/5.2 មេធាវីការពារក្តីជំទាស់ទៅនឹងសម្រង់ពីកំណត់ហេតុ D40/8 ដោយឈរលើមូលហេតុថា សម្រង់នោះមានអំពើ និងការប្រព្រឹត្តិរបស់ជនជាប់ចោទ។ សម្រង់នេះរៀបរាប់ពីការជម្លៀសដោយខ្មែរក្រហម នូវវត្តមួយនៅក្នុងខែមេសា ឆ្នាំ១៩៧៥ និងបានយោងសំដៅទៅរក "អង្គការ"។ ដូចបានបង្ហាញក្នុងវាក្យខណ្ឌ XX ការយោងទៅរកស្ថាប័ន អង្គការ ឬ ក្រុមដែលជនជាប់ចោទត្រូវបានចោទប្រកាន់ថាជាសមាជិកនោះមិនមានគុណវុឌ្ឍិជាភ័ស្តុតាងនៃអំពើ និងការប្រព្រឹត្តិរបស់ជនជាប់ចោទខ្លួនឯងឡើយ។

ខ. នៅក្នុងឧបសម្ព័ន្ធ E208/5.6 មេធាវីការពារក្តីតវ៉ាថា សម្រង់ចេញពីកំណត់ហេតុ E3/428 ដែលរៀបរាប់អំពីការបញ្ជាឲ្យជម្លៀស ត្រូវបានចេញនៅត្រឹមថ្នាក់កងវរៈសេនាធំ នៅក្នុងខេត្តកំពត គឺជាការមិនអាចទទួលយកបាន បើគ្មានការសួរដេញដោលសាក្សីរបស់ភាគីបដិបក្ខនៃម្ចាស់កំណត់ហេតុនេះ។ ជាថ្មីម្តងទៀត គ្មានការនិយាយពីអំពើ និងការប្រព្រឹត្តិរបស់ជនជាប់ចោទទេ ហេតុដូច្នេះការជំទាស់នេះមិនត្រឹមត្រូវឡើយ[143]។

៦៦. ការជំទាស់ភាគច្រើនដែលនៅសល់ ជាប់ទាក់ទងនឹងសម្រង់នៃកំណត់ហេតុ ដែលរៀបរាប់ពីចេតនារើសអើងប្រឆាំងនឹង "ប្រជាជន ១៧មេសា" "ប្រជាជនថ្មី" ឬ "មន្ត្រីនៃរបបសាធារណរដ្ឋខ្មែរ"[144]។

---

[142] ក្នុង **E208/5.2**: D232/54, ត្រង់ ERN 00898446; D166/125, ត្រង់ ERN 00898456; D166/117, ត្រង់ ERN 00898458; D166/73, E3/509, ត្រង់ ERN 00898459; D232/48, ត្រង់ ERN 00898487: D232/12, ត្រង់ ERN 00898512; ក្នុងឧបសម្ព័ន្ធ **E208/5.3**: D125/104, ត្រង់ ERN 00898538; ក្នុងឧបសម្ព័ន្ធ **E208/5.6**: D234/9 និង E3/428, ត្រង់ ERN 00898673។

[143] D234/9, E3/428, ក្នុងឧបសម្ព័ន្ធ **E208/5.6** ត្រង់ ERN 00898673។

[144] ជាឧទាហរណ៍ ក្នុងឧបសម្ព័ន្ធ **E208/5.2**: D166/35, ត្រង់ ERN 00898426, D125/171, ត្រង់ ERN 00898427-28; D125/71, ត្រង់ ERN 00898431; D166/123, ត្រង់ ERN 00898432; D166/41, ត្រង់ ERN 00898443; D296/9, ត្រង់ ERN 00898444; D232/44, ត្រង់ ERN 00898449; D277/3, ត្រង់ ERN 00898451; D125/86, ត្រង់ ERN 00898456; D125/68, ត្រង់ ERN 00898468; D125/92, ត្រង់ ERN 00898476; D40/15, ត្រង់ ERN 00898481; D232/42, ត្រង់ ERN 00898488; D125/91, ត្រង់ ERN 00898494; D246/16, ត្រង់ ERN 00898498; D166/82, ត្រង់ ERN 00898515; ក្នុងឧបសម្ព័ន្ធ **E208/5.3**: D125/154,

មេធាវីការពារក្ដីសន្និដ្ឋានថា បញ្ហានៃការប្រព្រឹត្តិដោយរើសអើងមកលើក្រុមទាំងនេះ មិនបានដេញដោលទេ។

៦៧. ទីមួយ នៅទីនេះមេធាវីការពារក្ដីអនុវត្តការសាកល្បងផ្នែកច្បាស់ដែលខុស។ បញ្ហាថាតើបញ្ហានោះធ្លាប់បាន "ដេញដោល" ពុំមានបន្ទុកចំពោះការទទួលយកកំណត់ហេតុសាក្សីឡើយ - វៀរលែងតែមេធាវីការពារក្ដីចោទថា កំណត់ហេតុដែលបានដាក់ជូននោះមិនមែន *ត្រួតបន្ថែម* ទៅលើភ័ស្តុតាងដែលមានស្រាប់។ ទោះបីជាការជំទាស់ត្រូវបានធ្វើឡើងដោយផ្អែកលើទឡ្ហីករណ៍ទីពីរក៏ដោយ ក៏វាត្រូវតែបរាជ័យ។ ការប្រព្រឹត្តិដោយរើសអើង ប្រឆាំងនឹងក្រុមដូចបានលើកយោងខាងលើ ធ្លាប់ជាកម្មវត្ថុនៃបង្ហាញភ័ស្តុតាងសក្ខីកម្មដ៏ទូលំទូលាយ ហើយមានការពាក់ព័ន្ធនឹងឯកសារ បកក ជាច្រើនដែលអង្គជំនុំជម្រះសាលាដំបូងបានទទួលយករួចហើយ[145]។ ភ័ស្តុតាងដែលមាននៅក្នុងកំណត់ហេតុជាលាយល័ក្ខណ៍អក្សរ ដែលបានចុះបញ្ជីក្នុងឧបសម្ព័ន្ធ ១២ និង១៣ ដែលបានកែសម្រួលឡើងវិញគឺជាបមាណីយករណ៍ និងជាកម្លាំងត្រួតបន្ថែមចំពោះភ័ស្តុតាងនោះ។

៦៨. ទីពីរ សហព្រះរាជអាជ្ញាកត់សំគាល់ថា មេធាវីការពារក្ដីហាក់ដូចជាកំពុងតែប្រើការជំទាស់ "ការដេញដោល"មិនត្រឹមត្រូវរបស់ខ្លួន (ទាក់ទងនឹងចេតនារើសអើង) ដើម្បីច្រានចោលភ័ស្តុតាងនៃការជម្លៀសថ្ងៃ១៧ មេសា នោះតែម្តង[146]។ ដើម្បីឲ្យកាន់តែច្បាស់ ភ័ស្តុតាងបញ្ជាក់ពីមូលដ្ឋានឧក្រិដ្ឋកម្មទាក់ទងនឹងការជម្លៀស ជាញឹកញាប់ ទោះបីវាមិននិរន្តរក៏ដោយ ក៏ទាក់ទងនឹងបញ្ហានៃការប្រព្រឹត្តិដោយរើសអើងចំពោះប្រជាជនក្រុង និងមន្ត្រីនៃសាធារណរដ្ឋខ្មែរដែរ។ ទាំងពីរគឺជាបញ្ហាដែលស្ថិតក្រោមវិសាលភាពនៃសវនាការនេះ ទាំងពីរធ្លាប់ជាកម្មវត្ថុនៃការផ្តល់ភ័ស្តុតាងសក្ខីកម្ម ហើយទាំងពីរ គឺស្ថិតនៅក្នុងជំពូកនៃអង្គហេតុដែលអង្គជំនុំជម្រះសាលាដំបូងធ្លាប់បានប្រកាសថា ជាភ័ស្តុតាងដែលអាចទទួលយក

---

ត្រង់ ERN 00898533; ក្នុងឧបសម្ព័ន្ធ **E208/5.6**: D166/100, ត្រង់ ERN 00898650; D25/28, ត្រង់ ERN 00898652; D125/170, ត្រង់ ERN 00898655។

[145] ជាឧទាហរណ៍ ដើមបណ្តឹងរដ្ឋប្បវេណី សាក្សី និងអ្នកជំនាញខាងក្រោម បានពិភាក្សាពីធាតុផ្សំនៃចេតនារើសអើងប្រឆាំងនឹងប្រជាជន ១៧ មេសា និង/ឬ អតីតមន្ត្រីនៃសាធារណរដ្ឋខ្មែរ៖ Denise Affonço, ជុំ សុខា, ឡាយ បូនី, ពេជ ស្រីផល, François Ponchaud, Philip Short, ខឹម ងន, សុខ ឈិន, អ៊ុំង ឆាត់ និង ស៊ុំ ជា។

[146] សូមមើល ជាឧទាហរណ៍ ក្នុងឧបសម្ព័ន្ធ **E208/5.6**: D125/170, ត្រង់ ERN 00898655 ដែលមេធាវីការពារក្ដីដាក់បញ្ចូលទៅក្នុងចំណែកនៃសម្រង់ដែលពាក់ព័ន្ធ ទាក់ទងនឹងការជម្លៀសនិងហេតុផលដែលផ្តល់ជូនប្រជាជនជាយុត្តិកម្មចំពោះការជម្លៀស។ ក្នុងចំណោមបញ្ហាផ្សេងទៀត ចំណុចដូចគ្នានេះក៏អនុវត្តចំពោះសម្រង់ពីកំណត់ហេតុ D166/100 (**E208/5.6**, ត្រង់ ERN 00898650), និងចំពោះកំណត់ហេតុ D125/71, (**E208/5.2** ត្រង់ ERN 00898431) ផងដែរ។

បាន ក្នុងទម្រង់ជាកំណត់ហេតុជាលាយលក្ខណ៍អក្សរ[147]។ គោលជំហរដូចគ្នានេះក៏អនុវត្តចំពោះការព្យាយាមរបស់មេធាវីការពារក្តីក្នុងការច្រានចោលភស្តុតាងភវនីយភាព ទាក់ទងនឹងទីតាំងឧក្រិដ្ឋកម្មទួលពោធិ៍ជ្រៃ ដែរ[148]។

៦៩. ជាចុងក្រោយ មេធាវីការពារក្តីក៏ជំទាស់ទៅនឹងកំណត់ហេតុដែលមានភស្តុតាងពាក់ព័ន្ធនឹងការដ្ឋាន និងសហករណ៍[149] ការប្រព្រឹត្តិចំពោះចាម[150] ពុទ្ធសាសនិកជន[151] ឬ ជនជាតិវៀតណាម[152] ឬចំពោះព្រឹត្តិការណ៍នានាដែលបានកើតឡើងនៅមុនឆ្នាំ១៩៧៥[153]ផងដែរ ដែលគេនិយាយថា មិនស្ថិតនៅក្នុងវិសាលភាពនៃសវនាការនេះ។ ដូចបានពិភាក្សាក្នុងវាក្យខណ្ឌ II.៥ ការជំទាស់ទាំងនេះមិនអើពើនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា អត្ថិភាពនិងការអភិវឌ្ឍន៍គោលនយោបាយទាំងប្រាំ ដូចបានរៀបរាប់ក្នុងដីកាដំណោះស្រាយ មិនដាក់បញ្ចូលក្នុងសវនាការនេះទេ។

៧០. ដូចបានពិភាក្សានៅក្នុងវាក្យខណ្ឌ II.៥ សហព្រះរាជអាជ្ញា បានដាក់ជូននូវសំណាកកំណត់ហេតុជាតំណាងមួយដែលពាក់ព័ន្ធនឹងគោលនយោបាយ បកក តាមរយៈការជ្រើសរើសកំណត់ហេតុមួយចំនួនតូចសម្រាប់ទីតាំងឧក្រិដ្ឋកម្មនិមួយៗដែលបានដាក់បញ្ចូលក្នុងសំណុំរឿង 00២ (ទីតាំងដែលមិនបានបញ្ចូលក្នុង 00២/១)។ កំណត់ហេតុទាំងនេះ ពាក់ព័ន្ធទៅនឹងវិសាលភាពនៃបញ្ហាផ្សេងៗដែលបានបញ្ចូលក្នុងសវនាការនេះដូចជាសាវតាប្រវត្តិសាស្ត្រ អត្ថិភាពនិងការអភិវឌ្ឍន៍បន្ថែមទៀតចំពោះគោលនយោបាយនានាក្នុងសម័យកាលកម្ពុជាប្រជាធិបតេយ្យ រចនាសម្ព័ន្ធសិទ្ធិអំណាច និងការ ប្រាស្រ័យទំនាក់ទំនងរបស់ បកក និងអត្ថិភាពនៃការវាយប្រហារដ៏ទូលំទូលាយនិងជាប្រព័ន្ធទៅលើប្រជាជនស៊ីវិល។ មេធាវីការពារក្តី ខៀវ សំផន អះអាងថា មានកំណត់ហេតុខ្លះ មិនស្ថិតក្នុងវិសាលភាព*ពេលវេលា* នៃសវនាការទេដោយមិនអើពើនឹងការពិតដែលថា ភស្តុតាងនៃការអភិវឌ្ឍន៍គោល

[147] **E96/7** សេចក្តីសម្រេចស្តីពីភាពអាចទទួលយកបាននៃកំណត់ហេតុស្តាប់ចម្លើយសាក្សី, ត្រង់កថាខណ្ឌទី២៤។

[148] ជាឧទាហរណ៍ សូមមើលឧបសម្ព័ន្ធ **E208/5.2**, ការជំទាស់ទៅនឹងកំណត់ហេតុ D125/174, ត្រង់ ERN 00898428-30។

[149] ជាឧទាហរណ៍ សូមមើលឧបសម្ព័ន្ធ **E208/5.3**: ការជំទាស់ទៅនឹងកំណត់ហេតុ D125/169, ត្រង់ ERN 00898524, D166/181, ត្រង់ ERN 00898529; និង ឧបសម្ព័ន្ធ **E208/5.6**: ការជំទាស់ទៅនឹងកំណត់ហេតុ D246/14, ត្រង់ ERN 00898650។

[150] ឧបសម្ព័ន្ធ **E208/5.2**: ការជំទាស់ទៅនឹងកំណត់ហេតុ D166/42, ត្រង់ ERN 00898509; D166/79, ត្រង់ ERN 00898514; ឧបសម្ព័ន្ធ **E208/5.3**: ការជំទាស់ទៅនឹងកំណត់ហេតុ D125/102, ត្រង់ ERN 00898531 និង D125/129, ត្រង់ ERN 00898539។

[151] ឧបសម្ព័ន្ធ **E208/5.2**: ការជំទាស់ទៅនឹងកំណត់ហេតុ D40/3, ត្រង់ ERN 00898460, D232/77, ត្រង់ ERN 00898475 និង D277/10, ត្រង់ ERN 00898502 (ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ ត្រូវបានកំណត់ពេលមកផ្តល់សក្ខីកម្មអំពីការឈឺចាប់របស់គាត់)។

[152] ឧបសម្ព័ន្ធ **E208/5.2**: ការជំទាស់ទៅនឹងកំណត់ហេតុ D125/57, ត្រង់ ERN 00898482។

[153] ឧបសម្ព័ន្ធ **E208/5.6**: ការជំទាស់ទៅនឹងកំណត់ហេតុ D125/76, ត្រង់ ERN 00898646, D232/7, ត្រង់ ERN 00898647, D232/87, ត្រង់ ERN 00898653 និង D125/69, ត្រង់ ERN 00898654។

នយោបាយនានារបស់ បកក នៅមុនខែមេសា ១៩៧៥ គឺមានការជាប់ពាក់ព័ន្ធដោយផ្ទាល់ទៅនឹងអត្ថិភាពនិងការពង្រឹងការអនុវត្តគោលនយោបាយទាំងនោះនៅថ្ងៃទី១៧ មេសា ១៩៧៥ និងក្នុងរយៈពេលជាច្រើនខែ ច្រើនឆ្នាំបន្ទាប់ពីនោះមកទៀតនោះឡើយ[154]។

៧១. សហព្រះរាជអាជ្ញា សូមស្នើឱ្យអង្គជំនុំជម្រះច្រានចោលការជំទាស់ទាំងអស់ ដែលបានដាក់ដោយមេធាវីការពារក្តី ខៀវ សំផន និងទទួលយកកំណត់ហេតុនៅក្នុងឧបសម្ព័ន្ធ ១២ និង ១៣ ដែលបានកែសម្រួលឡើងវិញ។ កំណត់ហេតុគួរបានទទួលយកជាសំណៅកោសលុប តាមការស្នើសុំរបស់សហព្រះរាជអាជ្ញា ធ្វើដូច្នេះទើបមានការដកចេញនូវភ័ស្តុតាងពីអំពើ និងការប្រព្រឹត្តិរបស់ជនជាប់ចោទ វៀរលែងតែសាក្សីបានស្លាប់ ឬមិនអាចរកបាន ដែលក្នុងករណីណាមួយនោះកំណត់ហេតុគួរបានទទួលយកទាំងស្រុង[155]។

**២. សេចក្តីជំទាស់របស់ នួន ជា ទៅនឹងកំណត់ហេតុស្តាប់ចម្លើយ និងពាក្យបណ្តឹងនានា**

៧២. ជាបញ្ហាអំពីការចូលចំណុចចាប់ផ្តើម សហព្រះរាជអាជ្ញាសូមជូនសេចក្តីសន្និដ្ឋានថា មិនមានការជំទាស់ទៅនឹងឯកសារដ៏ជាក់លាក់ណាមួយដែលមេធាវីការពារក្តី នួន ជា បានធ្វើឱ្យបានលំអិតគ្រប់គ្រាន់ដើម្បីទៅដាក់បន្ទុករបស់ខ្លួននៅក្នុងការបកស្រាយបង្ហាញថាគេមិនត្រូវទទួលយក នូវឯកសារទាំងឡាយនោះឡើយ។ នៅក្នុងឧបសម្ព័ន្ធរបស់ខ្លួន មេធាវីការពារក្តីបានប្រើប្រាស់ នូវចំណារជាទម្រង់ខ្លីៗដោយបានរៀបរាប់ពីប្រភេទទូទៅនៃព័ត៌មានក្នុងឯកសារ ដែលពួលគាត់បាន លើកឡើងចោទប្រកាន់ថាអាចជំទាស់បាន ដោយបានបន្សល់ទុកឱ្យអង្គជំនុំជម្រះធ្វើការកំណត់រក ថាតើផ្នែកជាក់លាក់ត្រង់

[154] ជាឧទហរណ៍ សូមមើល ការជំទាស់ទៅនឹងកំណត់ហេតុ D232/87 ក្នុងឧបសម្ព័ន្ធ **E208/5.6**, ត្រង់ ERN 00898653: មេធាវីការពារក្តីជំទាស់ទៅនឹងសម្រង់មួយចំនួនធំនៃកំណត់ហេតុដែលជាប់ពាក់ព័ន្ធនឹងសារតាប្រវត្តិសាស្ត្រ រួមទាំងការជម្លៀសភូមិនានាក្នុងឆ្នាំ១៩៧៣ នៃស្រុក ២០ដែលបានរំដោះ ព្រមទាំងការជម្លៀសក្រុងកំពង់ឆ្នាំងនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។ ស្រដៀងគ្នានេះ មេធាវីការពារក្តីស្នើសុំឱ្យច្រានចោលសម្រង់ពីកំណត់ហេតុ D125/69 (ឧបសម្ព័ន្ធ **E208/5.6**, ត្រង់ ERN 00898654) ដែលមានភ័ស្តុតាងអំពីការជម្លៀសព្រៃទប់ ដោយបង្ខំ ព្រមទាំងការជម្លៀសនៅក្នុងឆ្នាំ១៩៧៥។

[155] កំណត់ហេតុនៅក្នុងឧបសម្ព័ន្ធរបស់ ខៀវ សំផន ដែលបានកោសលុបចំពោះអំពើ និងការប្រព្រឹត្តិរបស់ជនជាប់ចោទមាន៖ ឧបសម្ព័ន្ធ **E208/5.4**: D368/2, ចុះបញ្ជី ត្រង់ ERN 00898552, D108/27.19, ចុះបញ្ជី ត្រង់ ERN 00898553; D313/1.2.406 និង D313/1.2.406.1, ចុះបញ្ជី ត្រង់ ERN 00898554-56; D313/1.2.405, ចុះបញ្ជី ត្រង់ ERN 00898557; IS 19.216, ចុះបញ្ជី ត្រង់ ERN 00898567; IS 19.219, ចុះបញ្ជី ត្រង់ ERN 00898567; D166/116, ចុះបញ្ជី ត្រង់ ERN 00898569; D94/4, ចុះបញ្ជី ត្រង់ ERN 00898585, IS 19.41, ចុះបញ្ជី ត្រង់ ERN 00898586; ឧបសម្ព័ន្ធ **E208/5.5**: D108/27.19, ចុះបញ្ជី ត្រង់ ERN 00898614; D223.15, ចុះបញ្ជី ត្រង់ ERN 00898616; IS 19.24, ចុះបញ្ជី ត្រង់ ERN 00898617; IS 19.108, ចុះបញ្ជី ត្រង់ ERN 00898619; D269/9/1.15.1 & D210/5 ឬ D248/2.2, ចុះបញ្ជី ត្រង់ ERN 00898620; IS 19.160, ចុះបញ្ជី ត្រង់ ERN 00898622; IS 19.182, ចុះបញ្ជី ត្រង់ ERN 00898623; IS 19.196, ចុះបញ្ជី ត្រង់ ERN 00898624។

ណាខ្លះនៃឯកសារនោះមានការពាក់ព័ន្ធទៅនឹងការជំទាស់នោះ ហើយថាតើវាទាក់ទងគ្នាយ៉ាងដូចម្ដេច។ អាស្រ័យហេតុដូច្នេះ ទម្រង់នៃការជំទាស់ទាំងនោះ គឺមិនមាន លក្ខណៈគ្រប់គ្រាន់ទេ។

*វិសាលភាព*

៧៣. ដោយអនុលោមតាមការដាក់ជូនតាមផ្លូវច្បាប់ដែលបានចែងនៅក្នុងផ្នែក II.៤ សហព្រះរាជអាជ្ញាសូមជូនសេចក្ដីសន្និដ្ឋានថា សេចក្ដីជំទាស់របស់មេធាវីការពារក្ដី នួន ជា ដែលថា សេចក្ដីថ្លែងនានាដែលគេបានផ្ដល់ជូននោះមិនអាចទទួលយកបានទេ ពីព្រោះសេចក្ដីថ្លែងទាំងនោះមានផ្ទុកទៅដោយភ័ស្តុតាងស្ដីពីបញ្ហានានាដែលនៅក្រៅវិសាលភាពនៃសំណុំរឿងលេខ ០០២/០១[156]។ ជាឧទាហរណ៍ មេធាវីការពារក្ដី នួន ជា បានថ្លែងថាឯកសារលេខ D125/68 គឺ "អំពីគុកព្រៃដំរីស្រុតស្ទើរតែទាំងស្រុង"[157] ហើយថាឯកសារលេខ D232/18 "ពាក់ព័ន្ធនឹងមន្ទីរសន្តិសុខក្រាំងតាចាន់"[158]។ ដូចដែលបានបកស្រាយបង្ហាញនៅក្នុងផ្នែក II.៤ និង II.៥ ដូច្នោះដែរ សេចក្ដីថ្លែងទាំងឡាយដែលទាក់ទងទៅនឹងឧក្រិដ្ឋកម្មនានាដែលបានប្រព្រឹត្តនៅតាមមន្ទីរសន្តិសុខនីមួយៗ គឺបានជួយបង្ហាញអំពី អត្ថិភាពនៃគោលនយោបាយរបស់ បកក ពាក់ព័ន្ធទៅនឹងពួកដែលគេសង្ស័យថាជាខ្មាំង ព្រមទាំងបាន ជួយដល់អង្គជំនុំជម្រះនៅក្នុងការពិចារណាពី លក្ខខណ្ឌតម្រូវស្ដីពីការវាយប្រហារជាទូទៅ និងជាប្រព័ន្ធសម្រាប់គោលបំណងនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។

*អំពីអំពើ និងការប្រព្រឹត្ត*

៧៤. អនុលោមតាមសេចក្ដីសន្និដ្ឋានលើអង្គច្បាប់ ដែលបានធ្វើឡើងនៅផ្នែក ទី II.៤ សហព្រះរាជអាជ្ញាសូមលើកឡើងជាមតិដើម្បីពិចារណាថា ការជំទាស់របស់មេធាវី នួន ជា ដែលថា មានកំណត់ហេតុស្ដាប់ចម្លើយសាក្សីមួយចំនួនក្នុងចំណោមកំណត់ហេតុ ដែលបានស្នើសុំផ្ដល់ជូនមិនអាចទទួលយកបានពីព្រោះនៅក្នុងកំណត់ហេតុទាំងនោះ មានភ័ស្តុតាងអំពីអំពើ និងការប្រព្រឹត្តរបស់ជនជាប់ចោទ គឺមិនមានមូលដ្ឋានត្រឹមត្រូវនោះឡើយ ដែលគួរតែត្រូវបានបដិសេធ[159]។ ឧទាហរណ៍ដូចជា មេធាវីរបស់

---

[156] សូមអាន ឧបសម្ព័ន្ធ ខ - ផ្នែក I ។

[157] សូមអាន ជាឧទហរណ៍ **E223/2/8/1.2** ឧបសម្ព័ន្ធ១ - សេចក្ដីជំទាស់របស់ នួន ជា ទៅនឹង ឧបសម្ព័ន្ធ១២ ដែលបានកែសម្រួលឡើងវិញ របស់ កសព - កំណត់ហេតុស្ដាប់ចម្លើយ លេខ១៨១ របស់សាក្សី។

[158] សូមអាន ជាឧទហរណ៍ **E223/2/8/1.2** ឧបសម្ព័ន្ធ១ - សេចក្ដីជំទាស់របស់ នួន ជា ទៅនឹង ឧបសម្ព័ន្ធ១២ ដែលបានកែសម្រួលឡើងវិញ របស់ កសព - កំណត់ហេតុស្ដាប់ចម្លើយ លេខ១៨០ របស់សាក្សី។

[159] See Annex B, part II.

នួន ជា បានចោទប្រកាន់ថា “ការណែនាំរបស់អង្គការ”[160] និងការយោងទៅលើ “ឋានានុក្រមថ្នាក់លើ” និង “មន្ទីរ៨៧”[161] ដែលស្មើនឹងអំពើ និងការប្រព្រឹត្តរបស់ជនជាប់ចោទ។ ផ្ទុយគ្នានឹងសេចក្តីសន្និដ្ឋានទាំងនេះ ឃ្លាដែលថា “អំពើ និងការប្រព្រឹត្តរបស់ជនជាប់ចោទ ដូចដែលបានចោទប្រកាន់នៅក្នុងដីការបញ្ជូនរឿងទៅជំនុំជម្រះ” គឺនិយាយសំដៅតែទៅលើជនជាប់ចោទតែប៉ុណ្ណោះ ហើយមិនសំដៅទៅលើជន ឬស្ថាប័នផ្សេងទៀតនោះឡើយ។

<u>*អំពីភាពនៅជិតគ្នាបំផុត*</u>

៧៥. អនុលោមតាមសេចក្តីសន្និដ្ឋានលើអង្គច្បាប់ ដែលបានធ្វើឡើងនៅផ្នែក ទី II.១-៣ សហព្រះរាជអាជ្ញាសូមជូនជាយោបល់ថា ការជំទាស់របស់មេធាវី នួន ជា ដែលថា មានកំណត់ហេតុស្តាប់ចម្លើយសាក្សីមួយចំនួនក្នុងចំណោមកំណត់ហេតុដែលបានស្នើសុំផ្តល់ជូន មិនអាចទទួលយកបានពីព្រោះនៅក្នុងកំណត់ហេតុទាំងនោះមានភ័ស្តុតាងអំពីបញ្ហានានា ដែលមានភាពនៅជិតគ្នាបំផុតនឹងជនជាប់ចោទនោះ គឺមិនមានមូលដ្ឋានត្រឹមត្រូវនោះឡើយ[162]។ ឧទាហរណ៍ដូចជា មេធាវីរបស់ នួន ជា បានចោទប្រកែកតវ៉ា កំណត់ហេតុស្តាប់ចម្លើយសាក្សីទាំងនោះមិនត្រូវបានទទួលយកពីព្រោះ នៅក្នុងកំណត់ហេតុទាំងនោះមានភ័ស្តុតាងអំពីអំពើ និងការប្រព្រឹត្តរបស់៖ ក) បុគ្គលនានាដូចជា ប៉ុល ពត, អៀង សារី, វណ្ណ រិទ្ធ, ឌុច, តាម៉ុក, អៀង ធីរិទ្ធ, វន វ៉េត, រស ញឹម", មូល សម្បត្តិ, សុន សេន, សោ ភឹម, ប៉ាង, កែ ពក, យុន យ៉ាត, ហ៊ូ យន់, ហ៊ូ នឹម, កុយ ធួន, និង តា ញ៉ែម[163]។ ខ) ក្រុមនានាដូចជា “មន្ត្រីយោធាជាន់ខ្ពស់នានា”[164]និង “សមាជិកជាន់ខ្ពស់នានារបស់ បកក” [*sic*] ដែលនៅជិតគ្នានឹង នួន ជា បំផុត”[165]។និងយោទៅលើមន្ទីរស-២១[166] ។ នៅពេលដែលបុគ្គលខ្លះក្នុងចំណោមបុគ្គលទាំងនេះនៅជិតគ្នាបំបផុនឹងកូនចៅក្រោមបង្គាប់ឬសហចារីរបស់ជនជាប់ចោទ បែបនេះ ធ្វើឲ្យការជំទាស់គ្មានសុពលភាព ព្រោះ៖ ក) អង្គជំនុំជម្រះនេះមិនបានសំរេចអំពី កត្តានៃ “ភាពនៅជិតគ្នាបំផុត” ដែលអាចយកមកអនុវត្តបានសំរាប់ការទទួលយកនូវកំណត់ហេតុស្តាប់ចម្លើយសាក្សីនៅ អវតក ឡើយ និង ខ)

---

[160] See, e.g., **E223/2/8/1.2** Annex 1 - NC Objections to OCP Revised Annex 12 - Witness Statements number 188.
[161] See, e.g., **E223/2/8/1.2** Annex 1 - NC Objections to OCP Revised Annex 12 - Witness Statements number 223.
[162] See Annex B, part III.
[163] See, e.g., **E223/2/8/1.2** Annex 1 - NC Objections to OCP Revised Annex 12 - Witness Statements number 189, 201, 226, 242, 258, 290, 297, 333, 338, 347, 398, 729, 737, 794 .
[164] See, e.g., **E223/2/8/1.2** Annex 1 - NC Objections to OCP Revised Annex 12 - Witness Statements, number 227.
[165] See, e.g., **E223/2/8/1.2** Annex 1 - NC Objections to OCP Revised Annex 12 - Witness Statements, number 265.
[166] See, e.g., **E223/2/8/1.2** Annex 1 - NC Objections to OCP Revised Annex 12 - Witness Statements, number 201.

ទោះបីជាការធ្វើតេស្តសាកពិសោធន៍អំពីភាពនៅជិតគ្នាបំផុត អាចឲ្យយកមកអនុវត្តបានក៏ដោយ ក៏ការជំទាស់មានលក្ខណៈទូលំទូលាយពេក ហើយថែមទាំងមិនមានការចង្អុលបង្ហាញភ័ស្តុតាងទៀត។ នៅក្នុងការជំទាស់ពុំមានការវែកញែកហេតុផលសមរម្យដូចជាអំពីអង្គហេតុ ឬក៏ព្រឹត្តការណ៍ដែលបង្ហាញពីសារៈសំខាន់ដែលចំបាច់ក្នុងការតម្រូវឲ្យត្រូវតែកោះហៅសាក្សីនោះទេ។

## *អំពីរចនាសម្ព័ន្ធ*

៧៦. អនុលោមតាមសំណើតាមផ្លូវច្បាប់ ដែលបានធ្វើឡើងនៅផ្នែក ទី II.១ និង៣ សហព្រះរាជអាជ្ញាជូនជាយោបល់ថា ការជំទាស់របស់មេធាវី នួន ជា ដែលថា មានកំណត់ហេតុស្តាប់ចម្លើយសាក្សីមួយចំនួនក្នុងចំណោមកំណត់ហេតុដែលបានស្នើសុំផ្តល់ជូន មិនអាចទទួលយកបាន ពីព្រោះរចនាសម្ព័ន្ធខាងរដ្ឋបាល ការប្រាស្រ័យទាក់ទង ឬខាងយោធាមិនមានសុពលភាព[167]។ ឧទាហរណ៍ដូចជាមេធាវី នួន ជា បានជជែកតវ៉ាថា ឯកសារនានាដែលរៀបរាប់ អំពី “រចនាសម្ពន្ធនៃសិទ្ធិអំណាច”[168], “ការរៀបចំនៅថ្នាក់តំបន់ និងភូមិភាគ”[169] និងការតភ្ជាប់របស់មជ្ឈិមទៅនឹងភូមិភាគ និងទៅនឹង ចំការកៅស៊ូ និងស្រែអំបិល”[170]មិនអាចទទួលយកបានទេពីព្រោះវាទាក់ទងទៅនឹងភ័ស្តុតាង “ជារចនាសម្ព័ន្ធ”។ អង្គជំនុំជម្រះសាលាដំបូង មិនបានចាត់ទុក ភ័ស្តុតាង “រចនាសម្ព័ន្ធ” ថាជាភ័ស្តុតាង សក្ខីកម្មជាលាយលក្ខណ៍អក្សរនោះឡើយ។ផ្ទុយទៅវិញ អង្គជំនុំជម្រះបានទទួលស្គាល់ថា យុត្តិសាសស្ត្ររបស់បណ្តាតុលាការ*ពិសេស*នានា មិនបានទោរទន់ទៅរកការទប់ស្កាត់កុំឲ្យទទួលយកនូវភ័ស្តុតាងកំណត់ហេតុស្តាប់ចម្លើយសាក្សីដែលមាននៅក្នុងភ័ស្តុតាងស្តីពីរចនាសម្ពន្ធនៃការប្រាស្រ័យទាក់ទង គោលនយោបាយ និងអត្ថិភាពនៃផែនការឧក្រិដ្ឋកម្មរួមនោះឡើយ[171]។

## *ការជំទាស់ដោយសារភាពលម្អៀងរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា*

៧៧. ក្រុមមេធាវីការពារក្តីបានចោទប្រកាន់ថា ម្ចាស់នៃរាល់កំណត់ហេតុស្តាប់ចម្លើយទាំងអស់នេះដែលប្រមូលចងក្រងបានដោយមជ្ឈមណ្ឌលឯកសារកម្ពុជា (DC Cam) តោងតែត្រូវបានធ្វើការសួរដេញ

[167] See Annex B, part IV.
[168] See, e.g., **E223/2/8/1.2** Annex 1 - NC Objections to OCP Revised Annex 12 - Witness Statements, number 188.
[169] See, e.g., **E223/2/8/1.2** Annex 1 - NC Objections to OCP Revised Annex 12 - Witness Statements, number 188.
[170] See, e.g., **E223/2/8/1.2** Annex 1 - NC Objections to OCP Revised Annex 12 - Witness Statements, number 189.
[171] **E96/7** Statements Decision, at para 21.

ដោលដោយភាគីបដិបក្ស ពីព្រោះបេសកកម្មរបស់ DC Cam គឺមិនមែនគ្រាន់តែបង្កើតនូវសំណុំឯកសារជាប្រវត្តិសាស្ត្រតែប៉ុណ្ណោះនោះទេ ប៉ុន្តែដើម្បីចងក្រងភ័ស្តុតាងប្រឆាំងនឹងជនជាប់ចោទផងដែរ ហើយដោយសារតែអ្នកធ្វើសម្ភាសន៍របស់ DC Cam បានខកខានមិនបាន "ស៊ើបអង្កេតអំពីការទទួលខុសត្រូវរបស់មន្ត្រីថ្នាក់ក្រោមនានាដើម្បីអាចឲ្យជឿទុកចិត្តបាន" [172]។ ពួកគេថែមទាំងបានចោទ DC Cam អំពី "ការជឿជាលក្ខណៈស្ថាប័នលើភាពមានទោសរបស់ នួន ជា" [173] ។ នេះគឺជាចំណុចចុងក្រោយគេបំផុតមួយ នៅក្នុងខ្សែដ៏វែងនៃការវាយប្រហារដោយពុំមានមូលដ្ឋានត្រឹមត្រូវទៅលើស្ថាប័នមួយដែលការងាររបស់ស្ថាប័ននោះ គឺដើម្បីប្រមូលចងក្រង និងរក្សាទុកនូវប្រវត្តិសាស្ត្រអំពីរបបកម្ពុជាប្រជាធិបតេយ្យ និងកត់ទុកនូវការចងចាំនានាទាំងខាងជនរងគ្រោះ និងទាំងខាងចារី គឺគ្មានអ្វីផ្សេងក្រៅពីប្រវត្តិសាស្ត្រនោះឡើយ។

៧៨. សហព្រះរាជអាជ្ញាកត់សំគាល់ឃើញថា អង្គជំនុំជម្រះបានសម្រេចរួចហើយថាកំណត់ហេតុស្តាប់ចម្លើយទាំងឡាយដែលប្រមូលបានមកដោយ DC Cam និងអ្នកសិក្សាស្រាវជ្រាវដទៃទៀតដែលនៅក្រៅពី អវតក គឺអាចឲ្យទទួលយកបាន ហើយអាចឲ្យដាក់នៅចំពោះមុខ អវតក បាន ទោះបីជាចម្លើយទាំងនោះមិនអាចមានសិទ្ធិត្រូវបានទទួលការសន្មតថា ជាចម្លើយសាក្សីដែលគួរឲ្យជឿទុកចិត្តដែលផ្តល់ដោយ កសចស នោះក៏ដោយ[174]។ អង្គជំនុំជម្រះបានបញ្ជាក់ថាសញ្ញាបង្ហាញអំពីភាពគួរឲ្យជឿទុកចិត្តអាច "ជួយដល់អង្គជំនុំជម្រះនៅក្នុងការធ្វើការវាយតម្លៃរបស់ខ្លួនអំពីថា តើភ័ស្តុតាងដែលជាបញ្ហានោះបំពេញបានគ្រប់តាមលក្ខណៈវិនិច្ឆ័យដូចដែលមានចែងនៅក្នុងវិធាន ៨៧(៣)នៃវិធានផ្ទៃក្នុងដែរឬទេ? និងតម្លៃជាភវនីយភាព និងស្ថានទម្ងន់ដែលអាចតម្រូវឲ្យពេលផ្តល់ឲ្យភ័ស្តុតាងនេះ" [175] ។ មានសញ្ញាបង្ហាញជាច្រើនអំពីភាពគួរឲ្យជឿទុកចិត្តដែលភ្ជាប់គ្នានឹង កំណត់ហេតុស្តាប់ចម្លើយនានាដែលបានដកស្រង់ដោយអ្នកសិក្សាស្រាវជ្រាវរបស់ DC Cam ហើយដែលក្នុងនោះរួមមាន៖ ឯករាជ្យភាពរបស់ DC Cam និងបេសកកម្មរបស់មជ្ឈមណ្ឌលនេះ។ ប្រការដែលកំណត់ហេតុស្តាប់ចម្លើយដែលស្រង់ដោយ DC Cam គឺជាការធ្វើប្រតិចារិកដែលដូចគ្នាគ្រប់ម៉ាត់ទៅនឹងខ្សែអាត់ថតសម្លេងការធ្វើសម្ភាសន៍។ ខ្លឹមសារនៃកំណត់ហេតុស្តាប់ចម្លើយសាក្សីផ្ទាល់ ដែលនៅក្នុងនោះពុំមានសញ្ញាបង្ហាញ

---

[172] ការជំទាស់របស់ នួន ជា ចុះថ្ងៃទី២៦ មេសា ២០១៣, កថាខណ្ឌទី ៤០-៤១។

[173] ដូចគ្នានឹងខាងលើ, កថាខណ្ឌទី ៤០។

[174] សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌទី២៩។

[175] *ដូចគ្នានឹងខាងលើ។*

អំពីការប្រើប្រាស់ល្បិចកល ឬលំអៀងទេនោះ គឺមានលក្ខណៈលំអិត និង ទូលំទូលាយជាទីបំផុត។ សហព្រះរាជអាជ្ញា សូមកត់សំគាល់ថា អង្គជំនុំជម្រះកាលពីមុនបានសម្រេចថា ឯកសារទាំងឡាយ ដែលទទួលនបានមកពីបណ្ណសារដ្ឋានរបស់ DC Cam គឺអាចមានសិទ្ធិត្រូវបានសន្មតថាមានការជាប់ទាក់ទង និងគួរឲ្យជឿទុកចិត្ត ដែលក្នុងនោះរួមទាំងមានយថាភាពផង[176]។

៧៩. ងាកមកមើលអំពីការចោទប្រកាន់នានារបស់ក្រុមមេធាវីការពារក្តីប្រឆាំងនឹង DC Cam វិញ សហព្រះរាជអាជ្ញាកត់សំគាល់ថា នៅក្នុងអម្លុងពេនៃការផ្តល់សក្ខកម្មរបស់ខ្លួននៅចំពោះមុខអង្គជំនុំជម្រះ ទាំងនាយក[177] និងទាំងនាយករង[178]នៃ DC Cam បានផ្តល់នូវភ័ស្តុតាងដែលគួរឲ្យជឿទុកចិត្តអំពី

---

[176] ឯកសារលេខ **E185** សេចក្តីសម្រេចលើការជំទាស់ទៅនឹង ឯកសារនានាដែលបានស្នើសុំដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ដែលនៅក្នុងឧបសម្ព័ន្ធរបស់សហព្រះរាជអាជ្ញាពី ក១-ក៥ និងទៅនឹងឯកសារនានាដែលបានលើកសំអាងនៅក្នុងកថាខណ្ឌនានានៃដីកាដំណោះស្រាយ ដែលពាក់ព័ន្ធទៅនឹងផ្នែកពីរដំបូងគេនៃវគ្គសវនាការលើសំណុំរឿងលេខ00២០1/, ចុះថ្ងៃទី៩ មេសា ២០១២, ត្រង់កថាខណ្ឌទី២៨។

[177] ឯកសារលេខ **E1/37.1** ប្រតិចារិក, ឆាង យុគ, ថ្ងៃទី១ ខែកុម្ភៈ ២០១២, ត្រង់ទំព័រទី១៤ (ដែលនិយាយថា៖ "គោលបំណងនៃការបង្កើតឯកសារនេះគឺដើម្បីចងក្រងឯកសារ ដើម្បីការផ្សះផ្សារ អ៊ីចឹងដើម្បីការផ្សះផ្សារនេះ យើងមានគោលបំណងជាចម្បងរបស់យើង ក៏ប៉ុន្តែដើម្បីការផ្សះផ្សារយើងមានគំនិតបីដែលយើងធ្វើ។ បើនិយាយឲ្យច្បាស់ការចងក្រងឯកសារនេះគឺដើម្បីសិក្សាអតីតកាល។ ហើយដើម្បីផ្សះផ្សារអតីតកាល យើងមានកម្មវិធី១បី៖ទីមួយ យើងជឿជាក់ថាពេលដែលខ្ញុំប្រើពាក្យយើង គឺទាំងអស់គ្នានៅក្នុងមជ្ឈមណ្ឌលឯកសារកម្ពុជា។គឺយើងចង់ឲ្យមានតុលាការមួយ ដើម្បីរកការពិតដើម្បីផ្តល់សេចក្តីវិនិច្ឆ័យចុងក្រោយអំពីអ្វីដែលកើតឡើងពីអតីតកាល។ទីពីរ គឺយើងចង់ឲ្យសិស្សានុសិស្សក្មេងទាំងអស់ជំនាន់ក្រោយចងចាំ ហើយបានរៀនសូត្រ។ហើយទីបី ចង់ឲ្យមានកន្លែងមួយ ជាលក្ខណៈអចិន្ត្រៃយ៍ ដើម្បីទប់ស្កាត់អំពើប្រល័យពូជសាសន៍នេះកុំឲ្យត្រឡប់មកវិញ។ត្រង់ទំព័រ១១៦(និយាយថា៖ "ខ្ញុំគិតថា ការសម្រេចរបស់យើងក្នុងការទប់ស្កាត់អំពើរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរ អំពើផ្សេងៗនេះគឺជាការសម្រេចចិត្តមួយ ដែលយើងមិនបានកែប្រែទេ។ ហើយយើងយល់ថា ការធ្វើបែបនេះគឺឈានជួយទៅដល់ ការចងចាំ ការទប់ស្កាត់ ការផ្សះផ្សារជាតិ។ វាមិនអាចប៉ះពាល់ដល់ឯកសារទេ")។

[178] **E1/31.1** ប្រតិចារឹក, វ៉ាន់ថាន់ ដារ៉ាពៅ, ២៣ មករា ២០១២, នៅត្រង់ទំព័រទី៦ (ដោយបានថ្លែងថា "មជ្ឈមណ្ឌលឯកសារ គឺជាអង្គការក្រៅរដ្ឋាភិបាល ជាអង្គការស្រាវជ្រាវឯករាជ្យ ជាអង្គការដែលមិនរកប្រាក់កម្រៃ និងមានបេសកកម្មច្បាស់លាស់។ គឺទីមួយ គឺយើងប្រមែប្រមូល និងចងក្រងឯកសារនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ និងទីពីរគឺយើងផ្តល់ឯកសារដល់អ្នកទាំងឡាយណាដែលចង់ស្វែងរកយុត្តិធម៌ដល់អ្នកដែលរស់រានមានជីវិតពីរបបកម្ពុជាប្រជាធិបតេយ្យ តាមរយៈការផ្តល់ឯកសារនេះតែម្តង")។ នៅត្រង់ទំព័រទី២៥ ("បាទចំពោះគោលបំណងនៃមជ្ឈមណ្ឌលឯកសារកម្ពុជានេះ គឺខ្ញុំបាទសូមបញ្ជាក់ម្តងទៀតថា មជ្ឈមណ្ឌលឯកសារកម្ពុជាមានគោលដៅសំខាន់ពីរ។ គឺទីមួយ គឺប្រមែប្រមូលចងក្រងឯកសារទាក់ទងទៅនឹងរបបកម្ពុជាប្រជាធិបតេយ្យ ដើម្បីបម្រើដល់ផ្នែក ប្រវត្តិសាស្ត្រ និងការចងចាំនៃរបបកម្ពុជាប្រជាធិបតេយ្យ។ ហើយគោលបំណងទីពីរ គឺការផ្តល់ជូនឯកសារដល់អ្នកទាំងឡាយដែលមានបំណងចង់ស្វែងរកនូវយុត្តិធម៌សម្រាប់អ្នករស់រានមានជីវិត ក៏ដូចជាការស្វែងរកនូវសាច់ញាតិក្រុមគ្រួសារដែលបានបាត់បង់នៅក្នុង

ភាពឯករាជ្យរបស់ DC Cam និងការផ្តោតរបស់មជ្ឈមណ្ឌលនេះទៅលើការប្រមូលចងក្រងឱ្យបាន ត្រឹមត្រូវ និងដែលអាចឱ្យជឿទុកចិត្តបាននូវព័ត៌មានប្រវត្តិសាស្ត្រស្តីពីរយៈកាលរបស់កម្ពុជាប្រជាធិបតេយ្យ ដោយគ្មានការភ័យខ្លាច ឬការកាន់ជើង។

៨០. ក្នុងពេលដែលមេធាវីការពារក្តីសួរឆ្លងទៅសាក្សីគឺ លោក ឆាំង ដែលជានាយកនៃមជ្ឈមណ្ឌល DC Cam លោកត្រូវបានសួរសំណួរជាច្រើនដែលគេគិតថាជាភាពលំអៀងចំពោះ នួន ជា និងមេដឹកនាំកម្ពុជាប្រជាធិបតេយ្យផ្សេងទៀត។ លោក ឆាំង បានបដិសេធនូវការលើកឡើងណាមួយអំពីភាពលំអៀង និងបានផ្តល់សក្ខីកម្មថា តាមពិត DC Cam បានផ្តល់ដោយស្ម័គ្រចិត្តនូវឯកសារដែលពាក់ព័ន្ធនឹង នួន ជា ទាំងអស់ដល់មេធាវីការពារក្តី ហើយបន្ទាប់មកក៏បានបញ្ជូនឯកសារសម័យកម្ពុជាប្រជាធិបតេយ្យបន្ថែមទៀតដល់មេធាវីការពារក្តី ជាការឆ្លើយតបទៅតាមសំណើរបស់ប្រធានអង្គភាពគាំពារការការពារក្តី[179]។ គាត់ក៏បានផ្តល់សក្ខីកម្មផងដែរថា នៅទូទាំងមួយជីវិតនៃ អ.វ.ត.ក សេវាកម្ម និងបណ្ណសាររបស់ DC Cam អាចឱ្យមេធាវីការពារក្តីចូលទៅរកឯកសារបានដូចអ្នកចូលរួមនៅក្នុងកិច្ចដំណើរការនីតិវិធីដទៃទៀតដែរ[180]។ គ្មានភ័ស្តុតាងណាមួយនៃភ័ស្តុតាងនេះ ត្រូវបានតវ៉ាដោយមេធាវីការពារក្តីទេ។ នៅពេលសួរដោយមេធាវីការពារក្តី នួន ជា ថាតើ DC Cam ធ្លាប់បានផ្តោតទៅលើការប្រមូលភ័ស្តុតាងដែលនឹងមានការជាប់ជំពាក់នឹងបុគ្គលជាក់លាក់ណាមួយនោះ លោក ឆាំង បានឆ្លើយថា "យើងមិនប្រើពាក្យថា "ភ័ស្តុតាង"ទេ។ ចំពោះយើង យើងស្វែងរកការពិត។ ខ្ញុំមិនដឹងថា

---

របបកម្ពុជាប្រជាធិបតេយ្យ")។ នៅត្រង់ទំព័រទី ៦៥-៦៦ (ដោយបានថ្លែងថា "ជាទូទៅ ហិរញ្ញប្បទានដែលបានផ្តល់ដោយប្រទេសម្ចាស់ជំនួយ ដោយម្ចាស់ជំនួយផ្សេងៗ គឺអត់មានលក្ខខណ្ឌអីដែលដាក់មកមជ្ឈមណ្ឌលឯកសារកម្ពុជាទេ។ គឺមជ្ឈមណ្ឌលឯកសារកម្ពុជាជាអ្នកសម្រេច ជាអ្នកធ្វើការងារដោយផ្ទាល់ខ្លួនៗ ដោយឯករាជ្យតែម្តង។ ... មជ្ឈមណ្ឌលឯកសារកម្ពុជាមិនបានទទួលជំនួយជាថវិកា (sic) ពីរដ្ឋាភិបាលកម្ពុជាទេ ប៉ុន្តែមជ្ឈមណ្ឌលឯកសារកម្ពុជាបានទទួលជំនួយឧបត្ថម្ភជាការអនុញ្ញាតឱ្យមជ្ឈមណ្ឌលឯកសារកម្ពុជាបានចុះទៅស្រាវជ្រាវគ្រប់ទីកន្លែងនៅក្នុងប្រទេសកម្ពុជា។ ... យើងមិនដែលទទួលការបញ្ជា (...) អ្វីមួយពីរដ្ឋាភិបាលទេ ក្រៅតែពីការអនុញ្ញាតឱ្យមជ្ឈមណ្ឌលឯកសារកម្ពុជាបានមានសិទ្ធិចុះធ្វើការស្រាវជ្រាវគ្រប់ទីកន្លែងទាំងអស់នៅក្នុងប្រទេសកម្ពុជា ក៏ដូចជានៅក្រៅប្រទេសកម្ពុជា")។ នៅត្រង់ទំព័រទី ៦៩ (ដោយបានថ្លែងថា "ខ្ញុំយល់ថា ទីមួយ គឺយើងមានឯកសារបង្ហាញច្បាស់លាស់។ ទីពីរ គឺយើងបានបង្ហាញពីគោលបំណងរបស់យើង ដែលជាអង្គការ (sic) មួយចងក្រងឯកសារដើម្បីបម្រើដល់ការចងចាំ និងប្រវត្តិសាស្ត្រនៃកម្ពុជាប្រជាធិបតេយ្យ")។ នៅត្រង់ទំព័រទី ៩៧ (ដោយបានថ្លែងថា "ចំណុចសំខាន់គឺថា មជ្ឈមណ្ឌលឯកសារកម្ពុជាមិនធ្វើការវិភាគទៅលើឯកសារដែលខ្លួនប្រមែប្រមូល និងទទួលបានទេ។ គឺឯកសារមកយ៉ាងដូចម្តេច គឺនៅជាឯកសារអ៊ីចឹង គឺអ្នកដែលទទួលយកទៅ ប្រើប្រាស់ធ្វើការវិភាគខ្លួនឯង វាយតម្លៃ ធ្វើការវិភាគ ធ្វើការសិក្សាខ្លួនឯង គឺយើងមិនបានធ្វើការវិនិច្ឆ័យទៅលើឯកសារនេះទេ")។

[179] **E1/38.1** ប្រតិចារឹក, ឆាំង យុ, ២ កុម្ភៈ ២០១២, ត្រង់ទំព័រទី៨២។

[180] **E1/37.1** ប្រតិចារឹក, ឆាំង យុ, ១ កុម្ភៈ ២០១២, ត្រង់ទំព័រទី៧៣។

លោកពេញចិត្តនឹងហៅថា ភ័ស្តុតាងឬអត់នោះទេ។ ប៉ុន្តែសម្រាប់យើងខ្ញុំ យើងចង់ដឹងការពិត”[181]។ នៅពេលសួរថាតើ DC Cam នឹងប្រមូលភ័ស្តុតាងដែលអាចនឹងសម្រាលដល់ពិរុទ្ធរបស់ បកក ចំពោះអំពើយុងឃ្នងទាំងឡាយណាមួយដែលបានកើតឡើងនៅក្នុងប្រទេសកម្ពុជា ក្នុងសម័យទសវត្សរ៍ ១៩៧០ ដែរឬទេ គាត់បានឆ្លើយថា វាមិនអាចជៀសរួចទេ នៅក្នុងន័យស្រប និងបានបញ្ជាក់អះអាងថា ភ័ស្តុតាងដូច្នេះតាមពិត ត្រូវបានប្រមូលដោយ DC Cam[182]។ ជាថ្មីម្តងទៀត ចំណុចនេះមិនត្រូវបាន មេធាវីការពារក្តីតវ៉ាទេ។

៨១. ដោយប្រឆាំនឹងកំណត់ហេតុនេះ ការចោទប្រកាន់ដែលគ្មានមូលដ្ឋានច្រំដែលៗរបស់មេធាវីការពារក្តី ប្រឆាំងនឹង DC Cam គួរត្រូវបានបដិសេធចោលយ៉ាងជាក់ស្តែងដោយតុលាការនេះ។ មេធាវីការពារក្តី មានឱកាសយ៉ាងច្រើនសន្ធឹកសន្ធាប់ដើម្បីដេញដោលសាក្សី និងតវ៉ាលើឯកសារនានារបស់ DC Cam ដែលពួកគាត់ប្រមូលបាន។ គេមិនអាចចង្អុលទៅរកឧទាហរណ៍ណាមួយអំពីកំណត់ហេតុ ឬភ័ស្តុតាង ដទៃទៀតដែលបានប្រមូលដោយ DC Cam នាំឲ្យមានភាពមិនអាចជឿទុកចិត្តបាន តាមរយៈការ លំអៀង ឬក្នុងទម្រង់នៃភាពមិនប្រក្រតីណាមួយផ្សេងទៀតឡើយ។ តាមពិត គេខកខានមិនបានតវ៉ានៅ ក្នុងតុលាការចំពោះសក្ខីកម្មរបស់ លោក ឆាំង ថា DC Cam ប្រមូលភ័ស្តុតាងដោយគ្មានលំអៀង និង ផ្តោតទៅលើតែការផ្តល់នូវកំណត់ហេតុប្រវត្តិសាស្ត្រមួយដែលត្រឹមត្រូវប៉ុណ្ណោះ។

៨២. សហព្រះរាជអាជ្ញាសន្និដ្ឋានថា កំណត់ហេតុ DC Cam ទាំងអស់ដែលបានដាក់បញ្ចូលក្នុង ឧបសម្ព័ន្ធ ១២ ដែលបានកែសម្រួលឡើងវិញ គួរត្រូវបានទទួលយកដោយហេតុថា កំណត់ហេតុទាំងនោះពាក់ព័ន្ធ ទៅនឹងសំណុំរឿង 00២/១ ហើយមានកម្រិតនៃភាពជឿទុកចិត្តបានយ៉ាងខ្ពស់។

៨៣. មេធាវីការពារក្តី នួន ជាបានជំទាស់ទៅនឹងការទទួលយកនូវប្រតិចារិកនានានៃសំណុំរឿងលេខ00១ ដោយផ្អែកលើហេតុផលជាច្រើន។ ទីមួយ ពួកគេបានពោលអះអាងថា ប្រតិចារិកទាំងនេះមិនត្រូវបាន ដាក់បញ្ចូលនៅក្នុងសំណើរបស់សហព្រះរាជាអាជ្ញានោះទេ (ឯកសារលេខ E96/8.3) ហើយថា ប្រតិចារិកទាំងនេះគួរតែត្រូវបានដកចេញពីព្រោះមិនមានការជូនដំណឹងឲ្យបានគ្រប់គ្រាន់[183]។ ការបដិ សេធនេះ គួរតែត្រូវបានបដិសេធចោល ពីព្រោះប្រតិចារិកទាំងឡាយត្រូវបានដាក់បញ្ចូលនៅក្នុង ឧបសម្ព័ន្ធច្បាប់ដើមលេខ១១ កាលពីក្នុងខែមេសាឆ្នាំ២០១១ រួចហើយ។ ទីពីរ មេធាវីការពារក្តី នួន ជា បានពោលអះអាងថា ការទទួលយកនូវប្រតិចារិកនានានៃសំណុំរឿងលេខ00១នៅក្នុងករណីនេះ គឺជា

---

[181] **E1/38.1** ប្រតិចារឹក, ឆាំង យុ, ២ កុម្ភៈ ២០១២, ត្រង់ទំព័រទី៨៥។

[182] **E1/38.1** ប្រតិចារឹក, ឆាំង យុ, ២ កុម្ភៈ ២០១២, ត្រង់ទំព័រទី៦៨-៦៩។

[183] E.g., **E223/2/8/1.1** Annex 3: NC Objections to OCP Annex 11 - Case 001 Trial Transcripts, entries 1, 2, 7 – 12.

ការរំលោភទៅលើសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបាននូវតុលាការមួយដែលឯករាជ្យ និងមិនលំអៀង ឬនូវសិទ្ធិស្មើភាពគ្នានៅចំពោះមុខតុលាការ។ ការជំទាស់នេះ មិនមានមូលដ្ឋានត្រឹមត្រូវទេ។ សហព្រះរាជអាជ្ញាសូមធ្វើការកត់សំគាល់ថា នៅក្នុងសេចក្តីសម្រេចដែលបដិសេធលើពាក្យសុំរបស់មេធាវីការពារក្តី ដើម្បីប្តឹងជំទាស់ចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូង។ អង្គជំនុំជម្រះមួយដែលបានបង្កើតឡើងដាច់ដោយឡែកបានសម្រេចថា ប្រការដែលអង្គជំនុំជម្រះសាលាដំបូងបានធ្វើជាអធិបតីនៅក្នុងការជំនុំជម្រះក្តីលើសំណុំរឿងលេខ០០១ ថាមិនមានមូលដ្ឋានមានសុពលភាពសម្រាប់ការចោទប្រកាន់អំពីភាពលំអៀងរបស់អង្គជំនុំជម្រះនេះទេ។ ដូចបានចង្អុលបង្ហាញនៅក្នុងនៅក្នុងសេចក្តីសម្រេចនោះ សំណុំរឿងភាគច្រើននៅឯតុលាការឧក្រិដ្ឋកម្មអន្តរជាតិនានាត្រូវបានធ្វើការជំនុំជម្រះនៅចំពោះមុខអង្គចៅក្រម ដែលបានធ្វើជាអធិបតីលើករណីរឿងដែលទាក់ទងទៅនឹងជាសំខាន់ទៅនឹងអង្គហេតុដដែល[184]។ ជាការឆ្លើយតបទៅនឹងការពោលអះអាងថា ចៅក្រមទាំងឡាយនឹងត្រូវជួបការលំបាក ឬការអាម៉ាស់ក្នុងការឈានទៅដល់ការធ្វើសេចក្តីសន្និដ្ឋានបញ្ចប់ដែលមានភាពស្របគ្នាជាមួយនឹងការរកឃើញរបស់ខ្លួន នៅក្នុងសំណុំរឿងលេខ០០១។ សេចក្តីសម្រេចបានសម្រេចដូច្នេះថា៖ “ចៅក្រមនានានៅ អវតក ជាចៅក្រមដែលមានគុណវិឌ្ឍិខ្ពស់ និងជាអ្នកច្បាប់ដែលមានបទពិសោធន៍ និងជំនាញឯកទេសខាងផ្នែកច្បាប់ដែលចែងពីសិទ្ធអំណាច និងកាតព្វកិច្ចរបស់ភាគី (ច្បាប់សារធាតុ)។ អ្នកសង្កេតការឯករាជ្យបានជំរាបជូនអំពីរាល់កាលៈទេសៈ ដែលពាក់ព័ន្ធទាំងអស់ដែលមិនគួរធ្វើការស្មានដោយសើរៗថាចៅក្រមនានានឹងត្រូវ “អាម៉ាសមុខ” ដោយសារតែការអនុវត្តដោយស្មោះត្រង់នូវមុខងារតុលាការរបស់ខ្លួន”[185]។ ស្រដៀងគ្នានេះដែរ នៅទីនេះ អ្នកសង្កេតការឯករាជ្យនឹងមិនមានការមន្ទិលសង្ស័យទេ អំពីសមត្ថភាពរបស់ចៅក្រមទាំងឡាយរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការយកជំនាញឯកទេសខាងតុលាការរបស់ខ្លួន និងមានទឹកចិត្តស្រស់ថ្លា ដើម្បីនឹងការពិនិត្យមើលប្រតិចារិកនានានៃសំណុំរឿងលេខ០០១ នៅក្នុងបរិបទនៃសំណុំរឿងលេខ០០២។

៨៤. ការលើកឡើងនូវអំណះអំណាងថា ការដែលអនុញ្ញាតឱ្យយកប្រតិចារិកនៃសំណុំរឿងលេខ០០១ ទៅប្រើនៅក្នុងសំណុំរឿងលេខ០០២ ជាការរំលោភទៅលើសិទ្ធិក្នុងការទទួលបាននូវសិទ្ធិអំណាចស្មើគ្នានៅចំពោះមុខតុលាការ តាមតក្កសាស្ត្រ គឺមិនមានភាពស៊ីសង្វាក់គ្នាជាមួយនឹងអត្ថិភាពនៃនីតិវិធីដែលចែងអំពីការទទួលយកប្រតិចារិកដោយផ្ទាល់តែម្តង។ នេះគឺជាលក្ខណៈពិសេសជារួមរបស់តុលាការ

[184] **E55/4** Decision on Ieng Thirith, Nuon Chea and Ieng Sary's Applications for Disqualification of Judges Nil Nonn, Silvia Cartwright, Ya Sokhan, Jean-Marc Lavergne and Thou Mony, 23 March 2011 (“Decision on Disqualification”), at para. 20.
[185] **E55/4** Decision on Disqualification, at para. 17 (internal citations omitted).

ឧក្រិដ្ឋកម្មនានាដែលការិយាល័យរបស់សហព្រះរាជអាជ្ញា គឺជាភាគីមួយនៅក្នុងគ្រប់រាល់ការជំនុំជម្រះក្តីទាំងអស់។ បើសិនជាដូចដែលមេធាវីរបស់ នួន ជា បានពោលអះអាងនោះការទទួលយកនូវប្រតិចារិកកាលពីកិច្ចដំណើរការនីតិវិធីកាលពីមុនមក មុខជារំលោភទៅលើភាពមានសិទ្ធអំណាចស្មើភាពគ្នានៅចំពោះមុខតុលាការទៅហើយ ពីព្រោះមេធាវីការពារក្តីមិនបានចូលរួមនៅក្នុងកិច្ចដំណើរការនីតិវិធីកាលពីមុននៅទេ តុលាការមិនអាចទទួលយកនូវប្រតិចារិកបែបនេះទាល់តែសោះ។ នេះគឺដល់ពេលដែលនឹងធ្វើមោឃៈភាព ចំពោះគោលបំណងនៃវិធាន៩២ស្ទួននៃវិធានផ្ទៃក្នុងដែលទាក់ទងនឹងប្រតិចារិកនេះវិញម្តង។

៨៥. អង្គជំនុំជម្រះបានទទួលយករួចហើយនូវប្រតិចារកមួយចំនួនដែលមកពីសំនុំរឿងលេខ០០១។ អង្គជំនុំជម្រះក៏បានសម្រេចផងដែរថា ការពិតដែលប្រតិចារិកមកពីការជំនុំជម្រះក្តីលើកមុនត្រូវបានទទួលយកដោយមិនមានការចូលរួមរបស់ម្ចាស់ប្រតិចារិកនោះនឹងជះឥទ្ធិពល ទៅលើតម្លៃជាភស្តុតាងភាព និងស្ថានទម្ងន់ដែលបានផ្តល់ទៅឲ្យឯកសារទាំងនេះ[186]។ ហេតុនេះ ការទទួលយកនូវប្រតិចារិកនៃសំណុំរឿងលេខ០០១ គឺនឹងមិនរំលោភទៅលើភាពមានសិទ្ធិអំណាចស្មើភាពគ្នានៅចំពោះមុខតុលាការនោះទេ ក៏ប៉ុន្តែប្រការ ដែលកំណត់ហេតុស្តាប់ចម្លើយសាក្សីទាំងនេះត្រូវបានទទួលយកដោយមិនមានធ្វើការសួរដេញដោលដោយភាគីបដិបក្សចំពោះសាក្សីនោះ សហព្រះរាជអាជ្ញាបានទទួស្គាល់ការពិតថា អាចមានផលប៉ះពាល់ចំពោះតម្លៃជាភស្តុតាងភាពនិង ស្ថានទម្ងន់នៃកំណត់ហេតុស្តាប់ចម្លើយសាក្សីទាំងនេះដែលអង្គជំនុំជម្រះសាលាដំបូងបានផ្តល់ឲ្យ។

៨៦. ទី៣ ចំណែកឯការជំទាស់ចំពោះកំណត់ត្រាតាមរបៀបស្តេណូវិញ ដូចដែលបានលើកឡើងនៅក្នុងឧបសម្ព័ន្ធទី៣[187] របស់មេធាវី នួន ជា (ឧទាហរណ៍ដូចជា "វិសាលភាព", "*A&C (នួន ជា, គណៈកម្មាធិការមជ្ឈិម,គណៈកម្មាធិការអចិន្ត្រៃយ៍;ផ្សេងទៀត)*", "*រចនាសម្ពន្ធ័ (តួនាទីរបស់មជ្ឈិម)*")សហព្រះរាជអាជ្ញា លើកយោងទៅលើសេចក្តីសន្និដ្ឋានរបស់ខ្លួន ដូចជាទៅលើការល្បងពិសោធន៍ខាងអង្គច្បាប់ និងវិសាលភាពនៃការជំនុំជម្រះក្តី នៅក្នុងផ្នែកពីទីII.២.- ទីII.៤.ខាងលើ។ សហព្រះរាជអាជ្ញាក៏សំលើកឡើងផងដែរថា ការជំទាស់ទាំងឡាយ គួរតែត្រូវបានបដិសេធ ព្រោះដោយសារមានលក្ខណៈទូលំទូលាយពេក និងពុំមានភាពជាក់លាក់។ ជាចុងក្រោយ ដូចដែលបានលើកឡើងនៅក្នុងការដាក់ជូននូវឧបសម្ព័ន្ធទី១២ និង១៣ដែលបានពិនិត្យឡើងវិញរួច សហព្រះរាជអាជ្ញា ត្រៀមខ្លួននឹងអនុវត្ត

[186] **E96/7** Statements Decision, at para. 25.
[187] **E223/2/8/1.1** Annex 3: NC Objections to OCP Annex 11 - Case 001 Trial Transcripts.

តាមការចាត់ចែងរបស់អង្គជំនុំជម្រះ បើសិនជាអង្គជំនុំជម្រះកំណត់ថា ការយោងទៅលើអំពើ និងការប្រព្រឹត្តរបស់ជនជាប់ចោទនៅក្នុងប្រតិចារិកគួរត្រូវបានធ្វើការកោសលប់ចេញខ្លះនោះ[188]។

## IV - សេចក្តីសន្និដ្ឋាន

៨៧. ចំពោះមូលហេតុដូចបានលើកឡើងខាងលើនេះ សហព្រះរាជអាជ្ញាសូមស្នើដល់អង្គជំនុំជម្រះមេត្តា៖

ក. បដិសេធនូវការលើកឡើងរបស់មេធាវីការពារក្តីដែលថា អង្គជំនុំជម្រះតោងតែងអនុវត្តបានម៉ឺងមាត់តាមវិធាន៩២*ស្ទួន* នៃវិធានផ្ទៃក្នុង ទោះបីជាមានការខុសគ្នាពីនីតិវិធីរវាង អវតក និង តុលាការ*ពិសេស*នានានោះក៏ដោយ។

ខ. បញ្ជាក់ច្បាស់ថា ការសម្រេចរបស់ខ្លួនដែល នៅក្នុងក្របខណ្ឌនៃនីតិវិធីរបស់ អវតក រាល់កំណត់ហេតុស្តាប់ចម្លើយសាក្សីទាំងអស់ដែលមានភវនីយភាពត្រូវបានទទួលយក លើកលែងតែត្រឹមកម្រិតដែលនៅក្នុងកំណត់ហេតុទាំងនេះ មានភ័ស្តុតាងស្តីពីអំពើ និងការប្រព្រឹត្តរបស់ជនជាប់ចោទដូចដែលបានចោទប្រកាន់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះតែប៉ុណ្ណោះ។

គ. បញ្ជាក់ច្បាស់ថា កំណត់ហេតុស្តាប់ចម្លើយរបស់សាក្សីដែលបានទទួលមរណភាពទៅហើយ ឬដែលមិនអាចមានលទ្ធភាពមកផ្តល់សក្ខីកម្មតទៅទៀតបាន នឹងត្រូវបានទទួលយកដោយមិនបាច់ធ្វើការកោសលប់ចេញឡើយ។

ឃ. បញ្ជាក់ច្បាស់ថា កំណត់ហេតុស្តាប់ចម្លើយសាក្សីដែលមាននៅក្នុងភ័ស្តុតាងទាក់ទងទៅនឹងកូនចៅក្រោមបង្គាប់របស់ជនជាប់ចោទ ក៏ដូចជា រចនាសម្ព័ន្ធ ការប្រាស្រ័យទាក់ទង និងគោលនយោបាយផ្សេងៗរបស់ បកក គឺអាចទទួលយកបាន។

ង. សម្រេចថា ការទទួលយកនូវគំរូតំណាងមួយឲ្យកំណត់ហេតុស្តាប់ចម្លើយសាក្សីទាក់ទងនឹងទីតាំងឧក្រិដ្ឋកម្មនៅក្នុងសំណុំរឿងលេខ00២/0១ ដែលមិនបានដាក់បញ្ចូលទៅក្នុងសំណុំរឿងលេខ 00២/0១ ដើម្បីគោលបំណងក្នុងការបង្កើតនូវធាតុផ្សំផ្សេងៗ ដូចជា ការប្រាស្រ័យទាក់ទងគោលនយោបាយ និងការវាយប្រហារដ៏ទូលំទូលាយ និងជាប្រព័ន្ធ។

[188] **E278** Co-Prosecutors' Submissions of Revised Annexes 12 and 13, paras. 21 - 23.

ច. ទទួលយកនូវរាល់កំណត់ហេតុស្ដាប់ចម្លើយសាក្សី ពាក្យបណ្ដឹង និងប្រតិចារិកទាំងអស់ដែលមានចុះនៅក្នុងបញ្ជីនៅក្នុងឧបសម្ពន្ធទី១១ និង ឧបសម្ព័ន្ធទី១២-១៣ ដែលបានពិនិត្យឡើងវិញរួច៕

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៣ | **លោក យ៉េត ចរិយ៉ា** សហព្រះរាជអាជ្ញារង | ភ្នំពេញ | |
| | **លោក** Andrew CAYLEY សហព្រះរាជអាជ្ញា | | |